សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំណាច និង ឯករាជ្យភាពរបស់ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឡេង ភ្រឹម**
**លី កុសល**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំចូលសិក្សា ២០១០
ជំនាន់ទី ១៩ ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អំណាច និង ឯករាជ្យភាពរបស់ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ឡោ ក្រឹម**

**លី កុសល**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **ឡោ ក្រឹម** និង ខ្ញុំបាទ **លី កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្ដែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត៖

- សូមលើកអញ្ជលីលំឱនកាយវាចារចិត្តគោរពដល់ លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្ដល់នូវសេចក្ដីស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកា ឲ្យកូនបានសិក្សារៀនសូត្ររហូតដល់បច្ចុប្បន្ននេះ។
- ឯកឧត្ដម **លុយ ចន្ធ្នា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចូលសិក្សានៅសាកលវិទ្យាល័យនេះ និងបង្ករលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀនផ្ដល់ការណែនាំ ថែមទាំងបានផ្ដល់ឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ។
- ថ្នាក់ដឹកនាំ បុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ករលក្ខណៈងាយស្រួល ដល់ការសិក្សារបស់យើងខ្ញុំ។
- សូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោក ដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងអំពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ លោកអ្នកមានគុណ ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមបានប្រកបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំង បួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទ **ឡោ ភ្រឹម** និង ខ្ញុំបាទ **លី កុសល** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស-និស្សិត ជាទីរាប់អាន ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

ក្នុងនាម ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី **អំណាច និងឯករាជ្យភាពរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** នេះឡើង ដោយត្រូវបានទទួលនូវការគាំទ្រ និងការជួយលើកទឹកចិត្តបង្ហាត់បង្ហាញកែតម្រូវយ៉ាងពេញទំហឹងពីសំណាក់លោកសាស្ត្រាចារ្យ **ហ៊ាខ ឡេខ** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ជាឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថ្មីថែមទៀត ដែលបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

ម៉្យាងវិញទៀត យើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះ យើងខ្ញុំរង់ចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់មិត្តអ្នកអានទាំងអស់គ្នាគ្រប់វិនាទី។

ជាទីបញ្ចប់នេះ សូមជូនពរដល់អ្នកអានគ្រប់រូបអោយជួបប្រទះតែនឹងភាពសុខដុមរមនារុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

សេចក្តីថ្លែងអំណរគុណ........................................ i
អារម្ភកថា........................................ ii
មាតិកា ........................................ iii

# សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ........................................ ២
២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ២
៣.គោលបំណងនៃការស្រាវជ្រាវ........................................ ៣
៤.ដែនកំណត់នៃការស្រាវជ្រាវ ........................................ ៣
៥.សារៈសំខាន់នៃការស្រាវជ្រាវ........................................ ៣
៦.វិធីសាស្រ្តនៃការស្រាវជ្រាវ........................................ ៣
   ៦.១.វិធីសាស្រ្តប្រមូលទិន្នន័យ ........................................ ៣
   ៦.២.វិធីសាស្រ្តវិភាគទិន្នន័យ........................................ ៤
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................ ៤

# ជំពូកទី ១
# ទស្សនៈទូទៅស្តីពីការបែងចែកអំណាច និង ឯករាជ្យភាព

១.១.និយមន័យ........................................ ៥
១.២.ការបែងចែកអំណាច ........................................ ៦
១.៣.ទ្រឹស្តីនៃការបែងចែកអំណាច........................................ ៧
១.៤.ការអនុវត្តន៍ការបែងចែកអំណាច ........................................ ៩
១.៥.ក្របខណ្ឌច្បាប់សម្រាប់ធានាឯករាជ្យភាពតុលាការ ........................................ ១០
   ១.៥.១.លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ........................................ ១០
   ១.៥.២.លិខិតបទដ្ឋានគតិយុត្តជាតិ........................................ ១២

# ជំពូកទី ២
# អំណាច និងឯករាជ្យភាពរបស់ព្រះរាជអាជ្ញា

២.១.លក្ខណៈសម្បត្តិរបស់ព្រះរាជអាជ្ញា ........................................ ១៤
   ២.១.១.ជំនាញវិជ្ជាជីវៈ ........................................ ១៤
   ២.១.២.ការជ្រើសរើស ........................................ ១៤
   ២.១.៣.ការបណ្តុះបណ្តាល ........................................ ១៤
   ២.១.៤.ការតែងតាំង........................................ ១៤

២.២.រចនាសម្ព័ន្ធ ..... ១៥
២.៣.ការគ្រប់គ្រង ..... ១៦
២.៤.ហិរញ្ញវត្ថុ ..... ១៧
២.៥.តួនាទី ..... ១៧
២.៥.១.ទទួលពាក្យបណ្ដឹង ..... ១៧
២.៥.២.បើកការស៊ើបសួរ ..... ១៧
២.៦.អំណាច ..... ១៨
២.៦.១.ការតម្កល់រឿងទុកឥតចាត់ការ ..... ១៨
២.៦.២.សេចក្ដីសម្រេចក្នុងការចោទប្រកាន់ ..... ១៩
២.៧.មុខងារនៃអង្គការអយ្យការ ..... ២១
២.៧.១.មុខងាររបស់អយ្យការនៅក្នុងរឿងព្រហ្មទណ្ឌ ..... ២១
២.៧.២.មុខងារនៅក្នុងការអនុវត្តសាលក្រមស្ថាពរ ..... ២២
២.៧.៣.ការធ្វើអធិការកិច្ចពន្ធនាគារ ..... ២៤
២.៨.គោលការណ៍សំខាន់នៃអង្គការអយ្យការ ..... ២៥
២.៨.១.អង្គឯកភាព ..... ២៥
២.៨.២.អង្គអវិភាគ ..... ២៦
២.៨.៣.អង្គឯករាជ្យ ..... ២៦
២.៨.៤.អង្គមួយមិនអាចបំបែកបាន ..... ៣៦
២.៨.៥.គោលការណ៍នៃការកត់សម្គាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការ ..... ២៦
២.៨.៦.ការមិនទទួលខុសត្រូវក្នុងជំនាញវិជ្ជាជីវៈ ..... ២៧
២.៩.គោលការណ៍នៃភាពមិនលម្អៀង ..... ២៧
២.៩.១.ឥរិយបថរបស់ព្រះរាជអាជ្ញាចំពោះជនជាប់ចោទ ..... ២៧
២.៩.២.ការចោទប្រកាន់ក្នុងផលប្រយោជន៍ច្បាប់ ..... ២៨
២.៩.៣.ទំនាស់ផលប្រយោជន៍ ..... ២៩
២.៩.៤.ការគោរព និង លើកស្ទួយដំណើរការត្រឹមត្រូវតាមនីតិវិធីច្បាប់ ..... ២៩
២.៩.៥.ការរើសអើងពូជសាសន៍ និងមតិនយោបាយ ..... ៣០
២.៩.៦. ការថ្លែងការណ៍ជាសាធារណៈ ..... ៣០
២.៩.៧.ចំណាត់ការនឹងការរំលោភអំណាចរបស់មន្ត្រីសាធារណៈ ..... ៣១
២.១០.ឯករាជ្យភាព ..... ៣១
២.១០.១.ឥទ្ធិពលផ្ទៃក្រៅ ..... ៣២

២.១០.២.ឥទ្ធិពលផ្ទៃក្នុង ........ ៣៣
២.១០.៣.ការប្រកាន់អាកប្បកិរិយាដែលញ៉ាំងឲ្យមានទំនុកចិត្តសាធារណៈ........ ៣៤
២.១០.៤.ភាពសត្យានុម័ត ........ ៣៥
២.១១.សុចរិតភាព ឬសេចក្តីទៀងត្រង់ ........ ៣៥
២.១២.សេចក្តីថ្លៃថ្នូរ និង ភាពស្អាតបាត ........ ៣៦
២.១២.១.ក្នុងជីវភាពឯកជន ........ ៣៦
២.១២.២.ក្នុងជីវភាពវិជ្ជាជីវៈ........ ៣៧

## ជំពូកទី ៣

## អំណាច និង ឯករាជ្យភាពរបស់ចៅក្រម

៣.១.លក្ខណៈសម្បត្តិរបស់ចៅក្រម ........ ៣៨
៣.១.១.ជំនាញវិជ្ជាជីវៈ........ ៣៨
៣.១.២.ការជ្រើសរើស ........ ៣៨
៣.១.៣.ការបណ្តុះបណ្តាល ........ ៣៩
៣.១.៤.ការតែងតាំង ........ ៣៩
៣.២.រចនាសម្ព័ន្ធ ........ ៤០
៣.៣.ការគ្រប់គ្រងរដ្ឋបាល ........ ៤១
៣.៤.ហិរញ្ញវត្ថុ ........ ៤២
៣.៥.ចៅក្រមស៊ើបសួរ ........ ៤២
៣.៥.១.សមត្ថកិច្ច ........ ៤២
៣.៥.២.តួនាទី ........ ៤៣
៣.៥.៣.ដីកាដំណោះស្រាយ ........ ៤៤
៣.៦.ចៅក្រមជំនុំជម្រះ ........ ៤៥
៣.៦.១.សមត្ថកិច្ច ........ ៤៥
៣.៦.២.តួនាទី ........ ៤៥
៣.៦.៣.សេចក្តីសម្រេចរបស់តុលាការ ........ ៤៦
៣.៧.ឯករាជ្យភាពរបស់តុលាការ ........ ៤៩
៣.៧.១.ឯករាជ្យស្ថាប័ន ........ ៤៩
៣.៧.២.ឯករាជ្យបុគ្គល ........ ៥០
៣.៨.គោលការណ៍ឯករាជ្យភាព ........ ៥១
៣.៨.១.ការប៉ុនប៉ង ដើម្បីធ្វើឲ្យមានឥទ្ធិពលដល់ចៅក្រម ........ ៥១

៣.៨.២.សកម្មភាពនយោបាយ...........................................................................................................៥១
៣.៩.គោលការណ៍អនាគតិ(ភាពមិនលម្អៀង)...........................................................................................៥២
៣.៩.១.អាកប្បកិរិយា និង ការធ្វើសវនាការ..................................................................................៥៣
៣.៩.២.ការស៊ើបអង្កេត ឬការស៊ើបសួររឿងក្តី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្តី.....៥៥
៣.៩.៣.ទំនាក់ទំនងវិជ្ជាជីវៈ សង្គម និងគ្រួសារ..................................................................................៥៦
៣.៩.៤. សកម្មភាពពាណិជ្ជកម្ម........................................................................................................៥៧
៣.៩.៥.អត្ថប្រយោជន៍ហិរញ្ញវត្ថុ ......................................................................................................៥៧
៣.៩.៦.ទំនាស់ផ្នែកផលប្រយោជន៍ ....................................................................................................៥៧
៣.១០.គោលការណ៍ភាពសុចរិត ..........................................................................................................៥៨
៣.១០.១.សុចរិតក្នុងតួនាទី .............................................................................................................៥៩
៣.១០.២.សុចរិតក្រៅតួនាទី..............................................................................................................៥៩
៣.១១.គោលការណ៍សេចក្តីថ្លៃថ្នូរ.........................................................................................................៦០
៣.១២.គោលការណ៍វិរិយភាព ..............................................................................................................៦០

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

១.សេចក្តីសន្និដ្ឋាន..........................................................................................................................៦១
២.អនុសាសន៍ ....................................................................................................................................៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយបានប្រកាន់យកនូវរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ដែលប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ដោយអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចត្រូវបានបែងចែកជា **បី** ដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

អំណាចតុលាការនៃព្រះរាជាណាចក្រកម្ពុជា ជាអំណាចឯករាជ្យ ដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ដោយអំណាចនេះគ្រប់ដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ តុលាការនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជា ពីរ ជាន់ គឺទី១-តុលាការជាន់ខ្ពស់ រួមមាន តុលាការកំពូល និងតុលាការឧទ្ធរណ៍ និងទី២-តុលាការជាន់ទាប រួមមាន សាលាដំបូងរាជធានី-ខេត្ត និងតុលាការយោធា ហើយនៅតាមសាលាជម្រះក្តីនីមួយៗត្រូវមានអគ្គអយ្យការ ឬអយ្យការនៅអមជានិច្ច។ រដ្ឋធម្មនុញ្ញក៏បានចែងបញ្ជាក់ផងដែរថា រាល់ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ហើយត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលបានអំណាចតុលាការនេះបានឡើយ ខណៈដែលមាត្រា ១៣១ថ្មី បានចែងថា មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ មាត្រា ១៣២ថ្មី នៃរដ្ឋធម្មនុញ្ញ បានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ហើយផ្តល់អាណត្តិដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីជួយព្រះអង្គក្នុងកិច្ចការនេះ។

ចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែមានអំណាច និងសេរីភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍វិជ្ជាជីវៈរបស់ខ្លួន ដោយពុំមានការជ្រៀតជ្រែកពីគ្រប់មជ្ឈដ្ឋានឡើយ។ អ្នកទាំងនោះត្រូវតែទទួលការការពារទាំងតាមផ្លូវច្បាប់ពីការវាយប្រហារ ការយាយី ឬការធ្វើទុក្ខទោស ទាំងតាមរយៈការអនុវត្តន៍ជាក់ស្តែងនៅពេលអនុវត្តនូវវិជ្ជាជីវៈរបស់ខ្លួន។

ប្រសិនបើចៅក្រមមិនអាចវាយតម្លៃអង្គហេតុ និងអនុវត្តច្បាប់ ប្រព័ន្ធយុត្តិធម៌នឹងក្លាយទៅជាអំណាចដែលធ្វើអ្វីស្រេចតែចិត្ត។ ប្រសិនបើព្រះរាជអាជ្ញា មិនទទួលបានការការពារនៅពេលអាយុជីវិតរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ដោយសារការងាររបស់ខ្លួន នោះភារកិច្ចធ្វើការចោទប្រកាន់របស់ខ្លួននឹងត្រូវបានរងផលប៉ះពាល់។ នេះ គឺជាការការពារពិសេសសម្រាប់ការបំពេញនូវការទទួលខុសត្រូវពិសេស។ នេះ គឺជាគោលការណ៍ស្តីពីឯករាជ្យភាព និងភាពមិនលម្អៀង។[១]

---

[១] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, សៀវភៅសិក្សាផ្នែកទី៣, ការពិចារណាពិស្តារផ្នែកគតិយុត្ត, "ប្រព័ន្ធតុលាការ", ភ្នំពេញ, ខែកក្កដា ឆ្នាំ២០០៤, ទំព័រទី២៦

ឥទ្ធិពលនៃអំណាចតុលាការ និងឯករាជ្យភាពពិតប្រាកដ វាបាននាំមកនូវយុត្តិធម៌ និងភាពស្របច្បាប់នៅក្នុងសង្គម ដែលនាំមកនូវជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ ភាពស្មើគ្នាចំពោះមុខច្បាប់ ព្រោះថា យុត្តិធម៌ពិតប្រាកដវាមានសភាពដូចជាទំហំអុកស៊ីសែនក្នុងលំហអាកាសដែលមនុស្សគ្រប់រូបមានតម្រូវការជាចាំបាច់បំផុតក្នុងជីវិតរស់នៅ។ កត្តាទាំងនេះហើយ ដែលនាំឲ្យសមាជិកសង្គមមួយ ឬប្រទេសជាតិមួយទទួលបាននូវសុខសន្តិភាព សុខដុមនីយកម្ម សាមគ្គីភាពដ៏រឹងមាំដែលនាំឲ្យសង្គមជាតិមានការអភិវឌ្ឍន៍មួយប្រកបដោយភាពរឹងមាំ។

មានកត្តាជាច្រើនដែលបានសិក្សាស្រាវជ្រាវទាក់ទងទៅនឹងអំណាច និង ឯករាជ្យភាពរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត នេះដោយព្យាយាមទាញហេតុផល ដើម្បីរកឲ្យឃើញថា តើអ្វីទៅជាអំណាច និងអ្វីទៅជាឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា ជាពិសេសអត្ថប្រយោជន៍នៃអំណាចឯករាជ្យភាពរបស់តុលាការ និងអយ្យការ ដែលយើងខ្ញុំបានស្រាយបញ្ជាក់នៅក្នុងសារណានេះ។

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

អំណាចតុលាការ ជាអំណាចមួយឯករាជ្យដាច់ដោយឡែកចេញពីស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។ អំណាចតុលាការត្រូវជានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋព្រមទាំងគ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិ អាចគ្រប់គ្រងអំណាចតុលាការនេះឡើយ។ ដោយសារត្រើវិស័យនេះហើយ ទើបរាជរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរយើង កំពុងផ្តោតការចាប់អារម្មណ៍ និងសង្កត់ធ្ងន់លើឯករាជ្យភាពនៃអំណាចតុលាការកម្ពុជាបច្ចុប្បន្ន ដើម្បីនាំមកវិញនូវការជឿជាក់ធានាដល់ការគោរព ការលើកស្ទួយភាពរឹងមាំអំណាចឯករាជ្យ និងអព្យាក្រឹតភាពនៃប្រព័ន្ធតុលាការ សំដៅកម្ចាត់ចោលនូវការលូកដៃចូលជ្រៀតជ្រែកដោយប្រយោល ឬដោយផ្ទាល់ដល់ស្ថាប័នជម្រះក្តីពីអ្នកមានអំណាច ឬស្ថាប័នដទៃទៀតរបស់រដ្ឋ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារការជម្រះក្តី ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធីច្បាប់ជាធរមាន ហេតុដូច្នេះ៖

- តើអ្វីទៅជាអំណាចនៃឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា?
- តើចៅក្រម និងព្រះរាជអាជ្ញា មានអំណាច និងឯករាជ្យភាពនៅពេលណា និងពុំមានអំណាច និងឯករាជ្យភាពនៅពេលណា?
- តើចៅក្រម និងព្រះរាជអាជ្ញា មានអំណាច និងឯករាជ្យភាពយ៉ាងដូចម្តេច ដើម្បីអនុវត្តតួនាទីរបស់ខ្លួន?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការតាក់តែងសារណានេះ គឺធ្វើឡើងក្នុងគោលបំណង ដើម្បីចង់បង្ហាញឲ្យឃើញពីតម្លៃប្រាកដនិយមស្តីពីតម្លៃដាច់ខាតនៃអំណាចឯករាជ្យរបស់ចៅក្រម និងព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រម និងព្រះរាជអាជ្ញា មានឯករាជ្យភាពពិតប្រាកដ តើវាមានផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិយើង? ផ្ទុយទៅវិញប្រសិនបើ ចៅក្រម និងព្រះរាជអាជ្ញា ពុំមានឯករាជ្យភាព តើវានាំឲ្យប៉ះពាល់អ្វីខ្លះដល់សង្គមជាតិយើង?

## ៤.ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយ វិសាលភាពនៃការស្រាវជ្រាវទៅលើប្រធានបទស្តីពី អំណាច និងឯករាជ្យភាពរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត គឺត្រូវផ្តោតការយកចិត្តទុកដាក់លើ អំណាច និងឯករាជ្យភាពជាសំខាន់របស់ចៅក្រម និងព្រះរាជអាជ្ញានៅតាមសាលាដំបូងរាជធានី-ខេត្តតែក្នុងរឿងព្រហ្មទណ្ឌតែប៉ុណ្ណោះ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ជាឯកសារស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយថ្មីថែមទៀត ដែលបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១.វិធីសាស្ត្រប្រមូលទិន្នន័យ

- **ទិន្នន័យទីមួយ** ជាប្រភេទទិន្នន័យផ្ទាល់ (Primary Data) បានសាកសួរសំណួរមួយចំនួនចំពោះសាស្ត្រាចារ្យច្បាប់ ជាពិសេសសាស្ត្រាចារ្យណែនាំ និងមន្ត្រីអង្គការសង្គមស៊ីវិលនានាពាក់ព័ន្ធទៅនឹងប្រធានបទរបស់យើងខ្ញុំ។
- **ទិន្នន័យទីពីរ** (Secondary Data) បានមកពីការដកស្រង់ចំពោះខ្លឹមសារសំខាន់ៗ និងចាំបាច់នានា ដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលមានជាធរមាន, សៀវភៅ, ព្រឹត្តបត្រ, របាយការណ៍, ទស្សនាវដ្តី, នៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ, គេហទំព័រនានា ដែលយើងខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោងមួយចំនួនទៀត។

### ៦.២.វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបាន គឺយកមកវិភាគតាមរយៈការពិពណ៌នាបែបគុណភាពដោយប្រើទិន្នន័យ ទីពីរ (Secondary Data) ច្រើនលើសលប់ជាងទិន្នន័យទីមួយ ព្រោះថាទិន្នន័យទីពីរយើងខ្ញុំប្រមូលបានច្រើន ដែលជាហេតុធ្វើឲ្យយើងខ្ញុំធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយជាងទិន្ន័យទីមួយ។

### ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណារនេះ មានចំនួន **៦២ទំព័រ** ហើយត្រូវបានបែងចែកជា **៣ជំពូក** ដូចខាងក្រោមនេះ ៖

**សេចក្តីផ្តើម** ជំពូកនេះបានបង្ហាញពី លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ (មានចំនួន ៤ទំព័រ ចាប់ពីទំព័រទី១ ដល់ទំព័រទី៤)។

**ជំពូកទី ១** **"ទស្សនៈទូទៅស្តីពីការបែងចែកអំណាច និង ឯករាជ្យភាព"** ៖ ជំពូកនេះនឹងបង្ហាញលោកអ្នកឲ្យបានដឹងខ្លះៗអំពី និយមន័យនៃពាក្យគន្លឹះ ដំណើការបែងចែកអំណាច ដែលរួមមានការលើកយកទ្រឹស្តីរបស់ទស្សនវិទូនានាមកស្រាយបំភ្លឺ និងចុងក្រោយលើកក្របខណ្ឌច្បាប់មួយចំនួនដែលធានាការប្រព្រឹត្តទៅនៃអំណាចឯករាជ្យ ដើម្បីផ្សារភ្ជាប់ទៅនឹងប្រធានបទយើងទាំងមូល (មានចំនួន ៩ទំព័រ ចាប់ពីទំព័រទី៥ ដល់ទំព័រទី១៣)។

**ជំពូកទី ២** **"អំណាច និងឯករាជ្យភាពរបស់ព្រះរាជអាជ្ញា"**៖ ជំពូកនេះនឹងស្រាយបំភ្លឺលោកអ្នកឲ្យដឹងអំពីលក្ខណៈសម្បត្តិរបស់ព្រះរាជអាជ្ញា រចនាសម្ព័ន្ធអង្គការ-ចាត់តាំង អំណាច ក៏ដូចជានីតិវិធីនិងគោលការណ៍នានាដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចឯករាជ្យភាពរបស់ព្រះរាជអាជ្ញា(មានចំនួន ២៤ទំព័រ ចាប់ពីទំព័រទី១៤ ដល់ទំព័រទី៣៧)។

**ជំពូកទី ៣** **"អំណាច និងឯករាជ្យភាពរបស់ចៅក្រម"** ៖ មិនខុសពីព្រះរាជអាជ្ញាឡើយ គឺយើងខ្ញុំបានលើកយកនូវលក្ខណៈសម្បត្តិ រចនាសម្ព័ន្ធអង្គការចាត់តាំង អំណាច ក៏ដូចជានីតិវិធី និងគោលការណ៍នានា ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចឯករាជ្យភាពរបស់ចៅក្រម(មានចំនួន ២៣ទំព័រ ចាប់ពីទំព័រទី៣៨ដល់ទំព័រទី៦០)។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** យើងខ្ញុំបានធ្វើការសន្និដ្ឋានជារួមនៃប្រធានបទទាំងមូល និងលើកឡើងនូវអនុសាសន៍មួយចំនួន ដែលយើងខ្ញុំបានមកពីការរកឃើញនៅក្នុងសារណានេះ(មានចំនួន ២ទំព័រ ចាប់ពីទំព័រទី៦១ ដល់ទំព័រទី៦២)។

# ជំពូកទី ១

# ទស្សនៈទូទៅស្តីពីការបែងចែកអំណាច និង ឯករាជ្យភាព

## ១.១.និយមន័យ

មុននឹងឈានដល់ការស្រាយបំភ្លឺទៅលើប្រធានបទទាំងមូល យើងគប្បីស្វែងយល់អំពីនិយមន័យនៃពាក្យគន្លឹះមួយចំនួនដែលរួមមានពាក្យ **អំណាច** និង **ឯករាជ្យភាព**។

បើយោងតាមវចនានុក្រមខ្មែរ ជាស្នាមព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត នៅឆ្នាំ ១៩៦៧ ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានពន្យល់អំពីពាក្យ **អំណាច ៖** ប្រភេទជា នាមស័ព្ទ មានន័យថា អានុភាព, សេចក្តីអាច, ដំណើរអង់អាច, សេចក្តីអាចហាន, ដំណើរអាចធ្វើអ្វីៗបានតាមចិត្តឬតាមលំអានច្បាប់ : មានអំណាច, អំណាចរាជការ, អំណាចច្បាប់។ ដោយអំណាច ដោយសារ, ដោយកម្លាំង : ដោយអំណាចគុណបុណ្យ...។ តាមអំណាចចិត្ត តាមអំពើចិត្តៈ ធ្វើតាមអំណាចចិត្តឥតក្រែងច្បាប់។ ឡើងអំណាចឡើងចាង, ឡើងដៃ។ អស់អំណាច អស់សេចក្តីអាច, អស់អានុភាព។ល។[២]

ដោយឡែកបើយោងតាមសមោធានវិទ្យាភាសារុស្ស៊ីៈ **អំណាច** ជាសម្បទា (សមត្ថភាព, ភាពដែលអាចធ្វើបាន) និងជាលទ្ធភាពក្នុងការឆ្លុះឲ្យឃើញនូវឥទ្ធិពលណាមួយជាកំណត់ទៅលើការងារទៅលើឥរិយាបថរបស់មនុស្សដោយមានជំនួយពីសំណាក់មធ្យោបាយនានាដូចជាឆន្ទៈច្បាប់ហិង្សា។ល។[៣]

ចំពោះគេហទំព័រ Wikipedia វិញ បានឲ្យនិយមន័យ **អំណាច** គឺជាសមិទ្ធិផលដែលបានមកពីគោលការណ៍តុល្យភាពអំណាច (Checks and Balances)។[៤] អំណាចសំដៅដល់ការសម្រេចសេចក្តីដោយឥតខ្លាច ឥតញញើត។

រីឯពាក្យ **ឯករាជ្យភាព** វិញ ក៏ត្រូវបានគេឲ្យនិយមន័យរួមមាន៖

ពាក្យ **ឯករាជ្យភាព** នេះបានរួមបញ្ចូលនូវពាក្យ **ឯករាជ្យ + ភាព** ដែលពាក្យ ឯករាជ្យ ប្រភេទជានាម គឺភាពនៃរដ្ឋ ឬប្រទេសដែលមានសិទ្ធិ និងសេរីភាពពេញបរិបូរក្នុងការគ្រប់គ្រងខ្លួនឯងមិនមែនចំណុះប្រទេសដទៃ។[៥]

---

[២] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, "វចនានុក្រមខ្មែរ", ភ្នំពេញ, ឆ្នាំ១៩៦៧, ទំព័រទី១៨៩៨

[៣] សុខ គាង, "វិទ្យាសាស្ត្រនយោបាយ", ភាគ១, ទំព័រទី៨០

[៤] http://km.wikipedia.org/wiki/អំណាច

[៥] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, "វចនានុក្រមខ្មែរ", ភ្នំពេញ, ឆ្នាំ១៩៦៧

**ឯករាជ្យភាព** នេះ បើតាមភាសាអង់គ្លេសបានឲ្យនិយមន័យថា Independence (from somebody / something) ឯករាជ្យ, មិនចូលចំណុះគេ, ស្វ័យភាព។[៦]

## ១.២.ការបែងចែកអំណាច

ព្រះរាជាណាចក្រកម្ពុជា ទទួលយកគោលនយោបាយប្រជាធិបតេយ្យសេរី និងពហុបក្ស ក៏ដូចជា ប្រទេសជាច្រើនទៀតដែរ ដោយអំណាចរបស់រដ្ឋត្រូវបានបែងចែកជា បី ដាច់ពីគ្នា និងមានឯករាជ្យពីគ្នាទៅវិញទៅមករវាង៖ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ចំពោះរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ក៏មានការបែងចែកអំណាចទាំងបីដាច់ដោយឡែកពីគ្នាផងដែរចាប់ពីជំពូកទី៧ ដល់ជំពូកទី ១២ថ្មី។

ពាក្យថា "អង្គការនីតិប្រតិបត្តិ" គឺសំដៅទៅលើរាជរដ្ឋាភិបាល ដែលមានសមាសភាព នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។[៧] អង្គការនីតិប្រតិបត្តិ មានតួនាទី "ប្រតិបត្តិច្បាប់ ឬអនុវត្តច្បាប់ និងអនុវត្តកម្មវិធីគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញ។

រីឯពាក្យថា "អង្គការនីតិបញ្ញត្តិ" វិញ គឺសំដៅទៅលើស្ថាប័នសភាមាន រដ្ឋសភា និងព្រឹទ្ធសភា។ សភាមានតួនាទីតាក់តែងច្បាប់ អនុម័តច្បាប់ ឃ្លាំមើលការអនុវត្តន៍ច្បាប់ និងចុះសួរសុខទុក្ខប្រជាពលរដ្ឋដោយផ្ទាល់។ សូមកត់សម្គាល់ថា បើគេប្រើពាក្យថាសភា គឺសំដៅលើស្ថាប័ននីតិបញ្ញត្តិ ឬពាក្យទូទៅ ដែលគេកត់សម្គាល់នូវសភាទាំងពីរថ្នាក់ រដ្ឋសភា និងព្រឹទ្ធសភា។

ចំពោះពាក្យថា "អង្គការតុលាការ" សំដៅទៅលើសាលាជម្រះក្តីទាំង ពីរថ្នាក់ គឺសាលាជម្រះក្តីជាន់ខ្ពស់(តុលាការកំពូល និងសាលាឧទ្ធរណ៍)និងសាលាជម្រះក្តីជាន់ទាប(សាលាដំបូងរាជធានី-ខេត្ត និងតុលាការយោធា)។ សាលាជម្រះក្តីមានតួនាទីកាត់ក្តីលើគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងរដ្ឋបាល និងពាណិជ្ជកម្មផងដែរ។

ចូរកត់សម្គាល់ផងដែរថា នៅប្រទេសកម្ពុជាមានស្ថាប័នពីរទៀតដែលមានការពាក់ព័ន្ធយ៉ាងច្រើននឹងនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ គឺស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

---

[៦] http://dict.antkh.com/dictionaries/independence.aspx

[៧] មាត្រា ៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

នៅក្នុងមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌ ៤ បានចែងអំពីការបែងចែកអំណាចទាំងបី ដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ប៉ុន្តែអំណាចទាំងនេះមានទំនាក់ទំនងរវាងគ្នាជានិច្ច។

## ១.៣.ទ្រឹស្តីនៃការបែងចែកអំណាច

លទ្ធិនៃការបែងចែកអំណាចនេះ ជាទស្សនៈដ៏មានសារៈសំខាន់បំផុត និងលំបាកដែលតម្រូវឲ្យគ្រប់របបនយោបាយ ជាពិសេសរបបនយោបាយប្រជាធិបតេយ្យដាច់ខាតត្រូវតែមានការបែងចែកអំណាចជាដាច់ខាត។

ការបែងចែកអំណាចរបស់រដ្ឋ ជាផ្នែកខុសៗគ្នានឹងធ្វើឲ្យមានតុល្យភាពអំណាចនៅក្នុងសង្គម ដើម្បីទប់ស្កាត់ការរំលោភបំពានរបស់បុគ្គលនៅក្នុងអំណាចណាមួយ និងទៅលើអំណាចណាមួយដទៃទៀត។

ការបង្កើតឲ្យមានការបែងចែកអំណាចដាច់ពីគ្នានេះ បង្ការកុំឲ្យមានការប្រមូលផ្តុំអំណាចទៅបុគ្គលតែម្នាក់ ឬក្រុមណាមួយដែលនាំឲ្យមានអំណាចផ្តាច់ការ។ គំនិតនៃការបែងចែកអំណាចនេះ បង្កើតឲ្យមានអំណាចប្រកួតប្រជែងគ្នា និងត្រួតពិនិត្យគ្នាទៅវិញទៅមក ដែលជាយន្តការពង្រឹងស្ថាប័នរបស់ខ្លួនទប់ទល់ការកៀបសង្កត់ពីខាងអំណាចណាមួយ”។

ខាងក្រោម គឺជាទស្សនៈមួយចំនួនរបស់ទស្សនវិទូដែលបានលើកឡើងអំពីការបែងចែកអំណាចនេះ រួមមាន៖

បើយោងតាមទ្រឹស្តីរបស់លោក John Locke (១៦៣២-១៧០៤ នៃគ.ស.) ជាទស្សនវិទូ និង ជាអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស។ លោក John Locke បានធ្វើការបែងចែកអំណាចជា បី គឺ ទី១-អំណាចនីតិបញ្ញត្តិ ស្ថិតក្នុងដៃសភា ទី២-អំណាចនិតិប្រតិបត្តិ ស្ថិតក្នុងដៃរដ្ឋាភិបាល តុលាការ និងយោធា និងទី៣-អំណាចសហព័ន្ធ។ អំណាចនិតិបញ្ញត្តិ និងអំណាចនិតិប្រតិបត្តិ មិនត្រូវស្ថិតនៅក្នុងដៃរបស់បុគ្គលណាមួយឡើយ ព្រោះបើបុគ្គលនោះយកអំណាចទាំងនោះទៅប្រើសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនពុំបានបម្រើផលប្រយោជន៍រួមទេនឹងធ្វើឲ្យកើតមានរបបផ្តាច់ការ។ ដូច្នេះការបែងចែកអំណាចជាវិធីសាស្ត្រ ជៀសវាងមិនឲ្យកើតមានឡើងនូវការប្រើអំណាចតាមទំនើងចិត្តបែបអាជ្ញាព្រឹត្ត ដែលជាកត្តាមិនធានាដល់សិទ្ធិសេរីភាព និងកម្មសិទ្ធិរបស់ពលរដ្ឋឡើយ។

លោក Montesquieu (១៦៥៥-១៧៥៥ នៃគ.ស.) ជាទស្សនវិទូនយោបាយបារាំង។ លោកបានឲ្យទ្រឹស្តីចំនួនពីរសម្រាប់ធ្វើការបែងចែកអំណាច គឺទ្រឹស្តីនៃការបែងចែកអំណាចបញ្ឈរ និងផ្តេក។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំសូមលើកយកទ្រឹស្តីនៃការបែងចែកអំណាចផ្តេកមកធ្វើការបកស្រាយពន្យល់តែប៉ុណ្ណោះ។ ទ្រឹស្តីនៃការបែងចែកអំណាចផ្តេក លោកបានធ្វើការបែងចែកអំណាចនេះជា បី ដោយមានតួនាទីរៀងៗខ្លួន គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដូចទៅនឹងការបែងចែកអំណាចនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់ព្រះរាជាណាចក្រកម្ពុជាដែរ។ ការបែងចែកអំណាចនេះ គឺធ្វើឡើងក្នុងគោលបំណងទប់ស្កាត់មិនឲ្យអំណាចដែលស្ថិតនៅក្នុងដៃបុគ្គលណាមួយនោះនាំទៅរកសេចក្តីវិនាសដល់ប្រទេសជាតិ និងដើម្បីរក្សាតុល្យភាពនៃអំណាច។ មួយទៀត គោលបំណងនៃការបែងចែកអំណាចនេះ គឺប្រឆាំងទៅនឹងរបបផ្តាច់ការ ដោយជៀសវាងការដណ្តើមយកអំណាចផ្តាច់មុខ ព្រោះថា "**សារជាតិរបស់មនុស្ស កាលណាបើបានអំណាចនៅក្នុងដៃរបស់ខ្លួនហើយ មនុស្សនឹងតស៊ូដើម្បីរក្សាអំណាចនោះ លុះដល់ដំណក់ឈាមចុងក្រោយ**"។ ហេតុដូច្នេះ ធ្វើយ៉ាងណាឲ្យអំណាចទប់ទល់នឹងអំណាច ពីព្រោះ មនុស្សទាំងអស់ដែលមានអំណាចតែងតែមានការប្រើប្រាស់នូវអំណាចទាំងនោះជ្រុលហួស។ ការពង្រឹងអំណាចឲ្យទៅក្នុងស្ថាប័នណាមួយ ឬបុគ្គលណាមួយដោយជៀសមិនរួចនឹងជួបប្រទះនឹងការប្រើអំណាចដោយហួសព្រំដែននឹងធ្វើឲ្យបាត់បង់នូវសេរីភាពបុគ្គល និងអធិបតេយ្យភាពប្រជាជន ហើយធ្វើឲ្យខូចខាតនូវតម្លៃនៃច្បាប់។

ចំពោះទស្សនៈរបស់ James Madison (១៧៥១-១៨៣៦ នៃគ.ស.) ជារដ្ឋបុរស និងជាទស្សនវិទូនយោបាយ ដោយត្រូវបានគេទទួលស្គាល់ថា ជា "បិតារដ្ឋធម្មនុញ្ញ" របស់សហរដ្ឋអាមេរិក។ លោក Madison បានគិតអំពីកត្តាចាំបាច់ក្នុងការបែងចែកអំណាច ជាពិសេស គឺការបែងចែកស្ថាប័នអំណាចនិតិបញ្ញត្តិជាពីរថ្នាក់។ អ្នកនយោបាយអាមេរិក បានឈរលើគោលការណ៍ នៃការបែងចែកអំណាចរបស់លោក Montesquieu ដែលបង្កើតនូវប្រព័ន្ធបែងចែកអំណាចឲ្យមានតុល្យភាពនឹងគ្នា ហើយអំណាចទាំងបី ត្រូវមានអំណាចប្រហាក់ប្រហែលគ្នា។ តាមទស្សនៈរបស់លោក អំណាចទាំងបីត្រូវឈរនៅលើទំនាក់ទំនងសមភាព។ យន្តការនេះ ត្រូវបានប្រើនៅក្នុងសហរដ្ឋអាមេរិករហូតមកដល់សព្វថ្ងៃនេះ។

ទ្រឹស្តីនៃគោលការណ៍បែងចែកអំណាច ត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយលោក V.S Soloviyev នៅក្នុងស្នាដៃរបស់លោក "អំពីល្អជាសច្ចៈភាព"។ ទស្សនវិជ្ជាសីលធម៌បានបង្ហាញយ៉ាងច្បាស់ថា អំណាចទាំងបី នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ មានរូបភាពខុសគ្នា និងទំនួលខុសត្រូវផ្សេងគ្នាជាចាំបាច់ អាចមានទំនាក់ទំនងគ្នាបានក្នុងលក្ខណៈ Checks and Balances ពីព្រោះ ស្ថាប័នអំណាចទាំងបីមានទិសដៅបម្រើឲ្យដល់ការរីកចម្រើននៃសង្គមជាតិដូចគ្នា។

លោក A. Tikhamirov នៅក្នុងស្នាដៃ "រដ្ឋរបបរាជានិយម នាឆ្នាំ១៩០៥" បានធ្វើការបែងចែកអំណាចបានយ៉ាងច្បាស់លាស់។ លោកបានសរសេរអំពីការកើតឡើងនៃអំណាចទាំងបីរបស់រដ្ឋ គឺ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ អំណាចនីមួយៗមានអត្ថន័យនៅពេលណាដែលការកើតឡើងដោយកម្លាំងតែមួយ។

## ១.៤.ការអនុវត្តន៍ការបែងចែកអំណាច

តាមការពិតប្រទេសនានា បានអនុម័តយកគោលការណ៍នៃលទ្ធិនេះ(ការបែងចែកអំណាច) នៅក្នុងកម្រិតផ្សេងៗគ្នា។ នៅក្នុងប្រទេសខ្លះ គេអនុវត្តយកគោលការណ៍ឲ្យសមាជិកនៃអំណាចនីតិបញ្ញត្តិអាចជាសមាជិកនៃអំណាចនីតិប្រតិបត្តិផងដែរ (បុគ្គលម្នាក់ធ្វើជាសមាជិករដ្ឋសភាផង និងជាសមាជិករដ្ឋាភិបាលផង) ដូចនៅប្រទេសកម្ពុជាសព្វថ្ងៃ។ ចំណែកការតាក់តែងច្បាប់ មិនមែនមានតែរដ្ឋសភាទេ ពេលខ្លះគេប្រគល់ទៅឲ្យរដ្ឋាភិបាលតាក់តែងច្បាប់ផងដែរ។ ទាំងនេះមាននៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាតែម្តង។

សំណួរត្រូវបានគេលើកឡើងថា ប្រសិនបើមានករណីនេះកើតឡើង តើគោលការណ៍នៃការបែងចែកអំណាចទាំងបីដាច់ពីគ្នានៅត្រង់ណា? តើតុល្យភាពនៃការត្រួតពិនិត្យអំណាច អាចធ្វើបានដោយរបៀបណា (Checks and Balances)។

នៅក្នុងប្រទេសដែលប្រើប្រាស់ច្បាប់ Common law ស្ថាប័នតុលាការ មានអំណាចកំណត់អត្ថន័យរបស់ច្បាប់ដែលអ្នកប្រាជ្ញច្បាប់ខ្លះហៅថា "ស្ថាប័នតុលាការមានអំណាចធ្វើច្បាប់"។ នៅក្នុងន័យនេះ គេឃើញសេចក្តីសម្រេចរបស់តុលាការមុនៗបានក្លាយជាយុត្តិសាស្ត្រ(Jurisprudence)សម្រាប់តុលាការក្រោយៗយកទៅអនុវត្តក្នុងរឿងស្រដៀងគ្នា។

នៅក្នុងប្រទេសដែលប្រើប្រព័ន្ធច្បាប់ រ៉ូម៉ាំងអាល្លឺម៉ង់ ឬប្រព័ន្ធច្បាប់ស៊ីវិល (Civil law) ដូចជានៅប្រទេសបារាំង ស្ថាប័នតុលាការពុំមានសិទ្ធិធ្វើច្បាប់ទេ ព្រោះថា នេះគឺជាការរំលោភទៅលើគោលការណ៍នៃការបែងចែកអំណាច។ តុលាការរដ្ឋបាលពិសេសត្រូវបានបង្កើតឡើង នៅក្រោមអង្គការនីតិប្រតិបត្តិដើម្បីធ្វើការនេះ។ ប៉ុន្តែនៅប្រទេសដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធច្បាប់ Common law គឺតួនាទី និងភារកិច្ចតុលាការនេះហើយជាអ្នកធ្វើច្បាប់ ប៉ុន្តែមិនមែនស្របទៅតាមគោលការណ៍នៃការបែងចែកអំណាចនោះឡើយ។

ជារួមមក ការបែងចែកអំណាចលើការដឹកនាំដោយរបៀបនេះ ជាគោលការណ៍នៃការបែងចែកអំណាចតម្រូវថា អំណាចនីមួយៗនៃអំណាចទាំងបីត្រូវកម្រិតព្រំដែននៃមុខងាររបស់ខ្លួនឲ្យបានច្បាស់លាស់ ហើយមិនអនុញ្ញាតឲ្យរំលោភបំពានលើអំណាចផ្សេងៗទៀតឡើយ។

## ១.៥.ក្របខណ្ឌច្បាប់សម្រាប់ធានាឯករាជ្យភាពតុលាការ

ការរក្សាបាននូវឯករាជ្យតុលាការ មានសារៈសំខាន់ចំពោះការសម្រេចនូវគោលដៅ និងការអនុវត្តន៍ត្រឹមត្រូវនូវមុខងាររបស់ខ្លួននៅក្នុងសង្គមសេរីក្នុងការពិនិត្យមើលនីតិរដ្ឋជាការសំខាន់ណាស់ ដែលឯករាជ្យភាពត្រូវទទួលការធានាពីរដ្ឋ និង ចែងនៅក្នុងអត្ថបទច្បាប់។[៨]

### ១.៥.១.លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

#### ១.៥.១.១.គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ

គោលការណ៍នេះបានបង្កើតបទដ្ឋានជាមូលដ្ឋាន ដើម្បីធានាឯករាជ្យភាព និងអនាគតិនៃតុលាការ គ្មានការជ្រៀតជ្រែកដែលមិនសមស្រប គ្មានយុត្តិកម្ម សេរីភាពក្នុងការសម្តែងមតិ ការបង្កើតសមាគម លក្ខណៈសម្បត្តិ ការជ្រើសរើស បណ្តុះបណ្តាល លក្ខខណ្ឌការងារ មុខតំណែង ការសម្ងាត់ខាងវិជ្ជាជីវៈ អភ័យឯកសិទ្ធិ ការដាក់វិន័យ ការព្យួរការងារ និងការដកចេញពីមុខតំណែង។ តុលាការ ត្រូវសម្រេចសេចក្តីដោយមិនលម្អៀង ផ្អែកលើអង្គហេតុ និងអង្គច្បាប់ ដោយមិនមានការរិតត្បិត ទទួលរងឥទ្ធិពលដែលមិនត្រឹមត្រូវ ការទាក់ទាញ ការគាបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកដោយផ្ទាល់ ឬដោយប្រយោលពីគ្រប់មជ្ឈដ្ឋាន ដោយសារមូលហេតុណាមួយឡើយ។ នៅក្នុងមាត្រា ៧ នៃគោលការណ៍ដដែលនេះ ក៏បានចែងថា ជាកាតព្វកិច្ចនៃរដ្ឋជាសមាជិក "ក្នុងការផ្តល់នូវធនធានគ្រប់គ្រាន់ដើម្បីអាចឲ្យតុលាការបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ"។

ហេតុដូច្នេះ ឯករាជ្យភាពរបស់តុលាការ រួមមាន៖

១. រដ្ឋត្រូវធានានូវឯករាជ្យភាពរបស់តុលាការ ហើយឯករាជ្យភាពនេះត្រូវតែតម្កល់នៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ជាតិ។ នេះគឺជាកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋ និងស្ថាប័នដទៃទៀតទាំងអស់ក្នុងការគោរព និងប្រតិបត្តិតាមឯករាជ្យភាពរបស់តុលាការ។

២. តុលាការ ត្រូវសម្រេចរឿងក្តីទាំងអស់នៅចំពោះមុខខ្លួនដោយមិនលម្អៀងដោយឈរលើមូលដ្ឋាននៃអង្គហេតុ និងអង្គច្បាប់ ដោយមិនមានការដាក់កំហិត ការប្រើឥទ្ធិពលមិនត្រឹមត្រូវ ការអន្ទង ការកៀបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែក ទោះដោយផ្ទាល់ ឬដោយប្រយោលពីមជ្ឈដ្ឋានណាមួយ ឬដោយមូលហេតុណាមួយក៏ដោយ។

៣. តុលាការ ត្រូវមានយុត្តាធិការ លើគ្រប់រឿងក្តីទាំងអស់ ដែលមានចរិតជាការវិនិច្ឆ័យ ហើយត្រូវមានអំណាចពេញលេញ ដើម្បីសម្រេចរឿងក្តីណាមួយដែលបានប្តឹងសុំឲ្យតុលាការសម្រេចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមច្បាប់កំណត់។

---

[៨] ចំណុចទី៤ នៃសេចក្តីប្រកាសនៅប៉េកាំងស្តីពី, "គោលការណ៍ឯករាជ្យភាពរបស់តុលាការនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីភិច, បេកាំង", ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៥

៤. មិនត្រូវឲ្យមានការជ្រៀតជ្រែកដែលមិនសមស្រប ឬគ្មានយុត្តិកម្មណាមួយទៅក្នុងកិច្ចការរបស់តុលាការឡើយ ហើយសេចក្តីសម្រេចរបស់តុលាការ មិនត្រូវឲ្យមានការពិនិត្យសើរើឡើងវិញដែរ។ ប៉ុន្តែ គោលការណ៍នេះ មិនបានធ្វើអោយប៉ះពាល់ដល់ការពិនិត្យសើរើតាមបែបតុលាការ ឬការបន្ធូរបន្ថយទោស ឬការសម្រាលទោសដោយអាជ្ញាធរមានសមត្ថកិច្ចចំពោះការផ្តន្ទាទោសដែលតុលាការបានសម្រេចស្របតាមច្បាប់ឡើយ។

៥. ជនគ្រប់រូប មានសិទ្ធិទទួលបានការជំនុំជម្រះទោសពីតុលាការធម្មតា ឬសាលាក្តីដែលប្រើប្រាស់នីតិវិធីច្បាប់ដែលមានស្រាប់។ សាលាក្តីទាំងឡាយណា ដែលមិនប្រើនីតិវិធីនៃដំណើរការក្តីតាមផ្លូវច្បាប់ ដែលមានស្រាប់ឲ្យបានត្រឹមត្រូវទេនោះ សាលាក្តីនោះមិនត្រូវបង្កើតឡើងដើម្បីជំនួសយុត្តាធិការនៃតុលាការធម្មតា ឬសាលាជម្រះក្តីផ្សេងទៀតឡើយ។

៦. គោលការណ៍ឯករាជ្យភាពរបស់តុលាការ ផ្តល់អំណាច និងតម្រូវឲ្យតុលាការធានាថាចំណាត់ការតាមផ្លូវច្បាប់ ត្រូវតែប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ ហើយត្រូវគោរពដល់សិទ្ធិរបស់គូភាគី។

៧. រដ្ឋសមាជិកនីមួយៗ មានកាតព្វកិច្ចផ្តល់ធនធានឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យតុលាការអាចបំពេញមុខងាររបស់ខ្លួនបានត្រឹមត្រូវ។[៩]

**១.៥.១.២.គោលការណ៍បែងហ្គាល័រ**

គោលការណ៍បែងហ្គាល័រ ក៏មានចែងទាក់ទងទៅនឹងស្ថាប័នតុលាការ គឺនៅត្រង់គោលការណ៍ ១.១ចែងថា "ចៅក្រមត្រូវបំពេញតួនាទីដោយឯករាជ្យ ផ្អែកលើគោលការណ៍វិនិច្ឆ័យទៅលើអង្គហេតុ និងយោងតាមចំណេះដឹងផ្នែកច្បាប់ ជៀសផុតពីឥទ្ធិពលខាងក្រៅ ការទាក់ទាញ ការគាបសង្កត់ ការគំរាមកំហែង ឬឥទ្ធិពលដោយផ្ទាល់ ឬប្រយោល ពីភាគីណាមួយ ឬហេតុផលណាមួយ។ ចំពោះគោលការណ៍ ១.៣ បានចែងថា "ចៅក្រម មិនត្រឹមតែត្រូវរួចផុតពីទំនាក់ទំនងមិនប្រក្រតី និងឥទ្ធិពលពីសំណាក់អង្គការនីតិប្រតិបត្តិ និងនីតិបញ្ញត្តិប៉ុណ្ណោះទេ ថែមទាំងត្រូវបង្ហាញឲ្យឃើញក្នុងក្រសែភ្នែកអ្នកសង្កេតការណ៍ ដែលមានការត្រិះរិះសមរម្យថា ពិតជារួចផុតពីឥទ្ធិពលទាំងនោះ។ ការបង្ហាញនូវរូបភាពថា យុត្តិធម៌របស់ខ្លួនដោយមិនអនុគ្រោះ មិនលម្អៀង ឬរើសអើង។ និងចុងក្រោយគោលការណ៍ ២.២ បន្ថែមថា ចៅក្រមគួរតែធានាថា "ការប្រព្រឹត្តរបស់ខ្លួនទាំងនៅក្នុង និងក្រៅតុលាការ រក្សា និងពង្រឹងទំនុកចិត្តពីសំណាក់សាធារណជន អ្នកវិជ្ជាជីវៈផ្នែកច្បាប់ និងគូវិវាទទៅលើភាពមិនលម្អៀងរបស់ចៅក្រម និងតុលាការ"។[១០]

---

[៩] អង្គការសហប្រជាជាតិ, "គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ", ចំណុចទី១-៧

[១០] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, របាយការណ៍ប្រចាំឆមាសលើកទី៣, "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាការវិវឌ្ឍក្នុងរយៈពេលពេញ១ឆ្នាំ" បោះពុម្ពខែមករា ឆ្នាំ២០១២ ទំព័រទី៧៤

## ១.៥.២.លិខិតបទដ្ឋានគតិយុត្តជាតិ

### ១.៥.២.១.រដ្ឋធម្មនុញ្ញ

នៅក្នុងការធានាឲ្យមានការការពារសិទ្ធិតាមផ្លូវច្បាប់ ដោយស្ថាប័នឯករាជ្យមួយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាឲ្យមានតុលាការឯករាជ្យមួយ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ចែងនៅក្នុងមាត្រា ៥១ ចែងថា "អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ មាត្រា ១២៨ ថា អំណាចតុលាការ ជាអំណាចឯករាជ្យដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ។ មាត្រា ១២៩ ចែងថា ការជម្រះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ហើយត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ មាត្រា ១៣០ ចែងថា គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ខណៈដែលមាត្រា ១៣១ ចែងថា មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញបានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ហើយផ្តល់អាណត្តិដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះអង្គក្នុងកិច្ចការនេះ។

### ១.៥.២.២.ក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងលម្អិតអំពីរបៀបដែលឯករាជ្យភាពត្រូវបានរក្សានៅក្នុងទម្រង់នីតិវិធីប្រចាំថ្ងៃ។ មាត្រា ៣៣៧ កំណត់នូវនីតិវិធីនៃការពិភាក្សាសម្រេចរបស់តុលាការ និងចែងថា "តុលាការ ថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច។ គ្មានបណ្តឹងសុំណាមួយអាចត្រូវដាក់ជូនតុលាការបានទៀតទេ។ គ្មានទឡ្ហីករណ៍ណាមួយ អាចត្រូវបានលើកយកសំអាងទៀតឡើយ។ ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ"។ មាត្រា ២៨៨ ចែងថា "រវាងមុខងារជាចៅក្រម និង មុខងារជាព្រះរាជអាជ្ញា ឬជាព្រះរាជអាជ្ញារង គឺមានវិសមភាពនឹងគ្នាយ៉ាងដាច់ខាត។ ចៅក្រមណាដែលបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវចាត់ទុកជាមោឃៈ។

### ១.៥.២.៣.ក្រមសីលធម៌ចៅក្រម

នៅក្នុងក្រមសីលធម៌ចៅក្រម និង ព្រះរាជអាជ្ញា ក៏មានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងភាពមិនលម្អៀង និងឯករាជ្យនេះផងដែរ។ ប្រការ ២ ចែងថា "ចៅក្រម ត្រូវបំពេញកិច្ចការរបស់ខ្លួនដោយឯករាជ្យឈរលើមូលដ្ឋានការវាយតម្លៃទៅលើអង្គហេតុ និងចំណេះដឹងផ្នែកច្បាប់ ដោយមិនត្រូវទទួល

រងឥទ្ធិពលដូចជា ការបញ្ចុះបញ្ចូល ការគាបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែក"។ ប្រការ ៥ ចែងថា ចៅក្រម ត្រូវតែអព្យាក្រឹតនៅក្នុងសកម្មភាពនយោបាយ។ ប្រការ ៧ សំដៅលើការទាមទារឲ្យមាន "ភាពមិនលម្អៀង" និងសារៈសំខាន់នៃការលើកកម្ពស់ទំនុកចិត្តសាធារណជនទៅលើគោលការណ៍នេះ។ ប្រការ ៩ ចែងថា "ចៅក្រម មិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយក្នុងអំឡុងពេលនៃការប្រព្រឹត្តទៅនៃនីតិវិធី នៅពេលដែលភាគីម្ខាងទៀតអវត្តមានឡើយ។

**១.៥.២.៤.ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា ១៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យចៅក្រម និងធានាការប្រព្រឹត្តទៅសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាឲ្យដំណើរការបានល្អប្រសើរ។[១១] ប៉ុន្តែការចូលជ្រៀតជ្រែកពីអំណាចដទៃត្រូវបានកត់សម្គាល់ថា ជាបញ្ហាធ្ងន់ធ្ងរបំផុតដែលញាំញីដល់ស្ថាប័នតុលាការកម្ពុជា។ ព្រះមហាក្សត្រ ទ្រង់គង់ជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានេះ ព្រមទាំងមានសមាជិក៨រូបផ្សេងទៀត ដែល៥រូបកាន់តំណែងនេះតាមរយៈតួនាទីដែលតម្រូវតាមច្បាប់ មានដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ សមាជិក ៣រូបទៀត ជាចៅក្រម ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយអង្គចៅក្រមពីក្នុងចំណោមសហការីរបស់ពួកគេ។

យោងតាមមាត្រា ១ នៃច្បាប់នេះ បានចែងអំពីគោលបំណងក្នុងការបង្កើតច្បាប់នេះឡើងដែលមានតួនាទី "ធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងដើម្បីធានាការប្រព្រឹត្តទៅនៃសាលាជម្រះក្តី នៃព្រះរាជាណាចក្រកម្ពុជាឲ្យដំណើរការបានល្អប្រសើរ។

[១១] មាត្រា ១ នៃព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

# ជំពូកទី ២
# អំណាច និងឯករាជ្យភាពរបស់ព្រះរាជអាជ្ញា

## ២.១.លក្ខណៈសម្បត្តិរបស់ព្រះរាជអាជ្ញា

### ២.១.១.ជំនាញវិជ្ជាជីវៈ

ព្រះរាជអាជ្ញា គឺជាមន្ត្រីសាធារណៈដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ក្នុងនាមផលប្រយោជន៍សង្គម។[១២] អង្គការអយ្យការ ក៏ជានាវ៉ាប់រងការអនុវត្តន៍សេចក្ដីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។[១៣]

### ២.១.២.ការជ្រើសរើស

ការជ្រើស និង ការបណ្ដុះបណ្ដាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងការបណ្ដុះបណ្ដាលចៅក្រម។[១៤]

យោងតាមគោលការណ៍ណែនាំស្ដីពី តួនាទីរបស់ព្រះរាជអាជ្ញា រដ្ឋត្រូវធានាថា *បុគ្គលដែលត្រូវបានជ្រើសរើសឲ្យធ្វើជាព្រះរាជអាជ្ញាត្រូវតែជាបុគ្គលដែលមានសុចរិត មានសមត្ថភាព មានការបណ្ដុះបណ្ដាលត្រឹមត្រូវ និងមានគុណសម្បត្តិ។*

### ២.១.៣.ការបណ្ដុះបណ្ដាល

ដូចគ្នានឹងចៅក្រមដែរ មុននឹងក្លាយជាព្រះរាជអាជ្ញា គឺត្រូវតែទទួលការបណ្ដុះបណ្ដាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល ២ឆ្នាំនៅសាលាភូមិន្ទចៅក្រម ព្រមទាំងឆ្លងកាត់កម្មសិក្សាដែលត្រូវបានកំណត់។

### ២.១.៤.ការតែងតាំង

សិស្សព្រះរាជអាជ្ញា ដែលបានបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈប្រកបដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។[១៥]

---

[១២] មាត្រា ៧៤ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ និងមាត្រា ៤ កថាខណ្ឌ២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[១៣] មាត្រា ២៧ វាក្យខណ្ឌ ២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[១៤] មាត្រា ៨២ នៃសេចក្ដីព្រាងច្បាប់ស្ដីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

បន្ទាប់ពីបានបំពេញកម្មសិក្សាចប់សព្វគ្រប់ហើយ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។[១៦] យោងតាមមាត្រា ១៣៩ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌ ៣ និងយោងតាមមាត្រា ១១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចែងថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេច និងលើកថ្វាយព្រះមហាក្សត្រក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្អាក់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់។ ហើយជាពិសេសថែមទៀតនោះ គឺយោងតាមមាត្រា ៨៩ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និង មាត្រា ១៨ កថាខណ្ឌ ២ នៃសេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពី ការតែងតាំង ការផ្លាស់ប្តូរ ការផ្អាក់ពីមុខងារ ការដាក់ឲ្យនៅទំនេរ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់ **តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។**

ដូច្នេះបានន័យថា រាល់ការស្នើថ្វាយព្រះមហាក្សត្រដោយឧត្តមក្រុមប្រឹក្សាដូចបានរៀបរាប់ខាងលើ ចាំបាច់ត្រូវតែមានសំណើពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន។

## ២.២.រចនាសម្ព័ន្ធ

ព្រះរាជអាជ្ញាអមសាលាដំបូង មានឋានន្តរសក្តិជាវរៈព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់មានឋានន្តរសក្តិជាវរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ។[១៧]

នៅអមសាលាដំបូង ត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង។[១៨] អយ្យការអមសាលាដំបូង ត្រូវដឹកនាំដោយព្រះរាជអាជ្ញា ១រូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូង ជាតំណាងអយ្យការអមសាលាដំបូង ដែលខ្លួនបំពេញការងារ។[១៩]

---

[១៥] មាត្រា ៨៣ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[១៦] មាត្រា ៨៤ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[១៧] មាត្រា ៣០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[១៨] មាត្រា ៨ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[១៩] មាត្រា ៧៤ កថាខណ្ឌ ៣ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

សមាសភាពអយ្យការអមសាលាដំបូងរួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[២០]

## ២.៣.ការគ្រប់គ្រង

ចៅក្រមអយ្យការគ្រប់រូប ត្រូវគោរពតាមអធិបញ្ជាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម ដែលរួមមាន៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។
- ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

[២០] មាត្រា ១៣ នៃសេចក្ដីព្រាងច្បាប់រៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

## ២.៤.ហិរញ្ញវត្ថុ

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។ ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាអាណាប័កទទួលសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ។[២១]

## ២.៥.តួនាទី

### ២.៥.១.ទទួលពាក្យបណ្តឹង

ព្រះរាជអាជ្ញា ទទួលពាក្យបណ្តឹងទាមទារ ឬបរិហារពី៖

- នគរបាលយុត្តិធម៌
- ជនរងគ្រោះ។

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។[២២]

### ២.៥.២.បើកការស៊ើបសួរ

នៅពេលដែលព្រះរាជអាជ្ញាទទួលបណ្តឹងទាមទារ ឬបណ្តឹងបរិហារ ឬកំណត់ហេតុមួយតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ត្រូវចុះ ឬបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាមួយឲ្យចុះពាក្យបណ្តឹងក្នុងបញ្ជីនៃពាក្យបណ្តឹងជាបន្ទាន់ ទោះបីជាបទល្មើសជាក់ស្តែងក្តី ឬមិនជាក់ស្តែងក្តី វាខុសគ្នាត្រង់ថា មានខ្លួនជនជាប់សង្ស័យ ឬគ្មាន។ បើសិនជាប់បទល្មើសជាក់ស្តែងមានខ្លួនជនជាប់សង្ស័យ ព្រះរាជអាជ្ញា អាចសួរយកចម្លើយបាន ដោយគាត់អាចបង្គាប់ឲ្យក្រឡាបញ្ជីអយ្យការណាម្នាក់សួរនាំយកចម្លើយជំនួសខ្លួន ហើយព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយចុះលេខពិសេស ហើយបញ្ជូនទៅប្រធានតុលាការ ដើម្បីចាត់តាំងចៅក្រមស៊ើបសួរ។ ប្រសិនបើគ្មានជនសង្ស័យទេ ក្រោយពីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មកនោះ ព្រះរាជអាជ្ញា ត្រូវធ្វើការស៊ើបអង្កេតបឋមរកវិមតិសង្ស័យតទៅទៀតនូវតម្រុយចំណុចត្រង់ណាដែលសង្ស័យ ដើម្បីធ្វើការចោទប្រកាន់ដោយសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬសាក្សី។

---

[២១] មាត្រា ៧៩ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[២២] មាត្រា ៤០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ការផ្តើមចោទប្រកាន់មិនទាន់ស្ពាពរទេ ហើយធ្វើការផ្តើមចោទដោយឲ្យតម្រុយទៅចៅក្រមស៊ើបសួរ។ កាលណាបានដឹងអំពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។[២៣]

## ២.៦.អំណាច

### ២.៦.១.ការតម្កល់រឿងទុកឥតចាត់ការ

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្តឹងមកមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬគ្មានភស្តុតាងណាមួយឲ្យជឿថា ពិតជាមានបទល្មើសកើតឡើងមែននោះ មានន័យថា អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលច្បាប់កំណត់ផ្តន្ទាទោស ឬក៏គ្មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទដូច្នេះព្រះរាជអាជ្ញានឹងចេញ ដីកាតម្កល់រឿងទុកឥតចាត់ការ ដោយមានសំអាងច្បាប់ និងសំអាងហេតុ។

ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃទទួលដំណឹងពីដីកានេះ ដោយអ្នកប្តឹងត្រូវដាក់ពាក្យនៅអង្គការអយ្យការពាក់ព័ន្ធ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញា ចេញអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[២៤] ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចនេះពុំមានអាជ្ញាអស់ជំនុំទេ ដោយព្រះរាជអាជ្ញា អាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ នៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។

សូមបញ្ជាក់ផងដែរថា ព្រះរាជអាជ្ញា អាចធ្វើការរលត់បណ្តឹងអាជ្ញាបានដែរ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។[២៥]

---

[២៣] មាត្រា ១១១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[២៤] មាត្រា ៤១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[២៥] មាត្រា ៧ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ២.៦.២.សេចក្តីសម្រេចក្នុងការចោទប្រកាន់

នៅពេលដែលមានភស្តុតាងធ្ងន់ល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់។ ដោយឡែកការផ្តើមការចោទប្រកាន់មានច្រើនសណ្ឋានក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ ត្រូវបានតុលាការធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរ។[២៦] ការចាប់ផ្តើមចោទប្រកាន់ចំពោះអនីតិជន ត្រូវជូនដំណឹងទៅអនីតិជនជាប់សង្ស័យ និងឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជននោះ។

ទាក់ទងនឹងអនីតិជនដែលជាជនជាប់សង្ស័យ សេចក្តីណែនាំអំពីការអនុវត្តន៍គោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជន ចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ បានកំណត់ថា "ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។

- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យតិចជា១៣ឆ្នាំ ព្រះរាជអាជ្ញា គប្បីចេញដីកាតម្កល់រឿងទុកឥតចាត់ការ ហើយឲ្យដំណឹងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី។
- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យនោះចាប់ពីអាយុ១៤ឆ្នាំឡើងទៅ តែតិចជាង១៨ឆ្នាំ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់បាន។
- ប្រសិនបើរកមិនឃើញអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីឲ្យចៅក្រមស៊ើបសួរ ស៊ើបសួរបន្ថែមក្នុងការស្វែងរកការពិតនៃអាយុរបស់ជននោះ។

#### ២.៦.២.១.បើកការស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺៈ

---

[២៦] មាត្រា ៥១ នៃព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវីលនៃព្រះរាជាណាចក្រកម្ពុជា

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន (ក្នុងករណីមិនអាចកំណត់បាន អាចបើកការស៊ើបសួរប្រឆាំងនឹង **អញ្ញាតជន** ពោលគឺ ជនមិនស្គាល់)
- ចុះកាលបរិច្ឆេទ និង ហត្ថលេខា។

ព្រះរាជអាជ្ញា មានកាតព្វកិច្ចធ្វើដីកានេះស្នើឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរក្នុងករណីដូចខាងក្រោម៖

- បទល្មើសឧក្រិដ្ឋជាក់ស្ដែង ឬមិនជាក់ស្ដែង
- បទល្មើសមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថា ត្រូវបើកការស៊ើបសួរ។

### ២.៦.២.២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងករណីនេះ ព្រះរាជអាជ្ញា ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចធ្វើបានតែចំពោះបទល្មើសមជ្ឈិមជាក់ស្ដែង និង បទល្មើសលហុ ប៉ុណ្ណោះ។[២៧]

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺព្រះរាជអាជ្ញាចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាការបញ្ជាដល់ជនជាប់ចោទឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។ ការដែលទទួលយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាសិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការដោយទាមទារឲ្យមានការធ្វើការចោទប្រកាន់ជនល្មើស និងអង្គហេតុទៅតុលាការតែម្ដងដោយមិនចាំបាច់ឆ្លងនីតិវិធីណាផ្សេងទៀត។

### ២.៦.២.៣.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញ ព្រះរាជអាជ្ញាអាចប្រើប្រាស់នីតិវិធីនេះបាន ដោយគ្រាន់តែធ្វើកំណត់ហេតុប៉ុណ្ណោះ ពុំមានចេញជាដីកាសន្និដ្ឋានអ្វីទេ។[២៨] លក្ខខណ្ឌដែលអាចឲ្យប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន មានដូចជា៖

---

[២៧] មាត្រា ៤៥ និង មាត្រា ៤៩ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[២៨] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,ឯកសារមេរៀន, "នីតិវិធីព្រហ្មទណ្ឌ", បោះពុម្ពឆ្នាំ២០១៣

- បទមជ្ឈិមជាក់ស្តែង
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ។ ហេតុនេះ ប្រសិនបើជនល្មើសត្រូវចោទប្រកាន់ពីបទប្រើប្រាស់គ្រឿងញៀន នីតិវិធីនៃការបង្ហាញខ្លួនភ្លាមមិនអាចយកមកប្រើប្រាស់បានឡើយ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

## ២.៧.មុខងារនៃអង្គការអយ្យការ

### ២.៧.១.មុខងាររបស់អយ្យការនៅក្នុងរឿងព្រហ្មទណ្ឌ

យោងតាមមាត្រា ១៣០ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា "មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា" និងយោងតាមមាត្រា ៥ កថាខណ្ឌ ២ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ បានចែងថា ក្នុងរឿងព្រហ្មទណ្ឌ ក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើការសេចក្តីសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្តីដើមជាដរាប។[២៩] តាមមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងបន្ថែមទៀតថា បណ្តឹងអាជ្ញា ត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ដោយអយ្យការ។ បានន័យថា ព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា និងជាគូក្តីដើមក្នុងរឿងព្រហ្មទណ្ឌ ដើម្បីការពារ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សង្គមតាមរយៈការចោទប្រកាន់ប្រឆាំងនឹងបុគ្គលទាំងឡាយដែលបានរំលោភច្បាប់។ យោងតាមមាត្រា ៨ កថាខណ្ឌ ៤ នៃសេចក្តីព្រាងច្បាប់រៀបចំអង្គការតុលាការ និង មាត្រា ២៧ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងបញ្ជាក់ថា ព្រះរាជអាជ្ញាត្រូវតែមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ដែលក្នុងរឿងក្តីព្រហ្មទណ្ឌនេះ គាត់ជាអ្នកប្តឹងទៅតុលាការហើយត្រូវតែបង្ហាញឲ្យបានច្បាស់នូវអ្វីដែលខ្លួនបានចោទប្រកាន់។ ក្នុងឱកាសជំនុំជម្រះតំណាងអយ្យការ ត្រូវចូលរួម ជាចាំបាច់ បើពុំដូច្នេះទេ តុលាការមិនអាចជំនុំជម្រះ ឬកាត់ទោសជនល្មើសបានឡើយ។[៣០] ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យមានការអនុវត្តន៍ច្បាប់ ហើយព្រះរាជអាជ្ញា ក៏ធានារ៉ាប់រងការអនុវត្តន៍សេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងសិទ្ធិធ្វើបណ្តឹងអាជ្ញា សិទ្ធិអំណាចស៊ើបអង្កេតបឋមក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង អំណាចធ្វើការចាប់ខ្លួន ការឃាត់ខ្លួន ចោទប្រកាន់ និងសិទ្ធិអំណាចច្រើនទៀតដែលច្បាប់បានផ្តល់ឲ្យ។[៣១]

---

[២៩] មាត្រា ៥ កថាខណ្ឌ ២ នៃច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣

[៣០] ហ៊ាង ឡេង, ឯកសារមេរៀនឆ្នាំទី២, "នីតិព្រហ្មទណ្ឌទូទៅ" កថាខណ្ឌ ១ ទំព័រទី៧

[៣១] មាត្រា ២៧ កថាខណ្ឌ ១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ២.៧.២.មុខងារនៅក្នុងការអនុវត្តន៍សាលក្រមស្ថាពរ

សាលក្រមមួយដែលចូលជាស្ថាពរ គឺមានន័យថា ផុតរយៈពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ហើយគឺមិនអាចធ្វើការកែប្រែបានឡើយ សូម្បីតែព្រះរាជអាជ្ញា ហើយតុលាការសាមីដែលចេញសាលក្រមនោះ ក៏មិនអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនឯងបានដែរ។ រាល់សាលក្រមទាំងអស់ត្រូវតែមានសំអាងហេតុ និងសេចក្តីសម្រេច។ សេចក្តីសំអាងហេតុ ជាមូលដ្ឋាននៃសេចក្តីសម្រេច។ សេចក្តីសម្រេចសម្តែងនូវបទល្មើសរបស់ជនជាប់ចោទថាមានពិរុទ្ធ ដោយត្រូវជាប់ពន្ធនាគារសមស្របទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ និងអាចត្រូវសងនូវសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះជាដើម។

ការអនុវត្តន៍ទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្តើមរបស់អយ្យការ។ អយ្យការធ្វើការអនុវត្តន៍ទោសនៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយទៅជាស្ថាពរ។ ការអនុវត្តន៍ទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតរបស់អយ្យការ។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា មិនមែនជាឧបសគ្គដល់ការអនុវត្តន៍ទោសទេ។ ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារនៅក្រោមឪវាទរបស់អយ្យការ។ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយការដើម្បីធានារ៉ាប់រងការអនុវត្តន៍ទោស។[៣២]

ចំពោះសាលក្រមព្រហ្មទណ្ឌ ដែលចូលជាស្ថាពរហើយតម្រូវឲ្យមានការដាក់ទោសជនសង្ស័យ ឬជនត្រូវចោទ ទោះបីមិនមានការស្នើសុំពីភាគីដើមបណ្តឹងក៏ព្រះរាជអាជ្ញាត្រូវអនុវត្តភ្លាមដែរ ព្រោះគាត់ជាដើមបណ្តឹងអាជ្ញា។

ការចុះអនុវត្តសាលក្រមនេះ ត្រូវបានបែងចែកជា ២ផ្នែក គឺៈ

#### ២.៧.២.១.សាលក្រមស្ថាពរចំពោះមុខ

ព្រះរាជអាជ្ញា ជាអ្នកអនុវត្តសាលក្រមដោយក្នុងករណីចាំបាច់ ព្រះរាជអាជ្ញា អាចកេណ្ឌកម្លាំងសាធារណៈបាន បើសាលក្រមស្ថាពរសម្រេចត្រូវផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ដូច្នេះព្រះរាជអាជ្ញា ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទដាក់ពន្ធនាគារតាមអំណាចរបស់សាលក្រម។

ក្នុងករណីផ្តន្ទាទោស ដែលមិនត្រូវបានសម្រេចឲ្យដាក់ក្នុងពន្ធនាគារ ដោយគ្រាន់តែសម្រេចឲ្យសងជម្ងឺចិត្ត ហើយភាគីចាញ់ក្តីមិនបានចូលរួមក្នុងសវនាការ និងបានប្តឹងទាស់ ហើយពេលមាន

[៣២] មាត្រា ៤៩៦, ៤៩៧ និង៤៩៨ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ការសុំឲ្យអនុវត្តសាលក្រមនេះ ព្រះរាជអាជ្ញា ត្រូវធ្វើការជូនដំណឹងដល់ភាគីចាញ់ក្តីដោយស្ម័គ្រចិត្ត ពីការអនុវត្តន៍សាលក្រមស្ថាពរនោះ។

ការស្នើសុំរបស់គូភាគី ដែលឈ្នះក្តីឲ្យអនុវត្តសាលក្រមស្ថាពរ ត្រូវចូលខ្លួនមកសុំប្រធានតុលាការ ហើយត្រូវចូលខ្លួនជួបជាមួយនាយកក្រឡាបញ្ជីតុលាការ ដើម្បីបង់ពន្ធសមាមាត្ររួចសុំសាលក្រមដែលចារទឹកប៊ិចពណ៌ក្រហមថា សាលក្រមបានចូលជាស្ថាពហើយ។

***ចំណាំ***

ករណីសាលក្រមមិនទាន់ស្ថាពរ ភាគីអាចៈ

- ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមចំពោះមុខ[៣៣]
- ប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។[៣៤]

**២.៧.២.២.សាលក្រមកំបាំងមុខ**

ក៏ជាអំណាចរបស់ព្រះរាជអាជ្ញាផងដែរ ក្នុងការអនុវត្តន៍សាលក្រមនេះ ហើយការអនុវត្តន៍សាលក្រមនេះ វាក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងការអនុវត្តន៍សាលក្រមចំពោះមុខដែរ។ បន្ទាប់ពីទទួលសម្រង់សាលក្រមព្រហ្មទណ្ឌរួចមក ក្រឡាបញ្ជីត្រូវចុះហត្ថលេខាទទួលយកសម្រង់សាលក្រមនេះ ប្រសិនបើត្រូវផ្តន្ទាទោសឲ្យដាក់ពន្ធនាគារនោះជាមួយសម្រង់សាលក្រមស្ថាពររបស់ចៅក្រមជំនុំជម្រះមកដាក់ពន្ធនាគារតាមសាលក្រម ហើយបញ្ជូនទៅស្នងការដ្ឋាននគរបាលគ្រប់ទីកន្លែងទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងរកចាប់ខ្លួនជនល្មើស។

***ចំណាំ***

ករណីសាលក្រមមិនទាន់ស្ថាពរ ភាគីអាចៈ

- ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមចំពោះមុខ[៣៥]
- ប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។[៣៦]

---

[៣៣] មាត្រា ៣៦០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៣៤] មាត្រា ៣៦២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៣៥] មាត្រា ៣៦០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៣៦] មាត្រា ៣៦២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ២.៧.៣.ការធ្វើអធិការកិច្ចពន្ធនាគារ

បើទោះបីជា ការគ្រប់គ្រងពន្ធនាគារជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃយ៉ាងណាក៏ដោយ ក៏ព្រះរាជអាជ្ញា មានសិទ្ធិធ្វើការត្រួតពិនិត្យពន្ធនាគារបានជាប្រចាំ។[៣៧]

ព្រះរាជអាជ្ញា ត្រូវចុះពិនិត្យពន្ធនាគារឲ្យបានទៀងទាត់ និងហ្មត់ចត់បំផុតដោយព្រះរាជអាជ្ញាត្រូវអនុវត្តតាមខ្លឹមសាររបស់លិខិតលេខ ៥០៩ រប.៩១០៦-៩៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៣ របស់ក្រសួងយុត្តិធម៌ គឺ៖

១. រៀងរាល់ខែនីមួយៗ ព្រះរាជអាជ្ញា ត្រូវចុះពិនិត្យពន្ធនាគារ និងមន្ទីរឃុំឃាំងខេត្ត-ក្រុង ឲ្យបានយ៉ាងតិច២ដង គឺធ្វើឡើងនៅពាក់កណ្តាលខែ និងចុងខែនីមួយៗក្នុងករណីចាំបាច់អាចចុះពិនិត្យបានគ្រប់ពេលវេលា។

២. ត្រូវត្រួតពិនិត្យមើលចំនួនទណ្ឌិតទាំងពីរភេទដែលកាត់ទោសរួចហើយ ចំនួនពិរុទ្ធជនដែលឃាត់ខ្លួនធ្វើដោយនគរបាល និង ចៅក្រមស៊ើបសួរ ពិនិត្យថិរវេលានៃការឃាត់ខ្លួន និង ឃុំខ្លួននោះ។

៣. ត្រួតពិនិត្យពីស្ថានភាពរស់នៅរបស់ទណ្ឌិត និងពិរុទ្ធជនទាំងនោះ ហើយជាគោលការណ៍ដាក់ឲ្យរស់នៅដាច់ដោយឡែកពីគ្នា។

៤. ពិរុទ្ធជនត្រូវដាក់ឲ្យរស់នៅដាច់ដោយឡែកពីទណ្ឌិត។

៥. បន្ទប់ឃុំឃាំងមិនត្រូវដាក់ពិរុទ្ធជន ឬទណ្ឌិត ឲ្យចង្អៀតពេកនោះទេ។

៦. មិនត្រូវឲ្យទណ្ឌិត ឬពិរុទ្ធជន ដេកបន្ទប់ផ្ទាល់តដ្ឋទេ ត្រូវធ្វើគ្រែទាបៗឲ្យសម្រាកគ្រប់គ្នាដោយមានកន្ទេល ខ្នើយ មុង ភួយ ផង។

៧. ពិនិត្យអនាម័យ និង សុខភាព ព្រមទាំងកត់ត្រាសំណូមពររបស់ជនទាំងនោះផង។

៨. រៀងរាល់បំណាច់ខែនីមួយៗ ព្រះរាជអាជ្ញា ត្រូវធ្វើរបាយការណ៍ពីលទ្ធផលនៃការត្រួតពិនិត្យរបស់ខ្លួនជូនមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីក្រសួងមានលទ្ធភាពចាត់ការតាមហេតុការណ៍ទាំងនោះ។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬនាំឲ្យបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវវាយដំ និងធ្វើទារុណកម្មឡើយ។

[៣៧] មាត្រា ៥០៩ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវសរសេររបាយការណ៍នានា ដែលជាសំណូមពរចាំបាច់របស់ទណ្ឌិត ឬពិរុទ្ធជន មកព្រះរាជអាជ្ញា ដូចជា ការហូបចុកមិនគ្រប់គ្រាន់ កន្លែងរស់នៅមិនមានអនាម័យល្អ ឬកន្លែងរស់នៅនោះមិនបានបែងចែកឲ្យបានច្បាស់លាស់រវាងអ្នកទោសប្រុស និងអ្នកទោសស្រី គឺឲ្យដេកជុំគ្នា ដែលជាលក្ខណៈមិនសមហេតុផល ឬមានការធ្វើទុក្ខទោសធ្ងន់ធ្ងរផ្សេងៗមកលើខ្លួនពីសំណាក់មន្ត្រីពន្ធនាគារ ឬមួយមានរបាយការណ៍ រាយការណ៍ពីប្រធានមន្ទីរឃុំឃាំងថាមានទណ្ឌិត ឬពិរុទ្ធជនណាមានជម្ងឺធ្ងន់ធ្ងរ ដែលត្រូវយកទៅព្យាបាលនៅក្រៅឃុំដោយមានលិខិតធ្វើកោសល្យវិច្ឆ័យបញ្ជាក់ពីគ្រូពេទ្យថាពិតជាមានជម្ងឺប្រាកដមែន ព្រះរាជអាជ្ញាត្រូវចាត់វិធានការចាំបាច់ទាំងឡាយ ដូចជា ត្រូវចុះទៅផ្ទាល់ដល់មន្ទីរឃុំឃាំង ដើម្បីពិនិត្យឲ្យបានច្បាស់លាស់ថា ពិតជាមានមែន ឬទេ បើមានគាត់ត្រូវពិនិត្យស្ថានភាពជាក់ស្តែង ហើយបើយល់ថា ទណ្ឌិត ឬពិរុទ្ធជនមានប្រភេទជម្ងឺធ្ងន់ធ្ងរ ឧទាហរណ៍ ជាប្រភេទជម្ងឺព្យាបាលមិនជា គាត់ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីសុំគោលការណ៍ដោះលែងដោយឥតលក្ខខណ្ឌ។ ប្រធានមន្ទីរឃុំឃាំងត្រូវធ្វើស្ថិតិពីចំនួនពិតប្រាកដរបស់ទណ្ឌិត និងពិរុទ្ធជន បើទណ្ឌិត ឬពិរុទ្ធជនណាគ្មានឈ្មោះក្នុងបញ្ជីត្រូវចាត់ទុកថាការឃុំឃាំងនេះខុសច្បាប់ ហើយត្រូវដោះលែងជនជាប់ឃុំឃាំងនោះភ្លាមដោយឥតលក្ខខណ្ឌ ហើយជនជាប់ឃុំឃាំងអាចប្តឹងទៅលើមន្ត្រីដែលឃុំខ្លួនដោយខុសច្បាប់នោះបាន។

## ២.៨.គោលការណ៍សំខាន់នៃអង្គការអយ្យការ

### ២.៨.១.អង្គឯកភាព

អង្គការអយ្យការជាអង្គឯកភាព ដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

ដូច្នេះ បានន័យថា ចៅក្រមអយ្យការគ្រប់រូបត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រម។[៣៨] ជាក់ស្តែងនៅពេលមានបទល្មើសធ្ងន់ធ្ងរព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[៣៩]

### ២.៨.២.អង្គអវិភាគ

អង្គការអយ្យការ គឺជាអង្គអវិភាគដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយ តាមការចាត់តាំងរបស់នាយឋានានុក្រម។

### ២.៨.៣.អង្គឯករាជ្យ

អង្គការអយ្យការគឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះ ត្រូវអនុវត្តទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងទៀត។ ប៉ុន្តែ សាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។[៤០]

### ២.៨.៤.អង្គមួយមិនអាចបំបែកបាន

សមាជិកអង្គការអយ្យការម្នាក់ជាអ្នកតំណាងឲ្យអង្គការអយ្យការទាំងមូល។ រាល់សមាជិកទាំងអស់អាចជំនួសគ្នាទៅវិញទៅមកបាននៅក្នុងរឿងក្តីតែមួយ។

### ២.៨.៥.គោលការណ៍នៃការកត់សម្គាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការ

គោលការណ៍នៃការកត់សម្គាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការចៅក្រមអយ្យការធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាជាការបំពេញវិជ្ជាជីវៈខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[៤១]

---

[៣៨] មាត្រា ៣០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៣៩] មាត្រា ៤០ កថាខណ្ឌ ៣ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៤០] មាត្រា ៧៥ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៤១] មាត្រា ៣០ កថាខណ្ឌ ២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ២.៨.៦.ការមិនទទួលខុសត្រូវក្នុងជំនាញវិជ្ជាជីវៈ

ចៅក្រមអយ្យការមិនទទួលខុសត្រូវទេ ប្រសិនបើខ្លួនចាញ់រឿងក្ដីព្រហ្មទណ្ឌនោះ។ ចៅក្រម-អយ្យការ ក៏មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាព្រះរាជអាជ្ញាឡើយ។ គោលការណ៍នេះ មិនត្រូវយកមកអនុវត្តឡើយក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញាប្រើប្រាស់ការសម្រេចរបស់ខ្លួនដោយរំលោភបំពានធ្ងន់ធ្ងរក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និងមុខងារដែលច្បាប់ប្រគល់ឲ្យ។[៤២]

## ២.៩.គោលការណ៍នៃភាពមិនលម្អៀង

ភាពមិនលម្អៀង នៃព្រះរាជអាជ្ញាបានដល់ការមិនប្រកាន់ឥរិយាបថលម្អៀងចំពោះជនជាប់ចោទដោយសារតែមូលហេតុ ភេទ នយោបាយ សង្គម វប្បធម៌ ឬការរើសអើងដទៃទៀត។ ដោយសារឈរលើទស្សនៈដែលថា ព្រះរាជអាជ្ញា ជាអ្នកធ្វើឲ្យមានការគោរពច្បាប់ ព្រះរាជអាជ្ញា គ្មានគំនិតស្អប់ ឬស្រឡាញ់ជននេះ ឬជននោះ ដោយសារគេមានទស្សនៈផ្ទុយ ឬស្របនឹងខ្លួនទេ។

### ២.៩.១.ឥរិយាបថរបស់ព្រះរាជអាជ្ញាចំពោះជនជាប់ចោទ

យើងដឹងថា ព្រះរាជអាជ្ញា ជាគូភាគីមួយតទល់នឹងជនជាប់ចោទនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។ ក្នុងឋានៈជាភាគីប្រឆាំង មិនមែនមានន័យថា ព្រះរាជអាជ្ញា ជាបច្ចាមិត្តនឹងជនជាប់ចោទនោះទេ។ ភាគីរងគ្រោះអាចមានមនោសញ្ចេតនាចំពោះជនជាប់ចោទខុសពីព្រះរាជអាជ្ញា ដោយសារគេទទួលរងការខូចខាតពីបទល្មើស។ តែអ្វីដែលព្រះរាជអាជ្ញាខូចខាតក្នុងរឿងព្រហ្មទណ្ឌមួយ គឺការរំលោភច្បាប់ និងការធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ។ ផលប្រយោជន៍របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្ដីនោះ គឺទាមទារឲ្យមានការគោរពច្បាប់ និងជួសជុលការខូចខាតដល់សង្គមមកវិញ។ ការសងសឹកជនជាប់ចោទ និងការធ្វើយ៉ាងណាឲ្យតែជនជាប់ចោទបានជាប់ពន្ធនាគារមិនមែនជាផលប្រយោជន៍របស់ព្រះរាជអាជ្ញាទេ។ បទល្មើសព្រហ្មទណ្ឌមួយដែលបានកើតឡើងអាចមិនមែនជាស្នាដៃរបស់ជនដែលកំពុងរងការចោទប្រកាន់ផងក៏ថាបាន។ ផលប្រយោជន៍របស់ព្រះរាជអាជ្ញា គឺទាមទារឲ្យចៅក្រមពិចារណាថា តើជនកំពុងចោទប្រកាន់នោះពិតជាអ្នកបានប្រព្រឹត្តឬយ៉ាងណា ហើយបើបានប្រព្រឹត្តមែន តើត្រូវផ្ដន្ទាទោសបែបណា? ដូច្នេះ នៅក្នុងសវនាការព្រះរាជអាជ្ញាជាអ្នកត្រូវប្រកាន់ជំហរធ្វើយ៉ាងណាឲ្យមានភាពសមរម្យ យុត្តិធម៌ នៅក្នុងការកាត់ក្ដី គឺមិនមែនកំណត់គោលដៅយកចាញ់យកឈ្នះដូចមេធាវីទេ ដោយសារតែមេធាវីបម្រើផលប្រយោជន៍កូនក្ដី រីឯព្រះរាជអាជ្ញាបម្រើ

[៤២] មាត្រា ៦ កថាខណ្ឌ ២ សេចក្ដីព្រាងច្បាប់ស្ដីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

ផលប្រយោជន៍សាធារណៈ។ ថ្វីបើព្រះរាជអាជ្ញាជាគូក្តី គោលការណ៍សច្ចធារណ៍នៃនិរទោសនៅតែត្រូវបានគោរពដោយតួអង្គទាំងអស់ រួមទាំងព្រះរាជអាជ្ញាផង។

### ២.៩.២.ការចោទប្រកាន់ក្នុងផលប្រយោជន៍ច្បាប់

ព្រះរាជអាជ្ញា មិនត្រូវលម្អៀងក្នុងការចោទប្រកាន់ ឬការមិនចោទប្រកាន់ និងក្នុងការស៊ើបអង្កេតរបស់ខ្លួនឡើយ។ ពិតមែនហើយ ព្រះរាជអាជ្ញាជាដើមបណ្តឹងអាជ្ញា ប៉ុន្តែព្រះរាជអាជ្ញា ធ្វើបណ្តឹងអាជ្ញាដោយផ្អែកតាមផលប្រយោជន៍ច្បាប់ បើសិនគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញា ត្រូវបញ្ឈប់ការចោទប្រកាន់។ ហ្នឹងធ្វើដូច្នេះបាន លុះត្រាណាតែព្រះរាជអាជ្ញាជម្រះគំនិតបុរេវិនិច្ឆ័យចេញ ព្រោះបុរេវិនិច្ឆ័យធ្វើឲ្យប៉ះពាល់ដល់ការយល់ និងវាយតម្លៃលើអង្គហេតុ និងការបកស្រាយ និងការអនុវត្តន៍ច្បាប់។ ការធ្វើបណ្តឹងដើម្បីរំខានដល់ជនជាប់ចោទ ឬដើម្បីគាបសង្កត់ជនជាប់ចោទក្នុងគោលបំណងផលប្រយោជន៍អ្វីមួយ គឺជាការប្រព្រឹត្តផ្ទុយពីក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

គោលការណ៍ណែនាំស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិ និងស្តង់ដារនៃការទទួលខុសត្រូវវិជ្ជាជីវៈ និងសេចក្តីថ្លែងពីករណីយកិច្ច និងសិទ្ធិជាសារវន្តរបស់ព្រះរាជអាជ្ញាទាមទារឲ្យព្រះរាជអាជ្ញា ស្វែងរកភស្តុតាងទាំងដាក់បន្ទុក និង ដោះបន្ទុកដោយមិនត្រូវមានគំនិតដើម្បីធ្វើយ៉ាងណាឲ្យជនជាប់ចោទទទួលការផ្តន្ទាទោសប៉ុណ្ណោះទេ ព្រោះផលប្រយោជន៍របស់ព្រះរាជអាជ្ញា គឺធ្វើយ៉ាងណាដើម្បីរកយុត្តិធម៌ និងការគោរពច្បាប់។ ការពិត នៅក្នុងប្រព័ន្ធដែលព្រះរាជអាជ្ញា មានតួនាទីជាអ្នកស៊ើបអង្កេតដើម្បីបង្កសំណុំរឿង ព្រះរាជអាជ្ញា មិនមែនស្វែងរកតែភស្តុតាងដាក់បន្ទុកតែប៉ុណ្ណោះទេ តែគាត់ពិនិត្យរកមើលលទ្ធភាពដែលអាចមានភស្តុតាងដោះបន្ទុកផងដែរ។ ព្រះរាជអាជ្ញា ជាអ្នកស្វែងរកនូវបទល្មើស ក៏ដូចជាភស្តុតាងដាក់បន្ទុក ប៉ុន្តែនៅក្នុងប្រទេសដែលមានចៅក្រមស៊ើបអង្កេត ដូចជា ប្រទេសបារាំង និងកម្ពុជាជាដើម ការស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក ជាភារកិច្ចរបស់ចៅក្រមស៊ើបអង្កេត។ ព្រះរាជអាជ្ញា ឬរដ្ឋអាជ្ញា គ្រាន់តែអាចធ្វើសេចក្តីសន្និដ្ឋានស្ថាពរស្នើសុំឲ្យលើកលែងចោទប្រកាន់ដាក់ជូនទៅចៅក្រមស៊ើបអង្កេត ប្រសិនបើគាត់យល់ថា ភស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់។ ក្នុងករណីនេះ វិធាននៃការមិនលម្អៀងរបស់ព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធនេះមិនសូវមានការទាក់ទងប៉ុន្មានទេ។ ប៉ុន្តែ នៅក្នុងដំណាក់ការនៃនីតិវិធីស៊ើបអង្កេតបឋម និងការស៊ើបអង្កេតបទល្មើសមជ្ឈិម ដែលព្រះរាជអាជ្ញាមានភារកិច្ចស៊ើបអង្កេតដោយខ្លួនឯង គោលការណ៍នៃភាពមិនលម្អៀងក្នុងបរិបទនេះ ប្រហែលជាត្រូវយកមកអនុវត្តបាន។

ស្តង់ដារនៃការទទួលខុសត្រូវវិជ្ជាជីវៈ និងសេចក្តីថ្លែងពីករណីយកិច្ច គឺជាសិទ្ធិជាសារវន្តរបស់ព្រះរាជអាជ្ញា តម្រូវថា ទោះបីការស៊ើបអង្កេតចេញលទ្ធផលឲ្យឃើញថា ជនជាប់ចោទមានប្រៀប ឬបង់ប្រៀបក្តី ឬនិយាយម្យ៉ាងទៀត ជនចាប់ចោទនឹងគ្មាន ឬមានពិរុទ្ធក្តី ព្រះរាជអាជ្ញា ត្រូវបើកបង្ហាញ

លទ្ធផលនោះឲ្យជនជាប់ចោទបានដឹង។ គោលការណ៍នេះប្រហែលជាមិនទាក់ទងនឹងព្រះរាជអាជ្ញា ក្នុងករណីដែលការស៊ើបអង្កេតដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតទេ ព្រោះជាភារកិច្ចបង្ហាញ លទ្ធផលនៃការស៊ើបអង្កេតស្ថិតនៅលើចៅក្រមស៊ើបអង្កេត។

### ២.៩.៣.ទំនាស់ផលប្រយោជន៍

គោលការណ៍ណែនាំស្តីអំពី តួនាទីព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិ និងស្តង់ដារ នៃការទទួលខុសត្រូវវិជ្ជាជីវៈ និងសេចក្តីថ្លែងពីករណីយកិច្ច និងសិទ្ធិជាសារវន្តរបស់ព្រះរាជអាជ្ញា មិនបានចែងជាក់លាក់ពីទំនាស់ផលប្រយោជន៍ ឬវិសមិភាពទេ។ នៅពេលណារឿងក្តីមួយត្រូវបាន ប្រគល់ឲ្យព្រះរាជអាជ្ញាណាម្នាក់ ស្ថានភាពរបស់ភាគីជាប់ចោទ អាចបង្កឲ្យមានវិសមភាពនៃមុខងារ របស់ព្រះរាជអាជ្ញាបាន ឧទាហរណ៍ ភាគីជាប់ចោទអាចជាមនុស្សជាប់សាច់ញាតិ មិត្តភក្តិ ឬអ្នកដែល ធ្លាប់មានផលប្រយោជន៍ជាប់ជាមួយព្រះរាជអាជ្ញា។ នៅក្នុងករណីបែបនេះ បើព្រះរាជអាជ្ញានោះ ទទួលយករឿងក្តីនោះ ភាពមិនលម្អៀង ឬភាពស្វាហាប់ ដើម្បីនាំជននោះទៅកាត់សេចក្តីនឹងត្រូវ ប៉ះពាល់។ ដើម្បីជៀសវាងការណ៍នេះ វិធានការមួយដែលសមស្រប គឺព្រះរាជអាជ្ញា ប្រហែលជាត្រូវ ដកខ្លួនពីរឿងក្តីនេះ កាលណាគាត់ដឹងថា ខ្លួនគាត់មានវិសមភាពនៅក្នុងរឿងក្តីនេះ។

### ២.៩.៤.ការគោរព និងលើកស្ទួយដំណើរការត្រឹមត្រូវតាមនីតិវិធីច្បាប់

ដោយសារព្រះរាជអាជ្ញា មានផលប្រយោជន៍តែក្នុងការធ្វើឲ្យមានការគោរពច្បាប់ ដូច្នេះ ព្រះរាជអាជ្ញា ក៏មានតួនាទីមួយដែរក្នុងការលើកស្ទួយដំណើរការត្រឹមត្រូវតាមនីតិវិធីច្បាប់។ ដំណើរ ការនេះទាមទារឲ្យព្រះរាជអាជ្ញាគោរពគោលការណ៍នៃការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ រួមមាន ការគោរពសិទ្ធិរបស់ជនជាប់ចោទ និងវិធានការទាំងឡាយដើម្បីស្វែងរក និង បង្ហាញភស្តុតាងដែល បានមកដោយស្របច្បាប់។ "គោលការណ៍ណែនាំអំពីតួនាទីរបស់ព្រះរាជអាជ្ញារបស់អង្គការសហ-ប្រជាជាតិ" ចែងថា ព្រះរាជអាជ្ញា មិនត្រូវប្រើភស្តុតាងដែលគាត់ជឿថាបានមកដោយមិនស្របច្បាប់។

នៅពេលដែលរឿងត្រូវបានបញ្ជូនមកខ្លួនក្តី នៅពេលធ្វើការស៊ើបអង្កេតដោយខ្លួនឯងក្តី ឬ ត្រួតពិនិត្យលើការស៊ើបអង្កេតដែលធ្វើដោយនគរបាលក្តី ព្រះរាជអាជ្ញា យកចិត្តទុកដាក់ធ្វើយ៉ាងណា ឲ្យភស្តុតាងដែលបញ្ជូន ឬប្រមូលបានមកនោះ ពិតជាបានមកដោយស្របច្បាប់។ នៅពេលដែល ព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនសង្ស័យដែលគេដឹង ឬមានជំនឿដោយ សមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយការប្រើប្រាស់នីតិវិធីមិនស្របច្បាប់ដែលអាច ចាត់ទុកថា ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅ នឹងការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មកាចសាហាវ អមនុស្សធម៌ ឬការរំលោភលើសិទ្ធិមនុស្ស និងសេរី ភាពផ្សេងៗដែលការពារដោយច្បាប់ និងរដ្ឋធម្មនុញ្ញ ដោយព្រះរាជអាជ្ញា ត្រូវបដិសេធមិនប្រើភស្តុតាង បែបនោះដាក់បន្ទុកទៅលើជនសង្ស័យឡើយ។ ព្រះរាជអាជ្ញា មិនត្រូវលើកទឹកចិត្តឲ្យមានការរំលោភ

តទៅទៀតទេ ដោយចាត់គ្រប់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថា បុគ្គលដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តខាងលើ ត្រូវបានចាត់ការតាមផ្លូវច្បាប់។ ព្រះរាជអាជ្ញា មិនត្រូវជួយលាក់បាំងអំពើទាំងនោះទេ ព្រោះការធ្វើដូច្នោះ ជាការលើកស្ទួយឲ្យមានអំពើពុករលួយ និងអាណាធិបតេយ្យនៅក្នុងការគ្រប់គ្រងវិស័យយុត្តិធម៌។

បើការស៊ើបអង្កេតជាភារកិច្ចរបស់ចៅក្រមស៊ើបអង្កេត តាមគោលការណ៍នេះ បើព្រះរាជអាជ្ញាមានហេតុផលនឹងជឿថា ភស្តុតាងដែលបានមកមិនត្រឹមត្រូវតាមច្បាប់ មធ្យោបាយដែលអាចឲ្យគាត់លើកស្ទួយគោលការណ៍នេះបាន គឺប្រហែលគាត់ត្រូវធ្វើញត្តិដើម្បីសុំដកភស្តុតាងនោះចេញពីសំណុំរឿង ហើយក្នុងករណីគ្មានភស្តុតាងណាផ្សេងទៀត ដើម្បីដាក់ពិរុទ្ធលើជនជាប់ចោទនោះគាត់ប្រហែលជាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរសុំលើកលែងចោទប្រកាន់តែម្តង។

### ២.៩.៥.ការរើសអើងពូជសាសន៍ និងមតិនយោបាយ

ដើម្បីរក្សាភាពមិនលម្អៀងនៅក្នុងដំណើរការនីតិវិធី ព្រះរាជអាជ្ញា គួរបំបាត់បុរេវិនិច្ឆ័យទាក់ទងទៅនឹងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយ ពិការភាព អាយុស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និងសង្គមឡើយ។ នេះជាគោលការណ៍ដែលចែងនៅក្នុងគោលការណ៍ណែនាំអំពីតួនាទីរបស់ព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិ ទាក់ទងនឹងភាពមិនលម្អៀងនៃព្រះរាជអាជ្ញា។ បើជនជាប់ចោទជាមនុស្សមាននិន្នាការយ៉ាងណាក្តី ព្រះរាជអាជ្ញា មិនត្រូវរិះរកមធ្យោបាយដើម្បីបន្ថែមទម្ងន់ការចោទប្រកាន់ ដោយសារតែខ្លួនមានស្ថានភាពផ្ទាល់ខ្លួន និងទស្សនៈនយោបាយផ្ទុយ ឬស្របនឹងជននោះទេ។ ព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍នៃភាពសត្យានុម័តដែលបានពិពណ៌នាខាងលើ។ ចំពោះជនជាប់ចោទដែលមានពូជសាសន៍ ឬសាសនាផ្សេងពីព្រះរាជអាជ្ញា អ្នកទាំងនោះត្រូវទទួលបានការប្រព្រឹត្តទៅដូចមនុស្សដទៃទៀតនៅក្នុងសង្គមដែរ។

### ២.៩.៦. ការថ្លែងការណ៍ជាសាធារណៈ

ការពិភាក្សាជាសាធារណៈពាក់ព័ន្ធនឹងសំណុំរឿង ដែលកំពុងដំណើរការអាចនាំឲ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត និងជំនឿទុកចិត្តលើភាពមិនលម្អៀងរបស់ខ្លួន។ ប៉ុន្តែការពិភាក្សាគ្នាអំពីប្រធានបទច្បាប់ទូទៅជម្រុញឲ្យមានការយល់ដឹងជាសាធារណៈពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ និងការគ្រប់គ្រងយុត្តិធម៌។ ប៉ុន្តែនៅក្នុងរឿងខ្លះ ការថ្លែងជាសាធារណៈរបស់ព្រះរាជអាជ្ញា អាចជាការឆ្លុះបញ្ចាំងនូវទស្សនៈស្ថាប័នអយ្យការ និងមុខតំណែងអយ្យការរបស់ខ្លួន។ ការថ្លែងទាំងនោះមានដូចជា រឿងដែលមានភាពចម្រូងចម្រាស់នយោបាយ រឿងដែលពាក់ព័ន្ធនឹងគណបក្សនយោបាយ រឿងដែលនាំឲ្យមានវិវាទ ឬការតិះទានពីបុគ្គលិកអយ្យការដែលមានទស្សនៈផ្ទុយគ្នា រឿងដែលបង្ហាញពីភាពលម្អៀង ឬបុរេវិនិច្ឆ័យចំពោះរឿងក្តីដែលខ្លួនកាន់។

### ២.៩.៧.ចំណាត់ការនឹងការរំលោភអំណាចរបស់មន្ត្រីសាធារណៈ

នៅពេលដែលមានការរំលោភអំណាចពីមន្ត្រីសាធារណៈ ជូនកាលព្រះរាជអាជ្ញា ត្រូវប្រឈមមុខនឹងឥទ្ធិពលដែលគាបសង្កត់មកលើខ្លួន ដែលជាការមួយធ្វើឲ្យព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តក្នុងការចោទប្រកាន់។ ការផ្តល់ និងរក្សាសុវត្ថិភាពចំពោះព្រះរាជអាជ្ញាអាចធ្វើឲ្យគេបំពេញភារកិច្ចរបស់គេបានដោយជោគជ័យ។ ប៉ុន្តែ នៅពេលខ្លះទៀត ការរួញរាក្នុងការធ្វើការចោទប្រកាន់កើតចេញពីគំនិតអង្គនិយម ដែលមានន័យថា អ្នករាជការជាមនុស្សនៅក្នុងអង្គរាជការដូចគ្នា។ គំនិតនេះផ្ទុយពីគោលការណ៍ស្មើភាពនៅចំពោះមុខច្បាប់។ ក្នុងករណីនេះ ព្រះរាជអាជ្ញា ត្រូវប្រព្រឹត្តស្មើមុខគ្នារវាងមនុស្សធម្មតា និងមន្ត្រីរាជការដោយត្រូវលុបបំបាត់ឲ្យអស់នូវគំនិតដែលនាំឲ្យមានការអនុគ្រោះទៅរកអ្នករាជការគ្នាឯងនេះ។

នៅពេលណាបានដឹង ឬទទួលបណ្តឹងទាក់ទងនឹងមន្ត្រីសាធារណៈ ព្រះរាជអាជ្ញាត្រូវប្រតិបត្តិខ្លួនឲ្យស្របនឹងច្បាប់ ដោយយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញា ចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬ បទឧក្រិដ្ឋដទៃទៀតដែលប្រឆាំងនឹងច្បាប់ជាតិ និងអន្តរជាតិ។

## ២.១០.ឯករាជ្យភាព

ព្រះរាជអាជ្ញាទាំងឡាយត្រូវអនុវត្តមុខងារ និងតួនាទីរបស់ខ្លួន ដោយឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួល ការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោល ពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ។[៤៣]

ឯករាជ្យភាពរបស់ព្រះរាជអាជ្ញា គឺជាគោលការណ៍សំខាន់នៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន។ កាលណាព្រះរាជអាជ្ញា គ្មានឯករាជ្យនោះទេ វានាំឲ្យសេចក្តីសម្រេចរបស់ខ្លួនមានភាពអយុត្តិធម៌រងនូវការរិះគន់។ ឯករាជ្យភាពព្រះរាជអាជ្ញា ខុសគ្នាពីឯករាជ្យភាពចៅក្រម។ នៅពេលទទួលរឿងក្តីណាមួយហើយចៅក្រមមិនមានកាតព្វកិច្ចត្រូវធ្វើតាមបញ្ជារបស់អ្នកណាមួយឡើយរួមទាំងសហសេរិក ឬថ្នាក់លើរបស់ខ្លួន ដូចជា ប្រធានតុលាការ ឬចៅក្រមនៅតុលាការថ្នាក់លើផងដែរ លើកលែងតែតាមរយៈសាលក្រម ឬសាលដីការបស់តុលាការនេះដែលបង្គាប់ឲ្យអនុវត្តតាម។ នៅក្នុងប្រព័ន្ធអយ្យការភាគច្រើន ព្រះរាជអាជ្ញាជាមន្ត្រីដែលមានលំដាប់ឋានានុក្រម។ គេធ្វើការដោយឯករាជ្យផង និងតាមការបង្គាប់របស់ថ្នាក់លើរបស់ខ្លួនផង។ ដូច្នេះ នៅក្នុងរឿងក្តីមួយ ព្រះរាជអាជ្ញាអាចនឹងទទួលរងឥទ្ធិពលផ្ទៃក្នុងផង និងឥទ្ធិពលខាងក្រៅផង។ នៅក្នុងជីវភាពប្រចាំថ្ងៃព្រះរាជអាជ្ញាគួរប្រកាន់

[៤៣] មាត្រា ៧៧ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

អាកប្បកិរិយាយ៉ាងណាមិនឲ្យសាធារណៈជនមើលឃើញថា ខ្លួនជាឧបករណ៍នយោបាយ ឬសេដ្ឋកិច្ចរបស់ជនណា ឬក្រុមណាមួយឡើយ។

### ២.១០.១.ឥទ្ធិពលផ្ទៃក្រៅ

ឥទ្ធិពលផ្ទៃក្រៅបានដល់ការគាបសង្កត់ដែលមានលក្ខណៈជានយោបាយសេដ្ឋកិច្ច និងសន្តិសុខជាដើម។ ដោយសារព្រះរាជអាជ្ញា ជាតួអង្គដែលជម្រុញឲ្យបណ្តឹងព្រហ្មទណ្ឌមានចលនាទៅមុខ ការគាបសង្កត់អាចមានលក្ខណៈជាការបន្ទុចបង្អាក់មិនឲ្យព្រះរាជអាជ្ញាចាត់ការបណ្តឹងណាមួយដែលខ្លួនយល់ថា តាមផ្លូវច្បាប់ និងដើម្បីផលប្រយោជន៍សាធារណៈ ត្រូវតែចាត់ការលើបទល្មើសណាមួយដែលខ្លួនបានដឹង ឬដែលត្រូវបានប្តឹងមក។ ម្យ៉ាងវិញទៀត នៅក្នុងរឿងខ្លះដែលខ្លួនយល់ថា មិនគួរចាត់ការដោយសារវាមិនបម្រើឲ្យផលប្រយោជន៍យុត្តិធម៌ តែបែរជាទទួលការគាបសង្កត់ឲ្យចាត់ការទៅវិញ។ ការទប់ទល់នឹងឥទ្ធិពលពីខាងក្រៅ គឺជាតម្លៃសីលធម៌មួយរបស់ព្រះរាជអាជ្ញា។

ក្រៅពីព្យាយាមទប់ទល់នឹងការគាបសង្កត់ពីខាងក្រៅ ព្រះរាជអាជ្ញា ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួនដោយមិនដាក់ខ្លួនឯងឲ្យនៅចំណុះអាជ្ញាធររដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតដែលជាការមួយធ្វើឲ្យកិត្តិយសនៃវិជ្ជាជីវៈរបស់ខ្លួនអាប់ឱន។

ថ្វីបើព្រះរាជអាជ្ញាឯករាជ្យពីជនរងគ្រោះ ប៉ុន្តែនៅពេលបំពេញមុខងារ និងភារកិច្ចព្រះរាជអាជ្ញាត្រូវយកចិត្តទុកដាក់ដល់ផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះដែរ។ ព្រះរាជអាជ្ញា ត្រូវប្រាប់ជនរងគ្រោះឲ្យគេបានដឹងពីសិទ្ធិទាំងអស់របស់គេនៅក្នុងដំណើរការព្រហ្មទណ្ឌ ព្រមទាំងធ្វើយ៉ាងណាឲ្យសិទ្ធិទាំងនោះបានសម្រេចទៀតផង។ សិទ្ធិទាំងនោះរួមមានៈ

- លទ្ធភាពទទួលបានយន្តការយុត្តិធម៌ និងការជួសជុលឆាប់រហ័ស
- ការដឹងពីការជឿនលឿននៃរឿងក្តី (តើរឿងក្តីរបស់គេបានឈានដល់ដំណាក់ការណាហើយ)
- ការជូនមតិរបស់ជនរងគ្រោះនៅគ្រប់ដំណាក់ការនៃរឿងក្តី
- ការការពារជាឯកជន និងសុវត្ថិភាពរបស់ជនរងគ្រោះ គ្រួសារ និងសាក្សីរបស់គេ
- លទ្ធភាពរកដំណោះស្រាយតាមយន្តការក្រៅផ្លូវការក្តី(ក្រៅពីនីតិវិធីតុលាការ)។

ទោះបីជនរងគ្រោះអាចរកដំណោះស្រាយតាមយន្តការក្រៅផ្លូវការក្តី ការសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីបន្ត ឬមិនបន្តជាសេចក្តីសម្រេចដោយឯករាជ្យរបស់ព្រះរាជអាជ្ញា ដោយពិចារណាយ៉ាងណាយកចិត្តទុកដាក់ដល់ផលប្រយោជន៍សាធារណៈប្រកបដោយយុត្តិធម៌។

ដើម្បីឲ្យការប្រតិបត្តិចំណុចសីលធម៌នេះសម្រេចបានដោយជោគជ័យ ត្រូវមានវិធានច្បាប់ និងរដ្ឋបាលនានា ដែលធានាសន្តិសុខ និងសុវត្ថិភាពដល់ព្រះរាជអាជ្ញា និងគ្រួសាររបស់គេនៅពេល

ណាមានការគំរាមកំហែងពីប្រភពខាងក្រៅនោះ។ ជាងនេះទៀត ព្រះរាជអាជ្ញា ត្រូវទទួលការការពារទល់នឹងការដាក់ឲ្យព្រះរាជអាជ្ញា រងនឹងការទទួលខុសត្រូវចំពោះផ្នែករដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬការទទួលខុសត្រូវដទៃទៀត ដែលកើតចេញពីការបំពេញមុខងារតាមផ្លូវច្បាប់របស់គេ។

ជួនកាល នៅក្នុងប្រព័ន្ធអយ្យការដែលមានរចនាសម្ព័ន្ធផ្សារភ្ជាប់ជាមួយនឹងអំណាចនីតិប្រតិបត្តិ ដែលច្បាប់អនុញ្ញាតឲ្យអំណាចនីតិប្រតិបត្តិអាចចេញសេចក្តីបង្គាប់ ដូចក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញអធិបញ្ញា ឬសេចក្តីបង្គាប់ទៅព្រះរាជអាជ្ញាបាន ដើម្បីរក្សាឯករាជ្យភាពរបស់ព្រះរាជអាជ្ញា មានវិធានការពីរដែលប្រទេសជាច្រើនបានអនុម័តប្រើ។ វិធានការទី១ មានជាវិធានការទាក់ទងទៅនឹងសេចក្តីបង្គាប់ចំពោះរឿងក្តីជាក់លាក់ណាមួយ។ វិធានការទី២ គឺជាសេចក្តីណែនាំទូទៅដែលជាសេចក្តីថ្លែងគោលនយោបាយទូទៅសម្រាប់ដំណើរការព្រហ្មទណ្ឌ។ ចំពោះករណីជាក់លាក់ សេចក្តីបង្គាប់ត្រូវធ្វើដោយមានតម្លាភាព អាជ្ញាធរដែលចេញសេចក្តីបង្គាប់នោះមិនចេញសេចក្តីបង្គាប់ណាដែលមិនស្ថិតនៅក្នុងដែនអំណាចរបស់ខ្លួន។ នៅក្នុងវិធានការដែលជាគោលនយោបាយទូទៅ អាជ្ញាធរចេញជាសារាចរ ឬប្រកាស ដែលចែងជាសេចក្តីណែនាំទូទៅទាក់ទងទៅនឹងរបៀបចាត់ការរឿងក្តី ដែលព្រះរាជអាជ្ញា អាចយកទៅអនុវត្តឲ្យមានភាពរលូនទូទាំងប្រទេស។

ឯករាជ្យភាពរបស់ព្រះរាជអាជ្ញា ក៏ទាមទារឲ្យមានការយកចិត្តទុកដាក់ទៅលើជីវភាពរបស់គេដែរ។ ដូច្នេះ ព្រះរាជអាជ្ញា គួរទទួលបានប្រាក់បៀវត្សគ្រប់គ្រាន់ មានប្រាក់សោធនិវត្តន៍សមរម្យ និងមានច្បាប់កំណត់លក្ខខណ្ឌនៃការតែងតាំងសមរម្យដែលជៀសវាងការដកហូតដោយទំនើងចិត្ត។

### ២.១០.២.ឥទ្ធិពលផ្ទៃក្នុង

ដោយសារព្រះរាជអាជ្ញា ត្រូវគោរពតាមឋានានុក្រម ដើម្បីជៀសវាងការប្រើឥទ្ធិពលមិនត្រឹមត្រូវរបស់ថ្នាក់លើទៅកាន់ព្រះរាជអាជ្ញានៅក្រោមបង្គាប់ ក្រមសីលធម៌ព្រះរាជអាជ្ញាទាមទារឲ្យមានវិធានការខ្លះដើម្បីការពារទប់ទល់នឹងការរំលោភអំណាចរបស់ថ្នាក់លើ។ ថ្នាក់លើនោះរួមមានព្រះរាជអាជ្ញានៅក្នុងមន្ទីរអយ្យការអមតុលាការនីមួយៗ អគ្គព្រះរាជអាជ្ញា ដែលគ្រប់គ្រងអយ្យការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ នៅក្នុងករណីដូច្នេះ ក្រមសីលធម៌ អាចហាមប្រាមថ្នាក់លើរបស់ព្រះរាជអាជ្ញាមិនឲ្យប្រើអំណាចដែលគ្មានហេតុផលបញ្ជាក់ត្រឹមត្រូវ ដើម្បីជ្រៀតជ្រែកលើកិច្ចការរបស់អ្នកនៅក្រោមបង្គាប់។ ជួនកាល ការសងសឹករបស់ថ្នាក់លើទៅលើព្រះរាជអាជ្ញា ដែលជាអ្នកនៅក្រោមបង្គាប់អាចធ្វើទៅបាននៅពេលស្នើសុំឡើងឋានន្តរសក្តិ បើថ្នាក់លើជាអ្នកមានអំណាចធ្វើមូលវិចារណ៍លើការបំពេញភារកិច្ចរបស់អ្នកនៅក្រោមបង្គាប់។ ដើម្បីជៀសវាងការកើតឡើងបែបនេះ នីតិវិធីនៃការវាយតម្លៃដើម្បីការស្នើឡើងឋានន្តរសក្តិ គួរចែងឲ្យមានភាពយុត្តិធម៌ សត្យានុម័ត និងជៀសវាងការគុំកួន ដោយគួរបើកឲ្យសាមីជនដឹង និងមានមតិអត្ថាធិប្បាយលើការវាយតម្លៃនោះដែរ។

### ២.១០.៣.ការប្រកាន់អាកប្បកិរិយាដែលញ៉ាំងឲ្យមានទំនុកចិត្តសាធារណៈ

ដោយសារព្រះរាជអាជ្ញា ត្រូវបំពេញមុខងារដើម្បីបម្រើផលប្រយោជន៍សាធារណៈប្រកបដោយយុត្តិធម៌ ជាការសំខាន់ដែលព្រះរាជអាជ្ញា ត្រូវសម្តែងអាកប្បកិរិយាបែបណា ដើម្បីមិនឲ្យសាធារណជនមើលឃើញថា ខ្លួនហាក់ដូចជាអ្នកបម្រើរបស់ក្រុមនយោបាយ ឬសេដ្ឋកិច្ចណាមួយ។ ការប្រកាន់ជំហរឯករាជ្យហុចអត្ថប្រយោជន៍ឲ្យដល់ព្រះរាជអាជ្ញានូវទំនុកចិត្ត និងកិច្ចសហការពីសាធារណជន។

បទដ្ឋានអន្តរជាតិមិនបានចែងឲ្យព្រះរាជអាជ្ញាត្រូវប្រកាន់អាកប្បកិរិយាបែបណាទេ ទាក់ទងទៅនឹងសម្ព័ន្ធភាពរបស់ព្រះរាជអាជ្ញានៅក្នុងកិច្ចការនយោបាយ។ ការនេះប្រហែលដោយសារបទដ្ឋាននោះគិតទៅដល់យុត្តាធិការខ្លះដែលព្រះរាជអាជ្ញាទទួលការតែងតាំងនយោបាយ។

ដើម្បីលើកស្ទួយទំនុកចិត្ត និងការពារមុខមាត់របស់ខ្លួន ព្រះរាជអាជ្ញាគួរស្ថិតនៅជាអព្យាក្រឹតក្នុងសកម្មភាពនយោបាយ ដូចជា ការធ្វើយុទ្ធនាការឃោសនាឲ្យគណបក្សនយោបាយមួយ ឬធ្វើការរៃអង្គាសថវិកាដើម្បីគាំទ្រគណបក្សនយោបាយ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញា មិនគួរជាសមាជិករបស់គណបក្សនយោបាយណាមួយទេ ព្រោះសមាជិកភាពនេះបង្កើតកាតព្វកិច្ចរបស់ខ្លួនចំពោះគណបក្សនយោបាយនោះ ដូច្នេះនឹងនាំឲ្យមានទំនាក់ទំនងផលប្រយោជន៍ នៅពេលណាព្រះរាជអាជ្ញាចាត់ការរឿងក្តីមួយទល់នឹងភាគីមួយដែលស្ថិតនៅក្នុងគណបក្សផ្សេង ឬមិនហ៊ានចាត់ការទល់នឹងភាគីមួយដែលស្ថិតក្នុងគណបក្សដូចខ្លួន។ មានករណីខ្លះទៀត ដែលមិនមានភាគីនៃរឿងក្តីជាសមាជិកគណបក្សនយោបាយទេ ប៉ុន្តែ កម្មវត្ថុនៃរឿងក្តីទាក់ទងទៅនឹងរឿងចម្រុងចម្រាស់ខាងមតិនយោបាយ។ ការណ៍នេះ រិតតែធ្វើឲ្យមតិសាធារណជន មានការសង្ស័យច្រើនទៅទៀត បើរឿងដែលមានកម្មវត្ថុដូចគ្នា តែផ្ទុយទៅវិញ ព្រះរាជអាជ្ញាបែរជាចាត់ការមិនទៀងទាត់ដោយម្តងចាត់ការបែបអញ្ចេះម្តងចាត់ការបែបអញ្ចុះ។ ដូច្នេះ ការពាក់ព័ន្ធរបស់ព្រះរាជអាជ្ញានៅក្នុងរឿងនយោបាយក្នុងរូបភាពជាសមាជិកភាពក្តី ឬការសម្តែងឲ្យឃើញថា ខ្លួនមានបុរេវិនិច្ឆ័យខាងនយោបាយក្តី (Political prejudicee) ជាការធ្វើឲ្យទំនុកចិត្តសាធារណៈរបស់ព្រះរាជអាជ្ញាចុះថយ។ អព្យាក្រឹតភាពក្នុងសកម្មភាពនយោបាយ គឺជាកត្តាសំខាន់ ដើម្បីរក្សាការពារឯករាជ្យភាពរបស់ខ្លួនជាព្រះរាជអាជ្ញា។

ព្រះរាជអាជ្ញា អាចចូលរួមផ្តល់ទស្សនៈទានដល់ការគ្រប់គ្រងវិស័យយុត្តិធម៌ និងការកែលម្អច្បាប់ដោយប្រើចំណេះដឹងផ្នែកច្បាប់ និងបទពិសោធន៍ផ្នែកអយ្យការរបស់ខ្លួន។ ម្យ៉ាងទៀត ព្រះរាជអាជ្ញា អាចបង្កើត ឬចូលរួមនៅក្នុងសមាគមព្រះរាជអាជ្ញា ឬចូលរួមនៅក្នុងអង្គការដទៃ ដែលតំណាងផលប្រយោជន៍របស់ព្រះរាជអាជ្ញា។ ការបង្កើត ឬការចូលរួមក្នុងសមាគម ឬក្នុងអង្គការដទៃ

ដែលតំណាងផលប្រយោជន៍ព្រះរាជអាជ្ញា មិនធ្វើឲ្យប៉ះពាល់នូវឯករាជ្យភាពរបស់ខ្លួនទេ តែផ្ទុយទៅវិញ គឺជួយជម្រុញ និងការពារឯករាជ្យភាពរបស់អយ្យការ និងវិជ្ជាជីវៈរបស់ខ្លួន។

### ២.១០.៤.ភាពសត្យានុម័ត

ជួលកាលមានអត្ថាធិប្បាយរបស់សាធារណជន ឬសារព័ត៌មាន ឬប្រភពផ្សេងទៀត ដែលធ្វើឲ្យព្រះរាជអាជ្ញាមានការរារែកក្នុងការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងរឿងក្ដីមួយ។ ភាពសត្យានុម័តគឺជាតម្លៃសីលធម៌មួយរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ធ្វើសេចក្ដីសម្រេចដោយឈរលើមូលដ្ឋាននៃការវាយតម្លៃលើអង្គហេតុ អង្គច្បាប់ និងផ្អែកលើចំណេះដឹងផ្នែកច្បាប់។ កាលណាភស្តុតាងបង្ហាញអង្គហេតុច្បាស់លាស់ថា បទល្មើសមួយបានកើតឡើង ហើយប្រភេទនៃបទល្មើសនោះទាមទារឲ្យអនុវត្តច្បាប់ព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ ព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅតែពីចាត់ការបណ្ដឹងព្រហ្មទណ្ឌដោយគ្មានរុញរា។ ផ្ទុយទៅវិញ បើអង្គហេតុមិនច្បាស់លាស់ ព្រះរាជអាជ្ញាត្រូវសម្រេចមិនចាត់ការបណ្ដឹងនោះ ដោយមិនទទួលរងនូវឥទ្ធិពលឬការគាបសង្កត់តាមរូបភាពណាមួយទេ។

## ២.១១.សុចរិតភាព ឬសេចក្ដីទៀងត្រង់

ភាពសុចរិត ជាតម្លៃរួមសម្រាប់មន្ត្រីទាំងអស់ ជាពិសេសមន្ត្រីដែលមានភារកិច្ចទៅលើវិស័យយុត្តិធម៌។ ភាពសុចរិតនេះ ជាគុណសម្បត្តិមួយដែលធ្វើឲ្យសាធារណៈជនមើលឃើញពីភាពថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ព្រះរាជអាជ្ញា។

ភាពសុចរិតបានដល់ការមិនប្រព្រឹត្តអ្វីដែលច្បាប់មិនអនុញ្ញាតឲ្យធ្វើ ឬការធ្វើអ្វីមួយដែលខុសសីលធម៌នៃវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងការបំពេញភារកិច្ចអ្វីមួយ ភារកិច្ចនោះត្រូវបំពេញដោយយកចិត្តទុកដាក់មិនធ្វើឲ្យខូចប្រយោជន៍អ្នកដទៃ។ ការបំពេញ ឬមិនបំពេញភារកិច្ចអ្វីមួយជាថ្នូរនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីផលប្រយោជន៍របស់អ្នកទីបី ជាការធ្វើឲ្យខូចប្រយោជន៍ដល់ភាគីដែលពាក់ព័ន្ធ និងផលប្រយោជន៍សាធារណៈ។ ការប្រព្រឹត្តអំពើពុករលួយជាឧទាហរណ៍មួយយ៉ាងជាក់ស្តែងនៃការទទួលផលប្រយោជន៍ជាថ្នូរនឹងការមិនចាត់ការ ឬក៏ចាត់ការចំពោះរឿងណាមួយ។

ការកេងបន្លំមូលនិធិរបស់រដ្ឋនៅក្នុងការបំពេញភារកិច្ចផ្លូវការរបស់ព្រះរាជអាជ្ញា ក៏រាប់បញ្ចូលក្នុងភាពមិនសុចរិតបានដែរ ឧទាហរណ៍ ការកេងបន្លំប្រាក់បេសកកម្មជាដើម។

ការចោទប្រកាន់ដោយមិនខ្វល់ពីលផលវិបាកដែលនឹងត្រូវរងដោយជនជាប់ចោទ ក៏នាំឲ្យមានផលប៉ះពាល់ដល់ភាពសុចរិតនៃព្រះរាជអាជ្ញាដែរ។ ការធ្វើលិខិតចោទប្រកាន់ឲ្យរួចពីដៃ ដោយគិតថាការស្វែងរកភស្តុតាងដើម្បីដាក់បន្ទុក ឬដោះបន្ទុកជារឿងរបស់ចៅក្រមស៊ើបអង្កេត។ ការធ្វើដោយគ្មានការទទួលខុសត្រូវបែបនេះធ្វើឲ្យសាធារណៈជនសួរថា តើព្រះរាជអាជ្ញា ធ្វើនេះដើម្បីសង

សឹកគេ ឬធ្វើដោយបានទទួលសំណូកពីភាគីម្ខាងទៀត ឧទាហរណ៍ នៅក្នុងរឿងបំណុលមួយដើមបណ្តឹងមកប្តឹងព្រះរាជអាជ្ញា ហើយរឿងនោះជារឿងខកខានបំពេញភារកិច្ចនៃកិច្ចសន្យាសុទ្ធសាធតែផ្ទុយទៅវិញ ព្រះរាជអាជ្ញា បែរជាចោទជាបទល្មើសឆបោក ឬបទល្មើសរំលោភលើសេចក្តីទុកចិត្ត។ នេះជាអំពើទុច្ចរិតមួយ បើព្រះរាជអាជ្ញាខ្លួនឯងមិនបានច្រឡំនៅក្នុងអង្គហេតុ និងអង្គច្បាប់ទេនោះ។

ជួនកាលទៀត ក៏មានករណីនៃការប្រើកិត្យានុភាពនៃមុខតំណែងអយ្យការរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ។ ឧទាហរណ៍ ព្រះរាជអាជ្ញាយកឈ្មោះរបស់ខ្លួនទៅធានាការរកស៊ីមួយ ឬអន្តរកម្មអ្វីមួយ ដូចជាបញ្ជាក់លិខិត ឬឯកសារនានាឲ្យមិត្តភក្តិ ឬបងប្អូនសាច់ញាតិដោយប្រើប្រាស់ឈ្មោះ មុខតំណែង និងឋានៈរបស់ខ្លួន ដើម្បីបានការអនុគ្រោះណាមួយ ប្រើប្រាស់ឈ្មោះ មុខតំណែង និងឋានៈរបស់ខ្លួន ដើម្បីឲ្យមានការផ្គាប់ផ្គុន ឬការយកចិត្តទុកដាក់ពិសេស ដូចជាលិខិតដែលធ្វើឡើងជាលក្ខណៈឯកជនទាក់ទងនឹងបញ្ហាបុគ្គលផ្ទាល់ខ្លួន មានជាអាទិ៍ ការទិញផ្ទះ ទិញរថយន្ត ជាដើម។

## ២.១២.សេចក្តីថ្លៃថ្នូរ និងភាពស្អាតបាត

សេចក្តីថ្លៃថ្នូរ និងភាពស្អាតបាតបានដល់ការប្រកាន់អាកប្បកិរិយាសមរម្យនៅក្នុងជីវភាពឯកជន និងជីវភាពសាធារណៈ។ អាកប្បកិរិយាខ្លះ គ្មានការហាមឃាត់ដោយច្បាប់ទេ ប៉ុន្តែ ការប្រព្រឹត្តនាំឲ្យមានការអាប់ឱនដល់រូបភាពវិជ្ជមានរបស់ព្រះរាជអាជ្ញា។ ការអាប់ឱននេះនឹងនាំឲ្យមានផលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរវិជ្ជាជីវៈព្រះរាជអាជ្ញាផង និងស្ថាប័នរបស់ព្រះរាជអាជ្ញាផង។

### ២.១២.១.ក្នុងជីវភាពឯកជន

ឧបមាថា ព្រះរាជអាជ្ញាម្នាក់ផឹកស្រវឹងដើរគ្រេតទ្រោតពេញផ្លូវថ្នល់ ហើយស្រែកជេរគេជេរឯង។ អាកប្បកិរិយាបែបនេះនាំឲ្យបាត់បង់ទំនុកចិត្តពីសាធារណជនថា តើព្រះរាជអាជ្ញារូបនេះអាចបំពេញមុខងាររបស់ខ្លួនដោយត្រឹមត្រូវដែរ ឬទេ? ឧទាហរណ៍មួយទៀត គឺព្រះរាជអាជ្ញា ដែលឈ្លោះជេរប្រពន្ធកូនប្រចាំថ្ងៃ។ អាកប្បកិរិយាបែបនេះ នាំឲ្យសាធារណជនមានការមន្ទិលថា តើព្រះរាជអាជ្ញារូបនេះនឹងមានការយកចិត្តទុកដាក់ និងឈឺឆ្អាលដល់ករណីអំពើហិង្សា នៅពេលណាករណីបែបនេះត្រូវបានប្រគល់ឲ្យខ្លួនដែរ ឬទេ?

ក្នុងខណៈដែលច្បាប់ហាមប្រាមទ្វេរពន្ធភាព ឬពហុពន្ធភាព ហើយព្រះរាជអាជ្ញាបែរជាមានប្រពន្ធ ២ ឬ៣ ហើយមានការឈ្លោះហែកកកាយគ្នាធ្វើឲ្យលេចឮដល់សាធារណជននោះ ការណ៍នេះក៏នឹងធ្វើឲ្យអាប់ឱនកិត្តិយសវិជ្ជាជីវៈផងផ្ទាល់ខ្លួនផង។សាធារណជននឹងមានការចំអកដល់ព្រះរាជអាជ្ញានោះផង និងវិជ្ជាជីវៈផង ដោយសារគេគិតថា ព្រះរាជអាជ្ញា ត្រូវមានតួនាទីគោរពច្បាប់មុនគេ ព្រោះខ្លួនជាឆ្មាំឃ្លាំមើលការបំពានច្បាប់។

ការសម្តែងនៅទីសាធារណៈពីការមិនអើពើនឹងច្បាប់ទម្លាប់ ក៏ជាការធ្វើឲ្យបាត់បង់ទំនុកចិត្តពីសាធារណជនដែរ។ ឧទាហរណ៍ ងាយជាងគេ គឺការមិនគោរពច្បាប់ចរាចរណ៍ ការមិនគោរពច្បាប់ពន្ធដារ ជាដើម។ បើព្រះរាជអាជ្ញា មិនគោរពបានសូម្បីតែច្បាប់តូចតាចមួយនោះ សាធារណជនពិតជាពិបាកនឹងជឿថា ព្រះរាជអាជ្ញា អាចនឹងគោរពច្បាប់ធំៗណាស់។

ព្រះរាជអាជ្ញា អាចប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួនដូចប្រជាពលរដ្ឋដទៃទៀតដែរនៅក្នុងការកំសាន្តផ្សេងៗនៅក្រៅពេលធ្វើការ ប៉ុន្តែ ទោះបីជាសកម្មភាពកំសាន្តនោះស្របច្បាប់ក្តី ពេលខ្លះក៏អាចនាំឲ្យព្រះរាជអាជ្ញាបាត់បង់នូវកិត្តិយសសេចក្តីថ្លៃថ្នូរដែរ ឧទាហរណ៍ ការចូលច្រៀងក្នុងក្លឹបហើយស្រវឹង និងប្រើអាកប្បកិរិយារំខានផ្លូវភេទដល់អ្នកបម្រើ។ ការណ៍នេះអាស្រ័យលើព្រះរាជអាជ្ញាខ្លួនឯងដែលត្រូវប្រើសុភវិនិច្ឆ័យថា តើទង្វើអ្វីមួយនៅក្នុងការកំសាន្តនោះមានលក្ខណៈសមរម្យនៅចំពោះមុខសាធារណជនយ៉ាងណា ដោយផ្អែកលើទំនៀមទម្លាប់សង្គម និងការចូលចិត្តរបស់សាធារណជន។

### ២.១២.២.ក្នុងជីវភាពវិជ្ជាជីវៈ

ការគោរពគ្នាទៅវិញទៅមករវាងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង និងទៅថ្នាក់លើទៅទៀតជាការធ្វើឲ្យការបំពេញភារកិច្ចរបស់អយ្យការមានប្រសិទ្ធភាព។ ប៉ុន្តែ ការគោរពនេះ មិនមែនមានន័យថា ជាការចំណុះនោះទេ។ ក្នុងខណៈដែលអ្នកនៅក្រោមបង្គាប់ត្រូវគោរពថ្នាក់លើ មន្ត្រីថ្នាក់លើក៏ត្រូវជៀសវាងការបំពានអំណាចដែរ។ បើការបំពានអំណាចនេះចេះតែរីករាលដាលស្ថាប័នអយ្យការទាំងមូលនឹងក្លាយទៅជាអាណាធិបតេយ្យ ហើយអាចបង្កឲ្យមានអំពើអយុត្តិធម៌កើតឡើង។

ការប្រាស្រ័យទាក់ទងល្អជាមួយមន្ត្រី និងបុគ្គលិកក្រោមឱវាទរបស់ខ្លួន ដោយភាពទន់ភ្លន់និង សមរម្យអាចបង្កើតបរិយាកាសសហប្រតិបត្តិការល្អក្នុងនាមជាមន្ត្រីបម្រើការពារផលប្រយោជន៍សាធារណៈ។

ការចាត់ការ ឬការធ្វើកិច្ចការមួយឲ្យបានឆាប់រហ័សទាន់ពេលនាំឲ្យមានការគោរពពីសាធារណជន។ ផ្ទុយទៅវិញ ការបង្អែបង្អង់ដោយគ្មានហេតុផលត្រឹមត្រូវនឹងធ្វើឲ្យបាត់បង់សិទ្ធិ និងផលប្រយោជន៍ភាគីដែលពាក់ព័ន្ធ ឧទាហរណ៍ ការផ្អឹបសំណុំរឿងដោយគ្មានហេតុផលត្រឹមត្រូវ។ ការចាត់ការទាន់ពេលវេលានេះទាក់ទងនឹងទំហំការងារ បុគ្គលិក ជំនួយការ គ្រប់គ្រាន់ សម្ភារៈ និងថវិកាសម្រាប់បម្រើការងារគ្រប់គ្រាន់ ពេលវេលា និងកិច្ចសហប្រតិបត្តិការពីបណ្តាអ្នកពាក់ព័ន្ធដែរ។ តែទោះជាយ៉ាងណាក្តី ការខិតខំប្រឹងប្រែងឲ្យអស់លទ្ធភាព គឺជាកត្តាចាំបាច់ដើម្បីបញ្ជាក់ពីការយកចិត្តទុកដាក់របស់ព្រះរាជអាជ្ញា នៅក្នុងការបំពេញភារកិច្ចរបស់គេ។

# ជំពូកទី ៣

# អំណាច និង ឯករាជ្យភាពរបស់ចៅក្រម

## ៣.១.លក្ខណៈសម្បត្តិរបស់ចៅក្រម

### ៣.១.១.ជំនាញវិជ្ជាជីវៈ

ចៅក្រម គឺជាមន្ត្រីសាធារណៈដែលទទួលការជ្រើសតាំងឲ្យដឹកនាំគ្រប់គ្រងកិច្ចការច្បាប់នៅតាមសាលាជម្រះក្តី។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ដែលចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពយ៉ាងម៉ឺងម៉ាត់ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។[៤៤] នៅក្នុងអាជីពរបស់ខ្លួន ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ។[៤៥]

### ៣.១.២.ការជ្រើសរើស

បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម ត្រូវតែជាអ្នកមានសមត្ថភាព និងជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ។

បើយោងតាមសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា បុគ្គលដែលត្រូវបានអនុញ្ញាតឲ្យប្រឡងជ្រើសរើសជាសិស្សចៅក្រម ចាំបាច់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុ ៣៥ឆ្នាំយ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ៤០ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង

៣. ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤. មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។[៤៦]

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រម ក៏អាចធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

---

[៤៤] មាត្រា ១២៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[៤៥] មាត្រា ៥ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៤៦] មាត្រា ១៩ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

១. មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ

២. មានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ឆ្នាំ

៣. មានអាយុមិនឲ្យលើសពី ៤៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

ចំពោះមេធាវី ក៏អាចប្រឡងចូលក្នុងក្របខណ្ឌនេះបានដែរ ដោយត្រូវគោរពតាមលក្ខខណ្ឌទាំង ៣ ខាងលើនេះដែរ។[៤៧]

### ៣.១.៣.ការបណ្តុះបណ្តាល

សាលាភូមិន្ទចៅក្រម ជ្រើសរើស និងធានារ៉ាប់រង ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ការបណ្តុះបណ្តាលបន្ត និង វិក្រឹត្យការ ចៅក្រម និង ព្រះរាជអាជ្ញាដែលកំពុងបំពេញការការនៅតាមសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា។

សាលាភូមិន្ទចៅក្រម ជាសាលាអនុវត្ត។ សិស្សចៅក្រម ត្រូវទទួលការបណ្តុះបណ្តាលបឋមខាងវិជ្ជាជីវៈដែលមានរយៈពេល២ឆ្នាំ។ ការងារបណ្តុះបណ្តាលរួមមាន ការបង្រៀនអំពីបច្ចេកទេសខាងតុលាការ និងការត្រិះរិះពិចារណាលើការិយាកម្មនៃការប្រតិបត្តិខាងវិជ្ជាជីវៈ។ សាលាភូមិន្ទចៅក្រមត្រូវរៀបចំឲ្យមានកម្មវិធីសិក្សាបន្ត និងថ្នាក់វិក្រឹត្យការសម្រាប់ចៅក្រម និង ព្រះរាជអាជ្ញា ដែលកំពុងធ្វើការិយាកម្មនៅសាលាជម្រះក្តី តាមបែបផែនដែលបានកំណត់ដោយបែបបទផ្ទៃក្នុង។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលបន្ត និងវិក្រឹត្យការ ត្រូវបានទទួលបន្ទុកដោយគណៈកម្មការវិទ្យាសាស្ត្រ និងគរុកោសល្យ ដែលបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល។

### ៣.១.៤.ការតែងតាំង

សិស្សចៅក្រម ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាចៅក្រមកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ។[៤៨]

បន្ទាប់ពីបានបំពេញកម្មសិក្សាចប់សព្វគ្រប់ហើយ ចៅក្រមកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម និង មានឋានន្តរសក្តិជាអនុចៅក្រមថ្នាក់ដំបូងគេ។[៤៩]

យោងតាមមាត្រា ១៣៤ថ្មី នៃរដ្ឋធម្មនុញ្ញត្រង់កថាខណ្ឌ ៣ និងយោងតាមមាត្រា ១១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយជាពិសេសថែមទៀតនោះ

[៤៧] មាត្រា ២៣ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៤៨] មាត្រា ២៤ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៤៩] មាត្រា ២៥ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

គឺយោងតាមមាត្រា៨៣ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងមាត្រា ១៨ វាក្យខណ្ឌ ១ នៃសេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានចែង និងបញ្ជាក់យ៉ាងច្បាស់អំពីអំណាចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច និងលើកថ្វាយព្រះមហាក្សត្រ ក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់។

ដូច្នេះ បានន័យថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេច និងលើកថ្វាយព្រះមហាក្សត្រក្នុងការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់ ដោយមិនចាំបាច់ឆ្លងកាត់តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឡើយ។

### ៣.២.រចនាសម្ព័ន្ធ

សាលាដំបូង ជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ សាលាដំបូង ត្រូវបែងចែកជាតុលាការជំនាញ។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក។[៥០]

ប្រធានសាលាដំបូង មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក។[៥១]

សមាសភាពសាលាដំបូងរួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង។[៥២]

[៥០] មាត្រា ១២ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥១] មាត្រា ៥ កថាខណ្ឌ ២ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

**សាលាដំបូងនីមួយៗ បែងចែកជាតុលាការជំនាញ ដូចខាងក្រោម៖**

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ។

តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង ចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ។[៥៣]

សមាសភាពរបស់តុលាការជំនាញនីមួយៗរួមមាន៖

- ប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី។[៥៤]

## ៣.៣.ការគ្រប់គ្រងរដ្ឋបាល

នៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មានអង្គភាពរដ្ឋបាលមួយ ដែលស្ថិតនៅក្រោមរដ្ឋបាលកណ្តាលក្រសួងយុត្តិធម៌សម្រាប់គាំទ្រដល់កិច្ចការដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។ នៅថ្នាក់សាលាដំបូង អង្គភាពរដ្ឋបាលនេះ ហៅថា លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានថ្នាក់ស្មើនឹងនាយកដ្ឋាន។[៥៥]

ក្រសួងយុត្តិធម៌ ត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ។ ក្រសួងយុត្តិធម៌ អាចចេញលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានា ដើម្បីធានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចាត់ឲ្យធ្វើអធិការ

---

[៥២] មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥៣] មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥៤] មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥៥] មាត្រា ១០ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

កិច្ចលើបញ្ហាណាមួយជាកំណត់ រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យ និងសម្រេច។

សាលាជម្រះក្តីជាន់ខ្ពស់ មានសមត្ថកិច្ចត្រួតពិនិត្យលើកិច្ចការជម្រះក្តីរបស់សាលាជម្រះក្តីជាន់ទាប។ ការត្រួតពិនិត្យនេះ ប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃនីតិវិធីឧបាស្រ័យ ដោយអនុលោមតាមបទបញ្ញត្តិស្តីពីនីតិវិធីជាធរមាន។[៥៦]

### ៣.៤.ហិរញ្ញវត្ថុ

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។ ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាអាណាប័កទទួលសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ។[៥៧]

### ៣.៥.ចៅក្រមស៊ើបសួរ

#### ៣.៥.១.សមត្ថកិច្ច

ចៅក្រមដែលមានសមត្ថកិច្ច គឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសគ្នា ហើយទទួលពាក្យបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូល ហើយការសម្រេចនេះបិទផ្លូវតវ៉ា។[៥៨]

---

[៥៦] មាត្រា ១១ កថាខណ្ឌ ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥៧] មាត្រា ៧៩ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៥៨] មាត្រា ១២៣ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ៣.៥.២.តួនាទី

#### ៣.៥.២.១.ទទួលពាក្យបណ្ដឹង

ចៅក្រមស៊ើបសួរ ទទួលពាក្យបណ្ដឹងអំពីអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

#### ៣.៥.២.២.បើកការស៊ើបសួរ

ចៅក្រមស៊ើបសួរ ត្រូវស៊ើបសួរតែអង្គហេតុនោះប៉ុណ្ណោះ។ ប្រសិនបើលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរ បើកការស៊ើបសួរអំពីអង្គហេតុថ្មីនេះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរ គ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរ មិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទៅលើអង្គហេតុ ដែលនៅចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។[៥៩]

ចៅក្រមស៊ើបសួរ អាចសុំឲ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះ តាមដីកាចាត់ឲ្យស៊ើបសួរជំនួស។[៦០]

ចៅក្រមស៊ើបសួរ អាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន នៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។

ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ។ ក្នុងករណីនេះ ព្រះរាជអាជ្ញា អាចចូលរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ។

ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូល។ ប៉ុន្តែ ចៅក្រម ត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ។ ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្ដីពី ប្រតិបត្តិការរបស់ខ្លួននេះ។[៦១]

---

[៥៩] មាត្រា ១៣១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៦០] មាត្រា ១២៥ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៦១] មាត្រា ១៣០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

### ៣.៥.៣.ដីកាដំណោះស្រាយ

សេចក្ដីសម្រេចរបស់ចៅក្រម គឺគេចង់សំដៅទៅលើសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលត្រូវបានគេឲ្យឈ្មោះថា **ដីកាសម្រេច**។ ដីកាសម្រេច គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន។[៦២]

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។

#### ៣.៥.៣.១.លើកលែងពីបទចោទ

ចៅក្រមស៊ើបសួរ ចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

ក្នុងករណីនេះ ចៅក្រមស៊ើបសួរ មិនអាចដោះលែងជនត្រូវចោទភ្លាមបានទេ លុះត្រាតែផុតរយៈពេលប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ដែលមានរយៈពេល ១ខែ គិតពីពេលប្រកាសដីកា សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង ៥ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងពីដីកាសម្រាប់អគ្គព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងជនដែលសុំឲ្យប្រគល់វត្ថុចាប់យកឲ្យខ្លួនវិញ។[៦៣]

#### ៣.៥.៣.២.បញ្ជូនទៅជំនុំជម្រះ

ប្រសិនបើយល់ឃើញថា អំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ការបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះនេះត្រូវធ្វើឡើងតាមរយៈ **ដីកាបញ្ជូនទៅជំនុំជម្រះ** ដោយដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។

ដីកានេះ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។[៦៤]

---

[៦២] ជួន សុភាសី, "នីតិវិធីសង្ខេប រដ្ឋប្បវេណី និង ព្រហ្មទណ្ឌ", ភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ទំព័រទី ៥៥

[៦៣] មាត្រា ២៧០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៦៤] មាត្រា ២៤៧ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

## ៣.៦.ចៅក្រមជំនុំជម្រះ

### ៣.៦.១.សមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ចខាងដែនដី គឺ៖

- តុលាការនាទីកន្លែងបទល្មើស
- តុលាការនាលំនៅឋានរបស់ជនជាប់ចោទ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ។

ក្នុងករណីដែលមានតុលាការ ពីរ ឬច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយ បានទទួលពាក្យបណ្តឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង។

វិវាទដែនដីរវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់ ដោយការសម្រេចនេះបិទផ្លូវតវ៉ា។[៦៥]

### ៣.៦.២.តួនាទី

#### ៣.៦.២.១.ទទួលពាក្យបណ្តឹង

យោងតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ចែងថា ក្នុងរឿងព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្តឹងដោយ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា។

នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ ប្រធានតុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃសវនាការ។

#### ៣.៦.២.២.សវនាការ

សាលាដំបូងជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និង បទលហុ ដែលជាប់ទាក់ទង។ សាលាដំបូងក៏អាចសម្រេចជាចៅក្រមទោលបានដែរ ចំពោះបទមជ្ឈិម និងបទលហុ។[៦៦]

---

[៦៥] មាត្រា ២៩០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៦៦] មាត្រា ២៨៩ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

មានតែសាលាជម្រះក្តីប៉ុណ្ណោះ ទើបមានអំណាចកាត់សេចក្តី និងប្រកាសសេចក្តីសម្រេចរបស់តុលាការបាន។[៦៧] ចៅក្រម គឺជាបុគ្គលតែមួយគត់ដែលមានសិទ្ធិអំណាចក្នុងការជម្រះក្តីផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋក៏ដូចជាសង្គមជាតិ។ រាល់ការជម្រះក្តីទាំងអស់របស់ចៅក្រម ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ដោយត្រូវគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឲ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន។

ការពិភាក្សាដេញដោយប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថា ភាពជាសាធារណៈនាំឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ តុលាការអាចបង្គាប់ឲ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់ទាំងស្រុង ឬមួយផ្នែកបានតាមសេចក្តីសម្រេចដោយសំអាងហេតុ។[៦៨]

### ៣.៦.៣.សេចក្តីសម្រេចរបស់តុលាការ

តុលាការជំនាញនីមួយៗរបស់សាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ។[៦៩]

សេចក្តីសម្រេចរបស់តុលាការជាន់ទាបត្រូវបានគេឲ្យឈ្មោះថា **ជាសាលក្រម** ។ សាលក្រមគឺជាការសម្រេចសេចក្តី ដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ហើយកើតមានអានុភាពដោយសារការប្រកាសដោយផ្អែកលើលិខិតសាលក្រមនេះ។

គ្រប់សាលក្រម ត្រូវតែប្រកាសនៅពេលសវនការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេច ត្រូវអានដោយសម្លេងខ្លាំងៗ ដោយប្រធានសវនាការ។[៧០]

ចំពោះការប្រកាសអំពីពិរុទ្ធភាព តុលាការត្រូវពិនិត្យមើលៈ

- តើអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួន ឬទេ?

---

[៦៧] មាត្រា ៦ កថាខណ្ឌ ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៦៨] មាត្រា ៣៩២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៦៩] មាត្រា ១៤ កថាខណ្ឌ ៣ នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

[៧០] មាត្រា៣៥០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ប្រសិនបើពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ។ ដោយឡែក ប្រសិនបើតុលាការយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។[៧១]

សាលក្រមអាចត្រូវបានបែងចែកជា ៣ ប្រភេទ៖

- **សាលក្រមចំពោះមុខ៖** ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការនោះ សាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ។ ប្រសិនបើជនជាប់ចោទ មិនអាចចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដោយមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរ ហើយតុលាការបានធ្វើការសួរចម្លើយជនជាប់ចោទនៅទីកន្លែងដែលជននោះនៅ សាលក្រមក៏ជាសាលក្រមចំពោះមុខជនជាប់ចោទដែរ។ សាលក្រមចំពោះមុខជនជាប់ចោទ មិនត្រូវឲ្យដំណឹងដល់ជននេះទេ។ ក្នុងករណីដែលសាលក្រមប្រកាសដោយមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះជាសាលក្រមចំពោះមុខ។[៧២]
- **សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ៖** ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថា ជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។[៧៣]
- **សាលក្រមកំបាំងមុខ៖** ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថា សាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ។ ក្នុងករណីដែលសាលក្រមប្រកាសដោយពុំមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះជាសាលក្រមកំបាំងមុខ។[៧៤]

---

[៧១] មាត្រា៣៥៩ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧២] មាត្រា៣៦០ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧៣] មាត្រា៣៦១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧៤] មាត្រា៣៦២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

**៣.៦.៣.១.បណ្ដឹងអំពីសាលក្រម**

សាលាក្រមព្រហ្មទណ្ឌ អាចត្រូវប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ដោយភាគីបាន។

**៣.៦.៣.១.១.បណ្ដឹងទាស់**

ក្រោយពីសាលក្រម ត្រូវបានប្រកាស ភាគីនៅក្នុងរឿងព្រហ្មទណ្ឌអាចប្ដឹងទាស់បានក្នុងករណីដែលសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខខ្លួន។

ជនដែលអាចប្ដឹងទាស់បាន គឺពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ បណ្ដឹងទាស់ត្រូវធ្វើដោយពាក្យប្ដឹងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ក្នុងករណីប្ដឹងទាស់ដោយពិរុទ្ធជន ព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលបានទទួលពាក្យបណ្ដឹងទាស់របស់ពិរុទ្ធជន បញ្ជូនបណ្ដឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។[៧៥]

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃ ផ្ដើមគិតពីថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខកាលណាសាលក្រម បានប្រគល់ឲ្យសាមីខ្លួនដោយផ្ទាល់ដៃ ឬថ្ងៃដែលសាមីខ្លួនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់សាមីខ្លួនដោយផ្ទាល់ដៃទេ។[៧៦]

**៣.៦.៣.១.២.បណ្ដឹងឧទ្ធរណ៍**

ជនដែលអាចប្ដឹងឧទ្ធរណ៍បាន គឺព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។

ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ គិតពីពេលប្រកាសសាលក្រម។[៧៧] ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ គិតចាប់ពីពេលប្រកាសសាលក្រម បើសាលក្រមនោះជាសាលក្រមចំពោះមុខ ឬគិតពីពេលទទួលដំណឹងសាលក្រម(ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ) បើសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ។[៧៨]

---

[៧៥] មាត្រា ៣៦៦ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧៦] មាត្រា ៣៦៨ និង៣៧២ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧៧] មាត្រា ៣៨១ នៃព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

[៧៨] ចាំង ស៊ីណាត, សិក្ខាសាលាស្តីពី "ក្រមនីតិវិធីព្រហ្មទណ្ឌ", រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០

#### ៣.៦.៣.២.អានុភាពនៃសាលក្រមចូលជាស្ថាពរ

នៅពេលដែលផុតរយៈពេលប្តឹងឧប្រាស្រ័យដែលបានកំណត់ដោយច្បាប់ នោះសាលក្រមនឹងចូលជាស្ថាពរ ហើយមានអានុភាពដូចខាងក្រោម៖

- **ការបិទផ្លូវតវ៉ា** ៖ ក្រោយពេលចូលជាសាលក្រមស្ថាពរ ភាគីនៃរឿងក្តីនោះមិនអាចធ្វើការប្តឹងឧបាស្រ័យនឹងសាលក្រមនោះជាថ្មីម្តងទៀតឡើយ លើកលែងបណ្តឹងសើរើក្នុងករណីពិសេសណាមួយ។
- **អានុភាពអនុវត្ត** ៖ សាលក្រមដែលបានចូលស្ថាពររួចហើយ មានន័យថា សាលក្រមនោះមានអនុភាពអនុវត្ត ដោយព្រះរាជអាជ្ញា ត្រូវចាប់ផ្តើមអនុវត្តទៅតាមអំណាចនៃសាលក្រមនោះជាដាច់ខាត។
- **អាជ្ញាអស់ជំនុំ** ៖ នៅពេលសាលក្រមចូលជាស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើតឡើង។

## ៣.៧.ឯករាជ្យភាពរបស់តុលាការ

ឯករាជ្យភាពនៃអង្គចៅក្រម គឺជាគោលការណ៍គន្លឹះមួយយ៉ាងសំខាន់ បើគ្មានឯករាជ្យភាព ក៏គ្មានភាពមិនលម្អៀង គ្មានភាពសុចរិត គ្មានភាពថ្លៃថ្នូរ ហើយក៏គ្មានវិរៈភាពចំពោះការងារដែរ។

ឯករាជ្យភាពនៃអង្គចៅក្រម មានលក្ខណៈចាំបាច់ណាស់ក្នុងការផ្តល់យុត្តិធម៌មួយប្រកបដោយអនាគតិ។ ចៅក្រមត្រូវតែធ្វើឲ្យគេគោរពឯករាជ្យភាពនៃអង្គចៅក្រម និងសម្តែងនូវឯករាជ្យនេះក្នុងនាមជាបុគ្គល និងស្ថាប័ន។[៧៩]

បើនិយាយអំពីឯករាជ្យភាពនៃតុលាការ នោះយើងត្រូវពិនិត្យមើលកត្តា ២យ៉ាងសំខាន់ គឺ **ឯករាជ្យភាពនៃស្ថាប័ន** និង **ឯករាជ្យភាពនៃបុគ្គលចៅក្រម**។

### ៣.៧.១.ឯករាជ្យស្ថាប័ន

នៅក្នុងសង្គមនីមួយៗតុលាការ គឺជាស្ថាប័នដែលមានតម្លៃខ្ពស់បំផុត។[៨០] ឯករាជ្យតុលាការនេះមានសារៈសំខាន់ចាំបាច់ក្នុងការធានាសវនាការជាសាធារណៈ មានយុត្តិធម៌ មានសមត្ថភាព មានឯករាជ្យ និងភាពមិនលម្អៀងដែលចែងក្នុងអត្ថបទច្បាប់។

ឯករាជ្យស្ថាប័ន សំដៅទៅលើអធិបតេយ្យភាពរបស់តុលាការទាំងមូល ផ្ទុយនឹងការរំលោភបំពានមកលើតួនាទី ឯកទេសរបស់តុលាការពីសំណាក់អង្គការនីតិបញ្ញត្តិ និងអង្គការនីតិប្រតិបត្តិ។

[៧៩] ឱត មុន្នី, សន្ទរកថាក្នុងឱកាសបើកសិក្ខាសាលាស្តីពី "ក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា", ភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ទំព័រទី ៣

[៨០] សេចក្តីប្រកាសនៅប៉េកាំងស្តីពី, "គោលការណ៍ឯករាជ្យភាពរបស់តុលាការនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីភិច", បេកាំង, ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៥ ទំព័រទី ៦ ចំណុចទី១

ទាក់ទងទៅនឹងការរំលោភបំពាននេះដែរ ចៅក្រមខ្លួនឯងត្រូវតែប្រុងប្រយ័ត្នទៅនឹងការប៉ុនប៉ងបំផ្លាញឯករាជ្យស្ថាប័ន ក្នុងន័យនេះ ចៅក្រមត្រូវច្រានចោលនូវការប៉ុនប៉ងមិនប្រក្រតីទាំងឡាយណា ដែលធ្វើឲ្យមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្ដីរបស់ខ្លួនតាមគ្រប់រូបភាព។[៨១]

ចៅក្រម ត្រូវច្រានចោលនូវការប៉ុនប៉ងដែលបានដាក់ជូន ឬស្នើសុំអ្វីដែលមិនមែនជាសេចក្ដីបញ្ជាក់ដំបូង ឬភស្តុតាងក្នុងអំឡុងពេលដំណើរការនីតិវិធីភាគី ឬតំណាងភាគី។ ប្រសិនបើចៅក្រមមិនអាចច្រានចោលនូវការប៉ុនប៉ងដាក់ជូនឬស្នើសុំនោះទេ ចៅក្រមត្រូវស្នើសុំយោបល់ពីប្រធានអង្គភាពដើម្បីចាត់វិធានការណ៍តាមច្បាប់។[៨២]

ជាទូទៅ មានតែស្ថាប័នតុលាការជាន់ខ្ពស់ទេ ទើបមានសិទ្ធិត្រួតពិនិត្យសេចក្ដីសម្រេចរបស់តុលាការនៃសាលាដំបូង។

តាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នសម្រាប់ធានានូវដំណើរការ និងការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការឲ្យបានល្អប្រសើរ ដូច្នេះដើម្បីឲ្យស្ថាប័ននេះមានភាពកាន់តែរឹងមាំចាំបាច់ត្រូវមានកញ្ចប់ថវិកាស្វយ័តរបស់ខ្លួន រួមទាំងសម្ភារៈបរិក្ខាគ្រប់គ្រាន់។ រីឯស្ថាប័នតុលាការវិញ គប្បីមានថវិកាស្វយ័តរបស់ខ្លួន និង សម្ភារៈគ្រប់គ្រាន់ដែរដោយមិនគួរគប្បីឲ្យថវិកានេះស្ថិតនៅក្នុងកញ្ចប់ថវិកានៃក្រសួងយុត្តិធម៌ឡើយ។

លើសពីនេះទៀត ដើម្បីធានាប្រសិទ្ធភាពការងារចៅក្រមត្រូវមានសិទ្ធិអំណាចក្នុងការដាក់វិន័យលើមន្ត្រីក្រោមឳវាទរបស់ខ្លួន។[៨៣]

**៣.៧.២.ឯករាជ្យបុគ្គល**

ឯករាជ្យបុគ្គលនៃអង្គចៅក្រម គឺស្ដែងឡើងតាមរយៈឯករាជ្យរបបភស្តុភារ រួមមាន ប្រាក់បៀវត្សការតែងតាំង ការតម្លើងថ្នាក់ ការតម្លើងឋានន្តរសក្ដិ ប្រាក់សោធន៍និវត្តន៍ សកម្មភាពផ្ទេរការងារពីកន្លែងមួយទៅកន្លែងផ្សេងទៀត និងវិន័យការងារ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការខ្លួនឯងផ្ទាល់។ ជាពិសេស ឯករាជ្យបុគ្គលនៃអង្គចៅក្រមនេះក៏ស្ដែងឡើងតាមរយៈកេតនភណ្ឌ(តម្លៃជាកិត្តិយស) របស់គាត់ដូចជា ភាពមិនអាចដកចេញពីមុខតំណែងបានផងដែរ។

ក្នុងដំណើរការនៃការសម្រេចចិត្ត ការរៀបចំឋានានុក្រមរបស់តុលាការ ភាពខុសគ្នាអំពីឋានៈ ឬ លំដាប់ថ្នាក់មិនត្រូវជ្រៀតជ្រែកទៅក្នុងករណីយកិច្ចរបស់ចៅក្រមក្នុងការអនុវត្តន៍យុត្តាធិការរៀងៗខ្លួន មានន័យថា ចៅក្រមគ្មានបុរេវិនិច្ឆ័យមិនទទួលរងឥទ្ធិពលពីប្រធានចៅក្រម ឬចៅក្រមដែលធ្វើ

---

[៨១] ប្រការ ២ នៃក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

[៨២] ប្រការ ៣ នៃក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

[៨៣] ឌិត មុន្ទី, សន្ទរកថាក្នុងឱកាសបើកសិក្ខាសាលាស្ដីពី "ក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា", ភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥

ការជាមួយគ្នាឡើយ។ ចៅក្រមក៏មានកាតព្វកិច្ចអនុវត្តច្បាប់ដូចដែលគាត់បានយល់ គ្មានការភ័យខ្លាច ការយោគយល់ ឯករាជ្យក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន ដោយមិនទទួលរងឥទ្ធិពលផ្សេងៗ ដូចជា ការអូសទាញ ការគាបសង្កត់ ការគំរាមកំហែង ការជ្រៀតជ្រែកពីសំណាក់ជនណាម្នាក់ ឬច្រើននាក់ និងហេតុផលអ្វីមួយ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។

ចៅក្រម ជានិច្ចកាលត្រូវយកចិត្តទុកដាក់គោរពក្រមសីលធម៌វិជ្ជាជីវៈទោះជានៅក្នុងម៉ោងធ្វើការ ឬក្នុងជីវិតឯកជនក៏ដោយ ត្រូវធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់ឯករាជ្យភាពស្ថាប័នតុលាការ ឯករាជ្យបុគ្គល និងជៀសវាងពីសាធារណជនមើលឃើញថា ខ្លួនមិនឯករាជ្យ។

## ៣.៨.គោលការណ៍ឯករាជ្យភាព

ចៅក្រម ត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យឈរលើមូលដ្ឋាននៃការវាយតម្លៃលើអង្គហេតុ និងផ្អែកលើចំណេះដឹងផ្នែកច្បាប់ ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗដូចជា ការអូសទាញ ការគៀបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកពីសំណាក់ជនណាម្នាក់ ឬច្រើននាក់ ឬហេតុផលអ្វីមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដើម្បីបង្ហាញឲ្យគេមើលឃើញថា ជាបុគ្គលមានអត្តចរិតយុត្តិធម៌ និងមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ក្នុងការវិនិច្ឆ័យសេចក្តី។ ចៅក្រម ត្រូវប្រានចោលនូវការប៉ុនប៉ងទាំងឡាយណាដែលធ្វើឲ្យមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន។

### ៣.៨.១.ការប៉ុនប៉ង ដើម្បីធ្វើឲ្យមានឥទ្ធិពលដល់ចៅក្រម

ចៅក្រម ត្រូវប្រានចោលនូវការប៉ុនប៉ងជូន ឬស្នើសុំអ្វីដែលមិនមែនជាសេចក្តីបញ្ជាក់ដំបូង ឬភស្តុតាងក្នុងអំឡុងពេលដំណើរការនីតិវិធីពីភាគី ឬអ្នកតំណាងរបស់ភាគី។ ប្រសិនបើចៅក្រមនោះមិនអាចប្រានចោលនូវការប៉ុនប៉ងដាក់ជូន ឬស្នើសុំនោះទេ ចៅក្រមនោះត្រូវស្នើសុំយោបល់ពីប្រធានអង្គភាពរៀងៗខ្លួន ដើម្បីចាត់វិធានការណ៍តាមច្បាប់។

ដូច្នេះ ចៅក្រម ត្រូវសម្រេចសេចក្តីដោយមិនលម្អៀង ផ្អែកលើអង្គហេតុ និងអង្គច្បាប់ ដោយមិនមានការរិតត្បិត ទទួលរងឥទ្ធិពលដែលមិនត្រឹមត្រូវ ការទាក់ទាញ ការគាបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយដោយសារមូលហេតុណាមួយឡើយ។

### ៣.៨.២.សកម្មភាពនយោបាយ

មន្ត្រីតុលាការ មានសិទ្ធិចូលរួមជាសមាជិកគណបក្សនយោបាយបានគ្រាន់តែមិនធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ ចៅក្រម ត្រូវស្ថិតនៅជាអព្យាក្រិតភាពក្នុងសកម្មភាពនយោបាយ។[៨៤]

[៨៤] មាត្រា ៥០ កថាខណ្ឌ ៣ នៃសេចក្តីព្រាងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

ការចូលរួមក្នុងក្រុម ឬការចាត់តាំង ឬការចូលរួមក្នុងការពិភាក្សាជាសាធារណៈ ប្រសិនបើសកម្មភាពនោះត្រូវមានមនុស្សម្នាក់ដែលមានការពិចារណាត្រឹមត្រូវប្រកបដោយអនាគតិ និងមានចំណេះដឹងជ្រៅជ្រះយល់ឃើញថា មានការប៉ះពាល់ទៅដល់និមិត្តរូបនៃភាពអនាគតិនៃអង្គចៅក្រម ចៅក្រមគួរជៀសវាងដោយសារថា វាអាចជាកម្មវត្ថុនៃបណ្តឹងទៅតុលាការ។

ជាការប្រពៃបំផុតចាប់តាំងពីថ្ងៃដែលបានទទួលងារជាចៅក្រម ចៅក្រម គួរបញ្ឈប់ទាំងស្រុងនូវគ្រប់សកម្មភាពនយោបាយ ទំនាក់ទំនងនយោបាយ និង ការប្រើប្រាស់មុខងារយុត្តាធិការដើម្បីឈ្នានីនយោបាយ។

## ៣.៩.គោលការណ៍អនាគតិ(ភាពមិនលម្អៀង)

ចៅក្រមត្រូវមានអាកប្បកិរិយា ទាំងក្នុង និងក្រៅតុលាការនូវលក្ខណៈអនាគតិរបស់ខ្លួន ដើម្បីការពារថែរក្សា និង លើកកម្ពស់ជំនឿទុកចិត្តពីសំណាក់សាធារណៈជន អ្នកមានវិជ្ជាជីវៈច្បាប់ និងភាគីវិវាទ។ ចៅក្រមមិនត្រូវចូលរួមពិភាក្សាជាសាធារណៈពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗនៅតុលាការឡើយ ព្រោះវាអាចនាំឲ្យប៉ះពាល់ដល់ជំនឿទុកចិត្តអំពីអនាគិរបស់ខ្លួន។ នៅក្នុងការសម្រេចសេចក្តី ចៅក្រមមិនត្រូវធ្វើបុរេវិនិច្ឆ័យទាក់ទងទៅនឹង ជាតិសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា និន្នាការនយោបាយ ពិការភាព អាយុ ស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និងសង្គមឡើយ។ ម្ចាស់បណ្តឹងអាជ្ញា ត្រូវស្វែងរកភស្តុតាងដាក់បន្ទុក ដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែ មិនត្រូវមានភាពលម្អៀងក្នុងការចោទប្រកាន់ ឬមិនចោទប្រកាន់ឡើយ គឺត្រូវធានានូវភាពត្រឹមត្រូវ និងប្រសិទ្ធភាពក្នុងការធ្វើបណ្តឹងអាជ្ញា។[៩៥]

អនាគតិ មកពីពាក្យ **"អ+អគតិ"** មានន័យថា សេចក្តីមិនលម្អៀង។ អនាគតិ គឺជាគុណភាពមូលដ្ឋានគ្រឹះរបស់ចៅក្រម និងជាកេតនភណ្ឌស្នូលនៃមុខងារតុលាការ វាក៏សំដៅផងដែរ ដល់ស្ថានភាពស្មារតី ឬឥរិយាបថរបស់តុលាការចំពោះវិវាទទាំងមូល និងចំពោះភាគីនានានៅក្នុងរឿងក្តីជាកំណត់ណាមួយ។ ដោយអនុលោមទៅតាមក្រមសីលធម៌ចៅក្រម នៅពេលបំពេញកិច្ចការតុលាការ ឬអយ្យការ ចៅក្រមត្រូវមាន៖

- **វីរិយសម្បយុត្ត** = ការបំពេញកិច្ចការប្រកបដោយវីរិយភាព ការបំពេញការងារដោយរហ័សរហួន ភាពសុចរិត និង គុណភាព ឬការបំពេញកិច្ចការប្រកបដោយវីរភាព
- **សុចរិតយុត្តិធម៌** = ភាពទៀងត្រង់ និង យុត្តិធម៌

[៩៥] ប្រការ ៧ នៃក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

- **បញ្ញត្តិគារវោ** = ការប្រតិបត្តិច្បាប់ឲ្យបានម៉ឺងម៉ាត់ ឬការគោរពតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់
- **សមទណ្ឌោ** = សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា
- **បញ្ញាវុធវិនិច្ឆ័យ** = ការសម្រេចសេចក្តីដែលប្រកបដោយបញ្ញា និង ភាពឆ្លាតវៃ។

**ព្រះសម្មាសម្ពុទ្ធ ទ្រង់បានផ្តល់នូវពុទ្ធោវាទមួយចំនួនដល់ចៅក្រមសម្រាប់ការវិនិច្ឆ័យសេចក្តីៈ**

- ចៅក្រមណាក៏ដោយ ត្រូវប្រកាន់យកអនាគតិធម៌ និងជៀសវាងអគតិធម៌
- ចៅក្រមត្រូវជៀសវាងការកាត់ក្តីប្រកបដោយអគតិធម៌ទាំង ៤ យ៉ាង
- ចៅក្រមត្រូវកុំគិតពីអំពើពុករលួយ
- ចៅក្រមមិនត្រូវទទួលសំណូកទេ
- ចៅក្រមមិនត្រូវធ្វើការបែងចែករវាងញាតិសន្តាន និងបុគ្គលដទៃទៀតទេ។
- ចៅក្រមត្រូវត្រងត្រាប់ស្តាប់រាល់ចំណុចទាំងអស់ ទាំងតូច ទាំងធំ ឲ្យបានល្អិតល្អន់ ហើយពិនិត្យមើលទាំងចំណុចដែលខុស និងចំណុចដែលត្រូវដោយការពិចារណាឲ្យបានហ្មត់ចត់។[៨៦]

កត្តាសំខាន់ ដែលធ្វើឲ្យចៅក្រមបាត់បង់សេចក្តីទៀងត្រង់រហូតដល់ក្លាយជាសេចក្តីទៀងទេរ គឺ **អគតិធម៌** ព្រោះអគតិធម៌ធ្វើឲ្យសភាពចិត្តរបស់ចៅក្រមមិនទៀងត្រង់ គឺល្អៀងទៀងទេរឃ្លាតចាកសុចរិតធម៌។ នៅក្នុងព្រះពុទ្ធសាសនាចង្អុលប្រាប់មូលហេតុនៃអគតិធម៌ គឺសេចក្តីទៀងទេរនេះ ដោយចែកជា ៤ ប្រភេទ គឺ

១. **ឆន្ទាគតិ**(Prejudice caused by love or desire; partiality) សេចក្តីលម្អៀងទៀងទេរ ព្រោះ សេចក្តីស្រឡាញ់ អាណិត ឬចូលចិត្ត ពោលគឺធ្វើឲ្យបាត់បង់យុត្តិធម៌ព្រោះអាល័យតែយកសេចក្តីស្រឡាញ់ អាណិត ឬចូលចិត្តដែលកើតឡើងចំពោះខ្លួនឯងផ្ទាល់ ញាតិសន្តាន ឬមនុស្សជិតស្និទ្ធជាត្រីវិស័យ ត្រូវនឹងសុភាសិតខ្មែរថា **ស្រឡាញ់ញាតិឃ្លាតច្បាប់** គឺព្រោះតែស្រឡាញ់សាច់ញាតិរបស់ខ្លួនទើបហ៊ាន ប្រព្រឹត្តល្មើសច្បាប់ដែលជាបទដ្ឋានរបស់សង្គម បើប្រព្រឹត្តល្មើសជារឿយៗរហូតដល់ជាប់ជានិស្ស័យ ក៏កើតមាន

---

[៨៦] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, សៀវភៅសិក្សាផ្នែកទី៣, ការពិចារណាពិស្តារផ្នែកគតិយុត្ត, "ប្រព័ន្ធតុលាការ", ភ្នំពេញ, ខែកក្កដា ឆ្នាំ២០០៤, ទំព័រទី២៨

នូវអំពើអយុត្តិធម៌នៅក្នុងសង្គមកាន់តែច្រើនឡើង ហើយធ្វើឲ្យស្ថាប័នតុលាការទាំងមូលអស់តម្លៃ និងធ្វើឲ្យប្រជាពលរដ្ឋបាត់ទំនុកចិត្តទៅលើប្រព័ន្ធតុលាការ។ សេចក្តីលម្អៀងទៀងទេរព្រោះសេចក្តីស្រឡាញ់ អាណិតចូលចិត្តនេះធ្វើឲ្យបាត់បង់ អព្យាក្រឹតភាព មិនអាចតម្កល់ខ្លួននិងបដិបត្តិដោយស្មោះស្មើគ្នាចំពោះមនុស្សទាំងពួងបានទេ។

២. **ទោសាគតិ**(Prejudice caused by hatred or enmity) សេចក្តីលម្អៀងទៀងទេរព្រោះសេចក្តីមិនស្រឡាញ់ មិនអាណិត ឬមិនចូលចិត្ត គឺស្អប់ ខឹង ក្រេវក្រោធ ឬទើសទាស់ចិត្ត ពោលគឺ ធ្វើឲ្យបាត់បង់យុត្តិធម៌ព្រោះសម្អប់ កំហឹង សេចក្តីក្រេវក្រោធ ឬទំនើសទើសទាស់ចិត្ត គឺលុះក្នុងអំណាចទោសៈ មានសភាពចិត្តទន់ខ្សោយមិនរឹងមាំ មិនយោគយល់អ្នកដទៃ មិនអាចញែករឿងផ្ទាល់ខ្លួនឲ្យចេញពីរឿងសាធារណៈបាន ដោយយកកំហឹងទល់នឹងកំហាល់ ឬយកកំហឹង យកទោសៈ ដើម្បីដោះស្រាយបញ្ហា។

៣. **មោហាគតិ**(Prejudice caused by delusion or stupidity) សេចក្តីលម្អៀងទៀងទេរព្រោះសេចក្តីវង្វេង កម្លៅ ល្ងង់ខ្លៅ ឬ យល់មិនដល់សភាពការណ៍ពិត ពោលគឺធ្វើឲ្យបាត់បង់យុត្តិធម៌ព្រោះសេចក្តីធ្វេសប្រហែលខ្ជីខ្ជា ដែលភាសាដោះសាថា ព្រោះខុសបច្ចេកទេសប្រញាប់វិនិច្ឆ័យដោយខ្វះការពិចារណាយ៉ាងល្អិតល្អន់ មិនបើកចិត្តឲ្យទូលាយសម្លឹងមើលអ្នកដទៃក្នុងផ្លូវទុទិដ្ឋិនិយម ឬថាមិនទទួលយកមតិយោបល់យល់ឃើញរបស់អ្នកដទៃ។ ចៅក្រមត្រូវមានចំណេះដឹងវិជ្ជាជីវៈគ្រប់គ្រាន់នៅពេលបំពេញការងារ កាលណាចៅក្រមខ្វះចំណេះវិជ្ជា នោះនាំឲ្យការគិតត្រិះរិះពិចារណានាំឲ្យមានភាពល្អៀងដោយសារភាពល្ងិតល្ងង់របស់ខ្លួន កើតមាននូវអំពើអយុត្តិធម៌ក្នុងសង្គម។

៤. **ភយាគតិ** (Prejudice caused by fear ) សេចក្តីលម្អៀងទៀងទេរព្រោះសេចក្តីភ័យខ្លាចញញើត បាក់ស្បាត ឬក្រែងចិត្ត ពោលគឺ ធ្វើឲ្យបាត់បង់យុត្តិធម៌ព្រោះខ្លាចក្រែងរអែងចិត្ត ឬភ័យខ្លាចចំពោះភយន្តរាយដែលនឹងកើតឡើងដល់ខ្លួនឯង ឬគ្រួសារ ធ្វើឲ្យបាត់បង់វីរភាព គឺសេចក្តីក្លាហាន ជាពិសេស សេចក្តីក្លាហានផ្នែកចរិយាធម៌ គឺ ហ៊ានគិត ហ៊ាននិយាយ និងហ៊ានធ្វើ ។

សេចក្តីលម្អៀងទៀងទេរទាំង ៤ ប្រការនេះជារាំងននដែលបិទបាំងសេរីភាពចិត្តរបស់ចៅក្រមដែលបម្រើតួនាទីជាអ្នកជម្រះក្តីផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋ និងសង្គមជាតិ ឲ្យល្អៀងឃ្លៀងឃ្លាត ឬល្អៀងឃ្លាងចាកយុត្តិធម៌ ពោលគឺ ជារាំងននបិទខ្ទប់សេរីភាពចិត្តឲ្យស្ថិតក្នុងគុកងងឹត គឺអយុត្តិធម៌។

កាលបើអគតិធម៌ទាំង ៤ នេះរីករាលដាលពាសពេញសង្គមហើយ ធ្វើឲ្យមនុស្សកើតទំនាស់ទាស់ទែងផ្សេងៗក្លាយជាបញ្ហាសង្គមកកកុះច្រើនឡើង មិនមានយន្តការដោះស្រាយទំនាស់ដែលត្រឹមត្រូវទេ ទីបំផុត ច្រកចេញនៃទំនាស់ គឺហិង្សា ព្រោះរាល់ទំនាស់មិនត្រូវបានដោះស្រាយដោយយុត្តិធម៌។ ទំនាក់ទំនង (Relationship) រវាងមនុស្សក្នុងសង្គមទើបមិនរលូន មិនទុកចិត្តគ្នា មិនស្មោះត្រង់ចំពោះគ្នា ព្រោះហេតុនោះយុត្តិធម៌ប្រៀបដូចជាច្រវ៉ាក់ដែលទាក់ទាញទំនាក់ទំនងទំនុកចិត្ត និង សេចក្ដីស្មោះត្រង់រវាងសមាជិកក្នុងសង្គមឲ្យរស់នៅជាមួយគ្នាបានយ៉ាងសុខដុមរមនាក្នុងលក្ខណៈថា ហ៊ានគិត ហ៊ាននិយាយ ហ៊ានធ្វើ តាមឆន្ទានុសិទ្ធិរបស់ខ្លួនៗដែលត្រូវការ។[៨៧]

### ៣.៩.១.អាកប្បកិរិយា និង ការធ្វើសវនាការ

ភាគីនៅក្នុងវិវាទ ព្រមទាំងអ្នកឯទៀតតែងតែឃ្លាំមើលសកម្មភាពរបស់ចៅក្រម ដើម្បីស្វែងរកសញ្ញានៃភាពអយុត្តិធម៌។

ការប្រព្រឹត្តអំពើណាមួយដែលនាំឲ្យអាប់ឱនកិត្តិយស សេចក្ដីថ្លៃថ្នូរ និងកិត្យានុភាពនៃអង្គចៅក្រមមិនត្រូវឲ្យកើតមានទេ ដូចជា ការស្ដីបន្ទោសមិនសមហេតុផលលើមេធាវី ការកត់សម្គាល់ដែលធ្វើឲ្យទោមនស្សទៅលើភាគី និង សាក្សី អាកប្បកិរិយាហួសប្រមាណ និងការខ្វះអំណត់របស់ចៅក្រម ដែលជាហេតុអាចបំផ្លាញដល់គោលការណ៍អនាគតិ។

ចៅក្រម ត្រូវប្រឹងប្រែងធ្វើឲ្យដំណើរការប្រព្រឹត្តទៅនៃសវនាការមានលក្ខណៈប្រកបដោយរបៀបរៀបរយ មានប្រសិទ្ធភាព ដែលគេមិនអាចរំលោភបំពានបានលើអភិក្រម ជាពិសេសត្រូវតែបង្ហាញអោយឃើញពីភាពម៉ឹងម៉ាត់គ្រប់គ្រាន់សម្រាប់គោលដៅនេះ។ ចៅក្រម ត្រូវតែរក្សាឲ្យបាននូវសមតាប្រកបដោយភាពស្មុគស្មាញ ដែលក្នុងនោះចៅក្រមត្រូវដឹកនាំនីតិវិធីប្រកបដោយប្រសិទ្ធភាពការពិចារណាត្រឹមត្រូវ និងដោយអនាគតិ។

នៅពេលដំណើរការនីតិវិធីក្នុងសវនាការ ចៅក្រម ត្រូវបង្ហាញនូវភាពហ្មត់ចត់ ការគោរពពេលវេលា អត់ធ្មត់ ចេះគួរសម មានសីលធម៌ យុត្តិធម៌នៅពេលបំពេញកិច្ចការសវនាការ មិនអធិប្បាយនូវអ្វីដែលមិនចាំបាច់មិនសមហេតុផលនៅក្នុងតុលាការ រក្សាសុជីវធម៌ជានិច្ច ជៀសវាងនូវការប៉ះទង្គិច ឬការសម្ដែងណាមួយដែលអាចនាំឲ្យមានការយល់ច្រឡំ ឬសង្ស័យអំពីអនាគតិឡើយ។

### ៣.៩.២.ការស៊ើបអង្កេត ឬការស៊ើបសួររឿងក្ដី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្ដី

ផ្អែកតាមគោលការណ៍ចំពោះមុខ ចៅក្រម មិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយនៅពេលដំណើរការនីតិវិធីដោយអវត្តមាននៃភាគីម្ខាងទៀតឡើយ លើកលែងតែច្បាប់អនុញ្ញាត ឬភាគី

---

[៨៧] http://www.khmerbuddhism.ca/profiles/blogs/3-11

ម្ខាងទៀតនោះយល់ព្រម។ ចៅក្រមមិនត្រូវធ្វើការស៊ើបអង្កេត ឬស៊ើបសួរអង្គហេតុនៃរឿងក្តីដោយឯកឯង និង ផ្ទាល់ខ្លួនទាំងក្នុងតុលាការ ទាំងក្រៅតុលាការលើកលែងតែច្បាប់អនុញ្ញាត។

ចំពោះបទល្មើសព្រហ្មទណ្ឌ ចៅក្រមត្រូវស៊ើបអង្កេតរាល់អំពើដែលច្បាប់បញ្ញត្តិថា ជាបទល្មើស ប៉ុន្តែ នៅពេលដែលខ្លួនទទួលបាននូវភស្តុតាងដាក់បន្ទុកលើជនសង្ស័យណាមួយដែលគេបានដឹង ឬមានជំនឿថា ជាភស្តុតាងបានមកពីការប្រើប្រាស់វិធីមិនស្របច្បាប់ ដែលបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់សង្ស័យរូបនោះ ជាពិសេស ទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តកម្មអមនុស្សធម៌ ឬសកម្មភាពរំលោភលើសិទ្ធិមនុស្សផ្សេងៗទៀត នោះត្រូវបដិសេធមិនប្រើភស្តុតាងបែបនោះ ដើម្បីដាក់បន្ទុកលើជនសង្ស័យឡើយ ហើយត្រូវចាត់គ្រប់វិធានការណ៍ចាំបាច់ទាំងអស់ ដើម្បីធានាថា បុគ្គលដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តខាងលើត្រូវបាននាំខ្លួនទៅកាន់តុលាការភ្លាម។

### ៣.៩.៣.ទំនាក់ទំនងវិជ្ជាជីវៈ សង្គម និងគ្រួសារ

នៅពេលបំពេញការងារចៅក្រមអាចជួប និងពិភាក្សាជាមួយអ្នកមានវិជ្ជាជីវៈច្បាប់បាន។ ចៅក្រមក៏អាចចូលរួមផងដែរ ក្នុងសកម្មភាពសង្គមរួមគ្នាជាមួយសមាជិកមកពីផ្នែកដទៃដែលផ្តល់សេវាកម្មច្បាប់។ ចៅក្រម មិនគួរជំនុំជម្រះរឿងក្តីណា ដែលមានមេធាវីមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គលជាមួយខ្លួនឡើយ។

បើយោងតាមមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងបញ្ជាក់យ៉ាងច្បាស់លាស់ អំពីការដកហូតចៅក្រមចេញពីមុខងាររបស់ខ្លួនក្នុងករណីដែលបានកំណត់ដូចខាងក្រោម៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី។
- កាលណាចៅក្រម ជាញាតិលោហិតក្នុងថ្នាក់ទី៦ ឬញាតិពន្ធក្នុងថ្នាក់ទី៣ ឬអតីតញាតិពន្ធក្នុងថ្នាក់ទី៣ របស់ភាគីណាមួយ។
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬធ្វើជាអ្នកជំនាញក្នុងរឿងក្តី។
- កាលណាចៅក្រមជាអ្នកតំណាង ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី។

- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមមជ្ឈត្តករចំពោះរឿងក្ដី ឬបានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់រឿងក្ដី។

រីឯមាត្រា ៧៥ នៃសេចក្ដីព្រាងច្បាប់រៀបចំអង្គការតុលាការ បានចែងថា ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្ដីតែមួយជាមួយនឹងចៅក្រមម្នាក់ ឬច្រើននាក់ ដែលជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី៤ រាប់ទាំងថ្នាក់ទី៤ នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ នេះផង ទោះក្នុងឋានៈជាចៅក្រមជំនុំជម្រះក្ដី ឬជាតំណាងអយ្យការក្ដី...។ ចំពោះមាត្រា ៧៦ នៃសេចក្ដីព្រាងច្បាប់ដដែលនេះ ក៏បានចែងបញ្ជាក់ដែរថា ចៅក្រមទាំងឡាយដែលមានសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី៤ រាប់ទាំងថ្នាក់ទី៤ នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ នេះផង ធ្វើជាមេធាវីឲ្យភាគីម្ខាងនៃរឿងក្ដីណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងក្ដីនោះបានឡើយ។ និងមាត្រា ៧៧ នៃសេចក្ដីព្រាងច្បាប់ដដែល ក៏បានបញ្ជាក់ដែរថា ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្ដីណាមួយ ដែលមានភាគីម្ខាងជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី៦ រាប់ទាំងថ្នាក់ទី៦ នេះផង ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់ទី៣ នេះផង។

រាល់បញ្ញត្តិដែលបានបង្ហាញបញ្ជាក់ខាងលើ សុទ្ធសឹងតែរាល់ការទំនាក់ទំនងវិជ្ជាជីៈរបស់ចៅក្រម នៅក្នុងសង្គម ក៏ដូចជា គ្រួសាររបស់ចៅក្រមផ្ទាល់តែម្ដង។

### ៣.៩.៤. សកម្មភាពពាណិជ្ជកម្ម

ចៅក្រម មិនអាចធ្វើជំនួញដើម្បីទទួលនូវប្រាក់កម្រៃ ឬអត្ថប្រយោជន៍អ្វីឡើយ ពីព្រោះថាសកម្មភាពនោះអាចរំខានដល់ការបំពេញការងារត្រឹមត្រូវ និងមានប្រសិទ្ធភាពរបស់ខ្លួន ឬគេអាចយល់ថា ចៅក្រមប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីរកស៊ី ឬអាចធ្វើឲ្យចៅក្រមមានទំនាក់ទំនងពាណិជ្ជកម្មជាបុគ្គលដែលមានរឿងក្ដីនៅតុលាការ។

### ៣.៩.៥.អត្ថប្រយោជន៍ហិរញ្ញវត្ថុ

ចៅក្រម មិនត្រូវមានអត្ថប្រយោជន៍ហិរញ្ញវត្ថុ អត្ថប្រយោជន៍អ្វីផ្សេង ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ក្នុងរឿងក្ដីដែលខ្លួនបានកាន់ឡើយ។

### ៣.៩.៦.ទំនាស់ផ្នែកផលប្រយោជន៍

ចៅក្រម ត្រូវដកខ្លួនចេញនៅពេលដែលខ្លួនយល់ថា មិនអាចធ្វើការវិនិច្ឆ័យដោយភាពអនាគតិបាន។ ទំនាស់ផលប្រយោជន៍អាចកើតមាននៅពេលដែលផលប្រយោជន៍របស់ចៅក្រមផ្ទាល់

ឬ សាច់ញាតិរបស់ចៅក្រម មានទំនាក់ទំនងជាមួយករណីយកិច្ចរបស់ចៅក្រមក្នុងការផ្តល់យុត្តិធម៌ប្រកបដោយអនាគតិ។

ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍ ចៅក្រម មិនគួរទទួលរឿងក្តីណាដែលពាក់ព័ន្ធជាមួយសមាជិកគ្រួសារ មិត្តភក្តិជិតស្និទ្ធ សមាគមចៅក្រមមានផលប្រយោជន៍ក្នុងរឿងក្តីដែលខ្លួនមានទំនាក់ទំនងជិតស្និទ្ធជាមួយភាគីវិវាទណាមួយ រឿងក្តីដែលចៅក្រមមានទំនាក់ទំនងជាមួយមិត្តភក្តិបងប្អូនដែលជាមេធាវី និងចៅក្រមខ្លួនឯងជាសាក្សីសំខាន់ ឬជាអ្នកជំនាញនៅក្នុងរឿងក្តី។

## ៣.១០.គោលការណ៍ភាពសុចរិត

ប្រព័ន្ធតុលាការមួយដែលសុចរិត គឺជាប្រព័ន្ធដែលគេស្គាល់ថា មានលក្ខណៈទៀងត្រង់ យុត្តិធម៌ ស្មោះត្រង់ មិនវៀចវេរ និង ត្រឹមត្រូវ។

តាមរយៈនេះ យើងអាចឲ្យនិយមន័យដូចតទៅ៖

**សុចរិត** ថ្នាក់ជានាម(សំស្រ្កឹត និងបាលីលាយគ្នា)គឺជាការប្រព្រឹត្តល្អកាន់សុចរិត(ហៅសុចរិតធម៌ក៏បានដែរ) មាន ៣យ៉ាង គឺការប្រព្រឹត្តល្អដោយ កាយ ហៅថា កាយសុចរិត... ដោយវាចា ហៅថា វចីសុចរិត... ដោយចិត្តសុទ្ធ ហៅ មនោសុចរិត។ ព.ផ្ទ. ទុច្ចរិត។ សុចរិតយុត្តិធម៌ សុចរិត និងយុត្តិធម៌ យុត្តិធម៌ មានសុចរិតជាប្រមុខ, ជាប្រធាន។[៨៨]

**សុចរិត** គឺជាភាពត្រឹមត្រូវ មិនធ្វើផ្ទុយនឹងច្បាប់ ស្មោះត្រង់ និង មានមនសិការចំពោះវិជ្ជាជីវៈរបស់ខ្លួន។ បើនិយាយពីសុចរិតរបស់ចៅក្រមវិញ គឺមានន័យថា "**ចៅក្រម ផ្តល់ភាពយុត្តិធម៌ពិតប្រាកដដល់ភាគីនៃរឿងក្តី**"។

ទំនុកចិត្ត និងការគោរពដែលផ្តល់ដោយសាធារណជនដល់អង្គចៅក្រមមានសារៈសំខាន់ផ្តល់ប្រសិទ្ធភាពដល់ប្រព័ន្ធយុត្តិធម៌របស់យើង និងជាពិសេសទៅដល់អត្ថិភាពនៃលទ្ធិប្រជាធិបតេយ្យដោយឈរលើឧត្តមភាពនៃនីតិ។ កត្តាជាច្រើនអាចធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្ត និងការគោរពពីសំណាក់សាធារណជនដល់អង្គចៅក្រម ដូចជា ការទិតៀនដែលមិនសមហេតុផល ឬគ្រប់អាកប្បកិរិយារបស់ចៅក្រម ដែលបង្ហាញពីការខ្វះខាតភាពសុចរិតទោះក្នុងតុលាការ ឬក្រៅតុលាការក៏ដោយ។ ដូច្នេះ ចៅក្រម ត្រូវខំប្រឹងធ្វើឲ្យមានអាកប្បកិរិយាដែលសមនឹងទទួលការគោរពពីសារណជន ហើយត្រូវទទួលបានការបណ្តុះបណ្តាលឲ្យមានភាពជានិមិត្តរូបនៃសុចរិត អនាគតិ និងសុភវិនិច្ឆ័យ។[៨៩]

ឥរិយាបថរបស់ចៅក្រមទោះនៅក្នុងតុលាការក្តី នៅក្រៅតុលាការក្តី និងជាកម្មវត្ថុនៃការពិនិត្យពិចារណា។

---

[៨៨] ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, "វចនានុក្រមខ្មែរ", ភ្នំពេញ, ឆ្នាំ១៩៦៧, ទំព័រទី១៣៦៩

[៨៩] អ៊ីវវិចិត្រ និង ស៊ុន លៀងហេង សារណា ស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈចៅក្រម",ភ្នំពេញ,ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ទំព័រទី១៥

### ៣.១០.១.សុចរិតក្នុងតួនាទី

សុចរិត គឺជាតម្លៃផ្សារភ្ជាប់ជាមួយមុខងាររបស់ចៅក្រមក្នុងនាមជាមន្ត្រីដោះស្រាយចំពោះរឿងរ៉ាវផ្សេងៗដែលគេបញ្ជូនមកឲ្យខ្លួន។ សុចរិតធ្វើឲ្យមានវិធីសាស្ត្រអព្យាក្រឹតអមដោយការយល់ដឹងអំពីសារៈសំខាន់ និងការថ្លឹងថ្លែងរវាងការប្រកួតប្រជែងរកផលប្រយោជន៍នៅក្នុងរឿងក្តី។ ភាពសុចរិតនេះ ត្រូវឆ្លុះបញ្ចាំងតាមរយៈការកាត់សេចក្តីទាំងមូលចាប់ផ្តើមពីការពិនិត្យអង្គហេតុ និងអង្គច្បាប់ រហូតដល់រកដំណោះស្រាយចុងក្រោយ។ វត្តមាននៃភាពមិនលម្អៀងមានសារៈសំខាន់ក្នុងការធ្វើយ៉ាងណាឲ្យមានការសម្រេចចិត្ត ទទួលបាននូវការឯកភាពត្រឹមត្រូវថា ជាដំណោះស្រាយល្អមានយុត្តិធម៌តាមផ្លូវច្បាប់រវាងគូភាគីទាំងពីរ និង អាចទទួលយកបានពីសាធារណជនទូទៅ។

ដើម្បីរក្សានូវភាពសុចរិតក្នុងនាមជាចៅក្រម ត្រូវរក្សារាល់ព័ត៌មានសម្ងាត់ មិនត្រូវយកទៅប្រើ ឬផ្សព្វផ្សាយទៅខាងក្រៅ ដើម្បីទាញយកផលប្រយោជន៍ និងមិនត្រូវទទួលអំណោយក្នុងលក្ខណៈជាថ្នូរនឹងការសម្រេចរឿងក្តី ពោលជនទាំងឡាយដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារក្នុងអង្គចៅក្រម ត្រូវតែជាអ្នកមានសមត្ថភាព និង ជាអ្នកសុចរិតមានសីលធម៌ស្អាតស្អំ។

ក្នុងការទំនាក់ទំនងជាមួយសហការី និងបុគ្គលិកស្ថាប័នតុលាការ ចៅក្រមត្រូវប្រាស្រ័យទាក់ទងដោយភាពទន់ភ្លន់ សមរម្យ អត់ធ្មត់ និង មិនត្រូវបង្ហាញឲ្យឃើញនូវអាកប្បកិរិយាដែលមិនរីករាយ មិនសប្បាយចិត្ត ចំពោះមន្ត្រីតុលាការ ឬបុគ្គលិកតុលាការឡើយ។ ក្រៅពីបទដ្ឋានដ៏ឧត្តុងឧត្តមនៃអត្តចរិតផ្ទាល់ខ្លួន ចៅក្រមត្រូវជម្រុញសហសេវិករបស់ខ្លួនឲ្យធ្វើការដូចគ្នា និងត្រូវគិតថាឥរិយាបថដែលគួរឲ្យស្តីបន្ទោសរបស់ចៅក្រមម្នាក់ និងជះឥទ្ធិពលអាក្រក់ដល់អង្គចៅក្រមទាំងមូល។ ចៅក្រមមានឱកាសផងដែរ ក្នុងការត្រួតពិនិត្យមើលឥរិយាបថមិនសមរម្យតាមលក្ខណៈវិជ្ជាជីវៈរបស់ចៅក្រមម្នាក់ទៀត គាត់ត្រូវតែចាត់វិធានការកែស្តានការណ៍នោះភ្លាម។

សកម្មភាពទំនាក់ទំនងបែបនេះ ធ្វើឲ្យចៅក្រមអាចស្វែងរកព័ត៌មានពីសហសេវិករបស់ខ្លួន អាចផ្តល់ព័ត៌មានដល់សហសេវិកដែលមានបញ្ហា ឬក៏ជួយសហសេវិកដើម្បីទៅរកជំនួយ និង អាចលើកបញ្ហាជូនទៅដល់ប្រធានចៅក្រម ឬអនុប្រធានចៅក្រម (ប្រធានអង្គភាពដែលចៅក្រមកំពុងបម្រើការ)។

### ៣.១០.២.សុចរិតក្រៅតួនាទី

ជាគោលការណ៍ ចៅក្រមត្រូវទទួលបានការអនុញ្ញាតឲ្យជួយបំពេញការទទួលបន្ទុកនៅក្នុងស្ថាប័នតុលាការ ដើម្បីជានាមិត្តភាព និងការជាប់ទំនាក់ទំនងជាមួយគ្រួសារនៅក្នុងសកម្មភាពសង្គម។ ប៉ុន្តែ វាតម្រូវឲ្យចៅក្រម ត្រូវថ្លឹងថ្លែងអំពីតុល្យភាពរវាងតម្រូវការនៅក្នុងស្ថាប័នតុលាការ និងការទាមទារដោយស្របច្បាប់នៃជីវិតជាបុគ្គល ការអភិវឌ្ឍន៍ និងគ្រួសារ។ ចៅក្រម ត្រូវទទួលស្គាល់ថា

"ធម្មជាតិនៃមុខតំណែងជាចៅក្រម បានជម្រុញឲ្យពួកគេស្ថិតនៅក្រោមការតាមដាន និងកម្រិតនូវអត្តចរិតរបស់ខ្លួនខុសពីជនទូទៅដែលពុំមានសម្ពាធបែបនេះឡើយ"។

ដូចនេះ ចៅក្រម ត្រូវថែរក្សាតុល្យភាពដ៏ល្អិតល្អន់រវាងករណីយកិច្ច ដែលស្ថិតនៅក្នុងបន្ទុករបស់ខ្លួន និងភាពចាំបាច់ស្របច្បាប់ដែលទាក់ទងទៅនឹងជីវិតឯកជនរបស់ខ្លួន និង ភាពសប្បាយរីករាយផ្ទាល់ខ្លួនក៏ដូចជា ក្រុមគ្រួសារខ្លួនដែរ។

### ៣.១១.គោលការណ៍សេចក្ដីថ្លៃថ្នូរ

សេចក្ដីថ្លៃថ្នូរ គឺជាគុណភាព ឬស្ថានភាពនៃតម្លៃកិត្តិយស និង ការទទួលបាននូវការគោរព។ ប្រសិនបើចៅក្រមប្រព្រឹត្តអ្វីមួយ ដែលខ្វះខាតសេចក្ដីថ្លៃថ្នូរនឹងនាំឲ្យស្ថាប័នតុលាការខូចឈ្មោះ។ សីលធម៌ និងភាពសុចរិតរបស់ចៅក្រម គឺជាអំណាចពិតប្រាកដដែលសាធារណជនទទួលយក និងគោរព។ ក្នុងន័យនេះ មន្ត្រីតុលាការ ត្រូវតែធ្វើជាគំរូល្អប្រកបដោយសេចក្ដីថ្លៃថ្នូរទាំងក្នុងការងារក៏ដូចជាក្នុងជីវភាពផ្ទាល់ខ្លួនផងដែរ។

ហេតុដូច្នេះ ចៅក្រមត្រូវតែចងចាំថា "ខ្លួនជាបុគ្គល ដែលស្ថិតក្រោមការឃ្លាំមើលជាអចិន្ត្រៃយ៍ពីសាធារណជន"។ ដូច្នេះ ចៅក្រម ត្រូវទទួលយកការកាត់បន្ថយនូវសេរីភាព និងឆន្ទៈផ្ទាល់របស់ខ្លួនខ្លះៗ ដើម្បីឲ្យប្រជាពលរដ្ឋមើលឃើញថា មានតម្លៃ។

### ៣.១២.គោលការណ៍វិរិយភាព

ចៅក្រមត្រូវធានាថា ខ្លួនបំពេញកិច្ចការតុលាការ ឬអយ្យការប្រកបដោយវិរិយភាព គឺត្រូវព្យាយាមខិតខំប្រឹងប្រែងបំពេញកិច្ចការតុលាការឲ្យបានឆាប់រហ័ស និងមានសុក្រឹតភាព ថែរក្សា និងបង្កើននូវចំណេះដឹង ជំនាញរបស់ខ្លួន ដើម្បីបំពេញកិច្ចការតុលាការ ឬអយ្យការឲ្យបានសុក្រឹត និងមានគុណភាព។

ចៅក្រម មិនត្រូវធ្វើកិច្ចការអ្វីដែលមានវិសមិតភាពជាមួយនឹងការទទួលខុសត្រូវប្រកបដោយវិរិយភាពនៃកិច្ចការតុលាការ ឬអយ្យការឡើយ។[៩០]

[៩០] មាត្រា ២៩ នៃក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

យោងតាមការស្រាយបំភ្លឺទៅលើចំណុចជាច្រើនទាក់ទងទៅនឹងប្រធានបទស្តីពី **អំណាច និងឯករាជ្យភាពរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** រួចមក ធ្វើឲ្យយើងខ្ញុំអាចសន្និដ្ឋានបានថា អំណាចរបស់ចៅក្រម និងព្រះរាជអាជ្ញា ពិតជាមានសារៈសំខាន់មិនអាចខ្វះបានជាដាច់ខាត ដើម្បីធានាយុត្តិធម៌សង្គម ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ក៏ដូចជា សន្តិសុខសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការប្រព្រឹត្តទៅរបស់រដ្ឋមួយស្ថិតនៅក្នុងចរន្តនិរន្តរភាពដែលក្នុងនោះព្រះរាជអាជ្ញា ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ពីបទល្មើសអាជ្ញាសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ និងជាពិសេស ធានារ៉ាប់រងការអនុវត្តន៍សេចក្តីសម្រេចខាងព្រហ្មទណ្ឌក្នុងនាមផលប្រយោជន៍សង្គម។ រីឯចៅក្រមវិញមានអំណាចក្នុងការជំនុំជម្រះក្តី ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈនៃវិជ្ជាជីវៈឯករាជ្យរបស់ខ្លួនទៅតាមនីតិវិធីច្បាប់ជាធរមាន។

បើទោះបីជាចៅក្រម និងព្រះរាជអាជ្ញា គាត់មានអំណាចដូចមានចែងនៅក្នុងច្បាប់ក៏ដោយក្នុងនោះក៏តម្រូវឲ្យគាត់មានឯករាជ្យភាពជាចាំបាច់ គឺត្រូវមានឯករាជ្យភាពដែលកើតចេញពីឆន្ទៈដោយខ្លួនឯង និងការធានាឯករាជ្យភាពពីមជ្ឈដ្ឋានខាងក្រៅ។ ការធានាឯករាជ្យភាពដែលកើតចេញពីឆន្ទៈដោយខ្លួនឯង មានន័យថា ចៅក្រម និងព្រះរាជអាជ្ញា ត្រូវមានសមត្ថភាពចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់ក្នុងការអនុវត្តន៍ការងារវិជ្ជាជីវៈ មិនប្រព្រឹត្តអំពើពុករលួយ និងជៀសវាងឲ្យបាននូវអំពើអគតិធម៌ទាំង៤ គឺលម្អៀងព្រោះសេចក្តី ស្រឡាញ់, ស្អប់, ខ្លាច, ខ្លៅ(អវិជ្ជា)។ ចំណែកឯការធានាឯករាជ្យភាពពីខាងក្រៅ គឺពិតជាមានសារៈសំខាន់ណាស់ ដែលក្នុងនោះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានថ្វាយព្រះរាជតួនាទីដល់មហាក្សត្រ ជាអ្នកធានាឯករាជ្យភាពរបស់តុលាការ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកជួយព្រះអង្គក្នុងកិច្ចការនេះ។ ដូច្នេះ ព្រះមហាក្សត្រ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងស្ថាប័នតុលាការ ដើម្បីឲ្យស្ថាប័នតុលាការធានាបានឯករាជ្យភាព។ ការធានានេះគឺជាការធានាការពារការជ្រៀតជ្រែកពីគ្រប់មជ្ឈដ្ឋានទៅក្នុងស្ថាប័នតុលាការដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីតាមគ្រប់មធ្យោបាយ។

កាលណាចៅក្រម និងព្រះរាជអាជ្ញា បាត់បង់ឯករាជ្យភាពនោះ វានឹងធ្វើឲ្យមានអំពើអយុត្តិធម៌កើតឡើងនៅក្នុងសង្គម ដែលជាហេតុធ្វើឲ្យប្រជាជនក្រីក្រសាមញ្ញ ស្លូតត្រង់ ទទួលរងការឈឺចាប់ខ្លោចផ្សារនៅក្នុងការរស់នៅ អំពើជិះជាន់កេងប្រវ័ញ្ចកើតឡើងកាន់តែច្រើនឡើងៗ បង្កឲ្យមាន

អស្ថេរភាព អសន្តិសុខនៅក្នុងសង្គមជាតិ ស្ថាប័នតុលាការទាំងមូលត្រូវបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ និងទទួលរងនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋាន។ ផ្ទុយទៅវិញកាលណាស្ថាប័នតុលាការមានអំណាច និងឯករាជ្យភាព មិនមានការជ្រៀតជ្រែកពីគ្រប់មជ្ឈដ្ឋាន វានាំឲ្យការសម្រេចសេចក្ដីរបស់តុលាការ មានយុត្តិធម៌ធ្វើឲ្យប្រជាពលរដ្ឋមានទំនុកចិត្តទៅលើស្ថាប័នតុលាការទាំងមូល ដោយធានាបាននូវយុត្តិធម៌ជូនប្រជាពលរដ្ឋ។

ដូច្នេះ ឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា ជាឧបករណ៍តែមួយគត់សម្រាប់ច្រោះ ឬរាវរកយុត្តិធម៌ពិតប្រាកដ ដែលជាយន្តការមិនអាចខ្វះបានក្នុងការធានាស្ថេរភាពសង្គម។

## ២.អនុសាសន៍

ក្រោយពីបានធ្វើការស្រាយបំភ្លឺទៅលើប្រធានបទ និងធ្វើការសន្និដ្ឋានជារួមរួចមក ក្នុងនាមយើងខ្ញុំជាកុលបុត្រខ្មែរ និងជាទំពាំងស្នងឬស្សីនៃប្រទេសជាតិ យើងខ្ញុំសូមផ្ដល់នូវអនុសាសន៍មួយចំនួន ដើម្បីអាចជួយពង្រឹងនូវអំណាច និងឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា បន្ថែមទៀតក្នុងការធានាបានយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិខ្មែរយើងទាំងមូល ដែលក្នុងនោះរួមមាន៖

- ការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញា ត្រូវតែមានស្ថាប័នមួយឯករាជ្យ ក្នុងការធានាជ្រើសបានបេក្ខជនដែលមានសមត្ថភាព និងចំណេះដឹងផ្នែកច្បាប់។
- ស្ថាប័នតុលាការ ត្រូវតែមានថវិកាស្វយ័តរបស់ខ្លួន មិនគួរគប្បីឲ្យថវិកានេះស្ថិតនៅក្នុងកញ្ចប់ថវិការបស់ស្ថាប័ននីតិប្រតិបត្តិឡើយ។
- ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ មិនត្រូវជាសមាជិកគណបក្សនយោបាយឡើយ៕

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

២. ច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣

៣. ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

៤. ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

៥. ព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៦. ព្រះរាជក្រមលេខ នស/រកម/០៧០៦ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

៧. ព្រះរាជក្រមលេខ នស/រកម/០៨០៧ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. អង្គការសហប្រជាជាតិ "គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ"

២. សេចក្តីប្រកាសនៅប៉េកាំងស្តីពី "គោលការណ៍ឯករាជ្យភាពរបស់តុលាការនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីភិច" បេកាំង, ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៥

## III. សេចក្តីព្រាងច្បាប់

១. សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

២. សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤

## IV. **ក្រមសីលធម៌**

១. ក្រមសីលធម៌ចៅក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧

## V. **ឯកសារជាសៀវភៅ**


១. **ចាំង ស៊ីណាត**, សិក្ខាសាលាស្តីពី "ក្រមនីតិវិធីព្រហ្មទណ្ឌ", រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០

២. **ជួន សុរាសី** "នីតិវិធីសង្ខេប រដ្ឋប្បវេណី និង ព្រហ្មទណ្ឌ" ភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩

៣. **ឱត មុន្នី**, សន្ទរកថាក្នុងឱកាសបើកសិក្ខាសាលាស្តីពី "ក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា", ភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥

៤. **សុខ គាង**, វិទ្យាសាស្ត្រនយោបាយ, ភាគ១

៥. **រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត**, ឯកសារមេរៀន "នីតិវិធីព្រហ្មទណ្ឌ " បោះពុម្ពឆ្នាំ២០១៣

៦. **ហ៊ាង ឡេង**, ឯកសារមេរៀនឆ្នាំទី២ "នីតិព្រហ្មទណ្ឌទូទៅ"

៧. **អ៊ីវ វិចិត្រ និង ស៊ុន លៀងហេង** សារណា ស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈចៅក្រម" ភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩

៨. វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, សៀវភៅសិក្សាផ្នែកទី៣, ការពិចារណាពិស្តារផ្នែកគតិយុត្ត, "ប្រព័ន្ធតុលាការ", ភ្នំពេញ, ខែកក្កដា ឆ្នាំ២០០៤

៩. ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ "វចនានុក្រមខ្មែរ" ភ្នំពេញ, ឆ្នាំ១៩៦៧

១០. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, របាយការណ៍ប្រចាំឆមាសលើកទី៣ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាការវិវឌ្ឍក្នុងរយៈពេលពេញ១ឆ្នាំ"បោះពុម្ពខែមករា ឆ្នាំ២០១២

១១. វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, សៀវភៅសិក្សាផ្នែកទី៣, ការពិចារណាពិស្តារផ្នែកគតិយុត្ត "ប្រព័ន្ធតុលាការ " ភ្នំពេញ, ខែកក្កដា ឆ្នាំ២០០៤


## VI. **គេហទំព័រនានា**


១. http://km.wikipedia.org/wiki/អំណាច

២. http://dict.antkh.com/dictionaries/independence.aspx

៣. http://www.khmerbuddhism.ca/profiles/blogs/3-11

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

❖❖❖❖

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យ ថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា"កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងរីកចម្រើនលូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

## ជំពូកទី ១១ ថ្មី
## អំពីអំណាចតុលាការ

**មាត្រា ១២៨._ ថ្មី (មាត្រា ១០៩ ចាស់)**

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩._ ថ្មី (មាត្រា ១១០ ចាស់)**

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០.- ថ្មី (មាត្រា ១១១ ចាស់)**

គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**មាត្រា ១៣១.- ថ្មី (មាត្រា ១១២ ចាស់)**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២.- ថ្មី (មាត្រា ១១៣ ចាស់)**

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**មាត្រា ១៣៣.- ថ្មី (មាត្រា ១១៤ ចាស់)**

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រម ដែលបានប្រព្រឹត្តខុស ។

**មាត្រា ១៣៤.- ថ្មី (មាត្រា ១១៥ ចាស់)**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និងមុខងារ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជំរះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។

**មាត្រា ១៣៥ . - ថ្មី (មាត្រា ១១៦ ចាស់)**

លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

# ច្បាប់

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ
## នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៩ ន.ស.៩៤

## ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

### ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នា ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានសេចក្តីតទៅនេះ ÷

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការរៀបចំ និង ការប្រព្រឹត្តទៅនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ជំពូកទី ១

## ការរៀបចំ តួនាទី និងសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មាត្រា ១.-

អនុលោមតាមមាត្រា ១១៣ និងមាត្រា ១១៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតអោយមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះមហាក្សត្រក្នុងការធានាឯករាជ្យនៃអំណាចតុលាការ ធានាវិន័យរបស់ចៅក្រម និងធានាការប្រព្រឹត្តទៅនៃសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា អោយដំណើរការបានល្អប្រសើរ ។

មាត្រា ២.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសមាសភាពដូចខាងក្រោមនេះ ៖

| | | |
|---|---|---|
| ១- | ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៣- | ប្រធានតុលាការកំពូល | សមាជិក |
| ៤- | អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | សមាជិក |
| ៥- | ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| ៦- | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| ៧- | ចៅក្រម ០៣ រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម | សមាជិក |

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវមានសមាជិកបំរុង ០៣ រូបទៀតដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស សំរាប់ជំនួសសមាជិកជាប់ឆ្នោតដែលអវត្តមាន ។

សមាជិកទាំងអស់ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។

សមាជិកទាំងអស់ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីមានវិសមិតភាព រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវបានជំនួសដោយអ្នកដឹកនាំមួយរូបទៀតនៃក្រសួងយុត្តិធម៌ ។

មាត្រា ៣.-

ព្រះមហាក្សត្រទ្រង់ជាប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងអោយធ្វើជាអធិបតីនៃអង្គប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

មាត្រា ៤.-

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវបានបោះឆ្នោតជ្រើសតាំង មានអាណត្តិ ៥ ឆ្នាំ ហើយអាចឈរឈ្មោះជាបន្តបន្ទាប់ សំរាប់អាណត្តិក្រោយទៀតបាន ។

មាត្រា ៥.-

ក្នុងករណីដែលសមាជិកជ្រើសតាំងណាមួយដោយការបោះឆ្នោត លាឈប់ឬអវត្តមានលើស ៦ ខែ សមាជិកបោះឆ្នោតជ្រើសតាំងនោះ ត្រូវជំនួសដោយសមាជិកបំរុងដែលមានអតីតភាពចាស់ជាងគេ ។ ក្នុងករណីនេះ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកបំរុងបំពេញបន្ថែម ។

មាត្រា ៦.-

បែបបទនិងការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកពេញសិទ្ធិនិងសមាជិកបំរុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ២
## ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មាត្រា ៧.-

ការប្រជុំ ត្រូវកោះប្រជុំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមព្រះរាជបញ្ជានៃព្រះមហាក្សត្រ ។

ការប្រជុំ អាចស្នើឡើងដោយសមាជិក ៣ រូប យ៉ាងតិច

មាត្រា ៨.-

ការប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងទុកជាបានការ លុះត្រាតែមានសមាជិក ៧ រូប យ៉ាងតិចចូលរួមប្រជុំ ។

មាត្រា ៩.-

សេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវយកតាមមតិភាគច្រើននៃសមាជិកវត្ត-មាន និងតាមការបោះឆ្នោតជាសម្ងាត់ ។ ប្រធានអង្គប្រជុំមិនចូលរួមក្នុងការបោះឆ្នោតនេះទេ ។ ប៉ុន្តែក្នុងករណី ដែលមានការបែងចែកសំលេងជាពីរស្មើគ្នា ប្រធានអង្គប្រជុំជាអ្នកសម្រេច

មាត្រា ១០.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពិគ្រោះមតិជាចាំបាច់ ដើម្បីផ្តល់យោបល់ទៅលើសេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់ ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការនិងការប្រព្រឹត្តទៅនៃវិស័យនេះ ។

យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីស្នើច្បាប់ ឬ សេចក្តីព្រាងច្បាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្នុងករណីប្រញាប់ រយៈពេលនេះអាចបន្ថយមកត្រឹម ១០ ថ្ងៃ ។

មាត្រា ១១.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចនិងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាច់ពីមុខងារ ការដាក់អោយនៅទំនេរ ការដាក់អោយនៅក្រៅក្របខ័ណ្ឌ ការហូតងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អោយយោបល់ចំពោះការតម្លើងថ្នាក់ និងការតម្លើងឋានន្តរសក្តិអោយចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ ។

មាត្រា ១២.-

ក្នុងមុខការដាក់ទោសវិន័យចំពោះចៅក្រមនិងព្រះរាជអាជ្ញា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ និងក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីដាក់ទោសវិន័យទាក់ទងនឹងចៅក្រមឬព្រះរាជអាជ្ញា ។

ក្នុងករណីខាងលើនេះ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលរួមទេ ។

សមាជិកជាប់ឆ្នោតដែលអវត្តមាន ត្រូវបានជំនួសដោយសមាជិកបំរុង ។

ក្នុងករណីត្រូវដាក់វិន័យចំពោះប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក្រុមប្រឹក្សាវិន័យត្រូវស្ថិតក្រោមព្រះរាជអធិបតីភាពនៃព្រះមហាក្សត្របព្រះរាជតំណាង ។

សំណុំឯកសារទាក់ទងដល់សាមីជនដែលត្រូវដាក់ទោសវិន័យ ត្រូវផ្ញើទៅជូនសមាជិកក្រុមប្រឹក្សាវិន័យទាំងអសពិនិត្យយ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ។

មាត្រា ១៣.-

ប្រធានក្រុមប្រឹក្សាវិន័យកំណត់ថ្ងៃ និងធ្វើការកោះប្រជុំ ។

មាត្រា ១៤.-

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ , ត្រូវធ្វើដូចសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានចែងក្នុងមាត្រា ៩ ។

មាត្រា ១៥.-

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យយល់ព្រម ។ សេចក្តីសម្រេចនេះជាសេចក្តីសម្រេចបិទការតវ៉ា ។

មាត្រា ១៦.-

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមព្រមទាំងអ្នកដែលចូលរួម ត្រូវ រក្សាការសម្ងាត់នៃអង្គប្រជុំ ។

មាត្រា ១៧.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសរើសចៅក្រមម្នាក់និងក្រឡាបញ្ជី អោយទទួលរ៉ាប់រងមុខងារជាលេខាធិការ ដែលមានភារកិច្ចធ្វើរបាយការណ៍ ធ្វើកំណត់ហេតុ រក្សាឯកសារនិងបំពេញកិច្ចការផ្សេងៗទៀត ។

មាត្រា ១៨.-

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវទទួលប្រាក់បំណាច់ម៉ោងប្រជុំដែលនឹងត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។

មាត្រា ១៩.-

ការចំណាយសំរាប់ដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវគ្រោងក្នុងថវិការបស់ក្រសួងយុត្តិធម៌ ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

មាត្រា ២០.-

ក្រោយពីច្បាប់នេះចូលជាធរមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីមានការព្រមព្រៀងពីប្រធានតុលាការកំពូល ត្រូវស្នើសុំទៅព្រះមហាក្សត្រ តែងតាំងចៅក្រម ៣ រូប ជាសមាជិកបណ្តោះអាសន្ននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរាប់អំឡុងពេលដែលពុំទាន់អាចរៀបចំបោះឆ្នោតជ្រើសរើសចៅក្រមសមាជិក តាមបទបញ្ញត្តិនៃមាត្រា ៨ ខាងលើបាន ។

ចៅក្រមតែងតាំងនេះ ត្រូវចប់ភារកិច្ចជាស្វ័យប្រវត្តិ នៅពេលចៅក្រមសមាជិកជាប់ឆ្នោតចូលមកទទួលការងារ ។

មាត្រា ២១.-

ការរៀបចំបោះឆ្នោតជ្រើសរើសចៅក្រមជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើក្រោយពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមចូលជាធរមាន និងបន្ទាប់ពីមានការតែងតាំងចៅក្រមអោយចូលក្នុងក្របខ័ណ្ឌចៅក្រមរួច ។

មាត្រា ២២.-

ចៅក្រមទទួលការងារដែលចាត់តាំងតាមបទបញ្ញត្តិនៃមាត្រា ២០ ខាងលើ មានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះជាបេក្ខជនអោយសហសេវិកខ្លួនបោះឆ្នោតជ្រើសរើសបាន ។

ប៉ុន្តែចៅក្រមនេះ ត្រូវលាឈប់ពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចាប់តាំងពីថ្ងៃដាក់ពាក្យសុំជាបេក្ខជន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី២

ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ជែម ស្គួន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌ចៅក្រម

អនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧

បោះពុម្ពផ្សព្វផ្សាយដោយតុលាការកំពូល

## ជំពូកទី ១

## គោលបំណង

ប្រការ ១ : គោលបំណង

## ជំពូកទី ២

## គោលការណ៍ ឯករាជភាព

ប្រការ ២ : គោលការណ៍

ប្រការ ៣ : ការប៉ុនប៉ងប្រើឥទ្ធិពលលើចៅក្រម

ប្រការ ៤ : សកម្មភាពនយោបាយ

ប្រការ ៥ : សមាជិកភាព នៃគណៈកម្មការមួយចំនួនរបស់រាជរដ្ឋាភិបាល

ប្រការ ៦ : ទំនាក់ទំនងផ្ទាល់ខ្លួន និង សង្គម

## ជំពូកទី៣

## គោលការណ៍ អនាគតិ (ភាពមិនលំអៀង)

ប្រការ ៧ : គោលការណ៍

ប្រការ ៨ : អាកប្បកិរិយា និង ការធ្វើសវនាការ

ប្រការ ៩ : ការស៊ើបអង្កេត ឬ ស៊ើបសួររឿងក្តី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្តី

ប្រការ ១០ : ទំនាក់ទំនង វិជ្ជាជីវៈ សង្គម និង គ្រួសារ

ប្រការ ១១ : សកម្មភាពពាណិជ្ជកម្ម

ប្រការ ១២ : សកម្មភាពសង្គម និង មនុស្សធម៌

ប្រការ ១៣ : ការផ្តល់សេវាកម្មច្បាប់ និង កិច្ចការច្បាប់

ប្រការ ១៤ : អត្ថប្រយោជន៍ហិរញ្ញវត្ថុ

ប្រការ ១៥ : ការនិយាយស្តីនៅទីសាធារណៈរបស់ចៅក្រម ក្នុងនាមជាបុគ្គល

ប្រការ ១៦ : ការអប់រំផ្នែកច្បាប់

ប្រការ ១៧ : ការដកខ្លួនរបស់ ចៅក្រម

## ជំពូកទី៤

## គោលការណ៍ ភាពសុចរិត

ប្រការ ១៨ : គោលការណ៍

ប្រការ ១៩ : ពតិមានសម្ងាត់

ប្រការ ២០ : ការទទួលយកអំណោយ (កាដូ)

ប្រការ ២១ : អាកប្បកិរិយា និង ការបញ្ជាក់លើឯកសារនានា

ប្រការ ២២ : ការប្រើប្រាស់នូវមុខតំណែងតុលាការ ឬ អយ្យការ

ប្រការ ២៣ : ទំនាក់ទំនងជាមួយមន្ត្រី និង បុគ្គលិកតុលាការ ឬ អយ្យការ

## ជំពូកទី៥

## គោលការណ៍ សេចក្តីថ្លៃថ្នូរ

ប្រការ ២៤ : គោលការណ៍

ប្រការ ២៥ : ការចូលរង្គសាល ក្លឹបកំសាន្ត លេងល្បែង ជាសមាជិកភាពនៃសកម្មភាពកំសាន្តផ្សេងៗ

ប្រការ ២៦ : ការចូលរួមជាមួយសាធារណៈជន

ប្រការ ២៧ : ស្ថានភាពហិរញ្ញវត្ថុ

ប្រការ ២៨ : អតីតចៅក្រម

## ជំពូកទី៦

## គោលការណ៍ ធិរិយភាព

ប្រការ ២៩ : គោលការណ៍

ប្រការ ៣០ : អត្ថិភាពនៃមូលដ្ឋាន ឬ សំអាងហេតុនៃសេចក្តីសម្រេច

ប្រការ ៣១ : កិច្ចការអាទិភាព

ប្រការ ៣២ : ការត្រួតពិនិត្យបុគ្គលិកតុលាការ ឬ អយ្យការក្រោមឱវាទ

ប្រការ ៣៣ : សកម្មភាពផ្ទាល់ខ្លួន

# ពេលបំពេញកិច្ចការតុលាការ ឬ អយ្យការ

## ចៅក្រមត្រូវមាន :

- **វិរិយសម្បយុត្ត** = ការបំពេញកិច្ចការប្រកបដោយវិរិយភាព
- **សុចរិតយុត្តិធម៌** = ភាពទៀងត្រង់ និង យុត្តិធម៌
- **បញ្ញត្តិគារវតា** = ការប្រតិបត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់
- **សមទណ្ឌា** = សមភាពនៃទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តអំពើល្មើសដូចគ្នា
- **បញ្ញានុធវិនិច្ឆ័យ** = ការសម្រេចសេចក្តីដែលប្រកបដោយបញ្ញា និង ភាពឆ្លាតវៃ

## ត្រូវវៀរសវាងនូវអគតិទាំង ៤ គឺ :

- **ឆន្ទាគតិ** = លំអៀងព្រោះស្រឡាញ់
- **ទោសាគតិ** = លំអៀងព្រោះទោសៈ ឬ ស្អប់
- **ភយាគតិ** = លំអៀងព្រោះភ័យខ្លាច
- **មោហាគតិ** = លំអៀងព្រោះមោហៈ ល្ងង់ អវិជ្ជា

## ជំពូកទី ១

## គោលបំណង

**ប្រការ ១ : គោលបំណង**

ក្រមសីលធម៌នេះមានគោលបំណងពង្រឹងនូវឯករាជភាព និង សេចក្តីថ្លៃថ្នូរបស់ចៅក្រមទាំងអស់ ក្នុងការអនុវត្តកិច្ចការតុលាការ ឬ អយ្យការ ក៏ដូចជាការប្រកាន់នូវឥរិយាបថរបស់ខ្លួននៅក្រៅតុលាការ ។ នៅក្នុងក្រមសីលធម៌នេះ ចៅក្រមមានន័យថា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ ។

ក្រមសីលធម៌នេះ គឺជាការបំពេញបន្ថែមលើច្បាប់ និង សេចក្តីណែនាំផ្សេងៗទៀតចំពោះចៅក្រម ដើម្បីបង្កើននូវជំនឿទុកចិត្តពីសាធារណៈជនលើប្រព័ន្ធតុលាការ និង ការពារកេរ្តិ៍ឈ្មោះចៅក្រម ។

## ជំពូកទី ២

## គោលការណ៍ ឯករាជភាព

**ប្រការ២ : គោលការណ៍**

ចៅក្រមត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ ឈរលើមូលដ្ឋាននៃការវាយតម្លៃលើអង្គហេតុ និង ផ្អែកលើចំណេះដឹងផ្នែកច្បាប់ ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗ ដូចជា ការអូសទាញ ការគៀបសង្កត់ ការគំរាមកំហែង ឬ ការជ្រៀតជ្រែកពីសំណាក់ជនណាម្នាក់ ឬ ច្រើននាក់ ឬ ហេតុផលអ្វីមួយ ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ដើម្បីបង្ហាញឱ្យគេមើលឃើញថា ជាបុគ្គលមានចរិតយុត្តិធម៌ និង មានមូលគតិយុត្តិច្បាស់លាស់ក្នុងការវិនិច្ឆ័យសេចក្តី ។ ចៅក្រមត្រូវប្រានចោលនូវការប៉ុនប៉ងទាំងឡាយណា ដែលធ្វើអោយមានឥទ្ធិពលដល់ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន ។

**ប្រការ៣ : ការប៉ុនប៉ង ដើម្បីធ្វើអោយមានឥទ្ធិពលដល់ចៅក្រម**

ចៅក្រមត្រូវប្រានចោលនូវការប៉ុនប៉ងដាក់ជូន ឬ ស្នើសុំអ្វីដែលមិនមែនជាសេចក្តីបញ្ជាក់ជំរឿង ឬ ភស្តុតាងក្នុងអំឡុងពេលដំណើរការនីតិវិធីពីភាគី ឬ អ្នកតំណាងរបស់ភាគី ។ ប្រសិនបើចៅក្រមនោះមិនអាចប្រានចោលនូវការប៉ុនប៉ងដាក់ជូន ឬ ស្នើសុំនោះទេ ចៅក្រមនោះត្រូវស្នើសុំយោបល់ពីប្រធានអង្គភាពរៀងៗខ្លួន ដើម្បីចាត់វិធានការណ៍តាមច្បាប់ ។

**ប្រការ៤ : សកម្មភាពនយោបាយ**

ចៅក្រម ត្រូវស្ថិតនៅជាអព្យាក្រឹត្យក្នុងសកម្មភាពនយោបាយ ។

**ប្រការ៥ : សមាជិកភាព នៃគណៈកម្មការមួយចំនួនរបស់រាជរដ្ឋាភិបាល**

ចៅក្រមអាចចូលរួមផ្តល់ទស្សនៈទានដល់រដ្ឋបាលយុត្តិធម៌ និង ការកែលំអច្បាប់ ដោយប្រើចំណេះដឹងផ្នែកច្បាប់ និង បទពិសោធន៍តុលាការ ឬ អយ្យការរបស់ខ្លួន ។ ក្នុងន័យនេះដើម្បីជាផលប្រយោជន៍សាធារណៈចៅក្រមអាចចូលរួមក្នុងគណៈកម្មការមួយចំនួនរបស់រាជរដ្ឋាភិបាល ក្នុងទំហំសកម្មភាពដែលចាំបាច់ទាក់ទង នឹងការពិភាក្សាច្បាប់

កែលំអប្រពន្ធ័យុត្តិធម៌ និង លើកកំពស់កំណែទំរង់ច្បាប់ ។

**ប្រការ៦ : ទំនាក់ទំនងបុគ្គល និង សង្គម**

ចៅក្រមមានសិទ្ធិដឹកនាំជីវិតផ្ទាល់របស់ខ្លួន និង ប្រើប្រាស់សិទ្ធិ និង សេរីភាពដូចប្រជាពលរដ្ឋដទៃមានដែរ ។ ប៉ុន្តែចៅក្រមត្រូវថ្លឹងថ្លែងអោយបានច្បាស់លាស់ អំពីតុល្យភាព រវាងតម្រូវការស្របច្បាប់នៃទំនាក់ទំនងបុគ្គល និង សង្គម និង ទំហំហានិភ័យនៃទំនាក់ទំនងនោះ ដែលអាចមានឥទ្ធិពលមិនប្រក្រតីដល់អាកប្បកិរិយា និង ការវិនិច្ឆ័យសេចក្តីរបស់ខ្លួន ។

## ជំពូកទី៣

## គោលការណ៍ អនាគតិ (ភាពមិនលំអៀង)

**ប្រការ៧ : គោលការណ៍**

ចៅក្រមត្រូវមានអាកប្បកិរិយា ទាំងក្នុង និង ក្រៅតុលាការនូវលក្ខណៈអនាគតិរបស់ខ្លួនដើម្បីការពារថែរក្សា និង លើកកំពស់ជំនឿទុកចិត្តពីសំណាក់សាធារណៈជន អ្នកមានវិជ្ជាជីវៈច្បាប់ និង ភាគីវិវាទ ។

ចៅក្រមមិនត្រូវចូលរួមពិភាក្សាជាសាធារណៈ ពាក់ព័ន្ធទៅនឹងបញ្ហា ដែលអាចមាននៅតុលាការឡើយ ព្រោះវាអាចនាំឱ្យប៉ះពាល់ដល់ ជំនឿទុកចិត្តអំពីអនាគតិរបស់ចៅក្រម ។

នៅក្នុងការសម្រេចសេចក្តី ចៅក្រម មិនត្រូវធ្វើបុរេវិនិច្ឆ័យ ទាក់ទងទៅនឹង ជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ពិការភាព អាយុ ស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និង សង្គមឡើយ ។

ម្ចាស់បណ្តឹងអាជ្ញា ត្រូវស្វែងរកភស្តុតាងដាក់បន្ទុក ដើម្បីធ្វើការចោទប្រកាន់ ប៉ុន្តែមិនត្រូវមានភាពលំអៀងក្នុងការចោទប្រកាន់ឬមិនចោទប្រកាន់ឡើយ គឺត្រូវធានានូវភាពត្រឹមត្រូវ និង ប្រសិទ្ធភាពក្នុងការធ្វើបណ្តឹងអាជ្ញា ។

**ប្រការ៨ : អាកប្បកិរិយា និង ការធ្វើសវនាការ**

នៅពេលដំណើរការនីតិវិធី ចៅក្រមត្រូវ :

- -បង្ហាញនូវភាពហ្មត់ចត់ គោរពពេលម៉ោងធ្វើការ អត់ធ្មត់ ចេះគួរសម មានសីលធម៌ និង យុត្តិធម៌នៅពេលបំពេញកិច្ចការតុលាការ ។
- -មិនអធិប្បាយនូវអ្វីដែលមិនចាំបាច់ និង មិនសមហេតុផលនៅក្នុងតុលាការ ។
- -រក្សាសុភាវធម៌ជានិច្ច និង ជៀសវាងនូវការប៉ះទង្គិច ឬ ការសម្តែងណាមួយដែលអាចនាំឱ្យមានការយល់ច្រឡំ ឬ សង្ស័យអំពីអនាគតិឡើយ ។

**ប្រការ៩ : ការស៊ើបអង្កេត ឬ ស៊ើបសួររឿងក្តី ការប្រាស្រ័យទាក់ទងជាមួយភាគីនៃរឿងក្តី**

ផ្អែកតាមគោលការណ៍ចំពោះមុខចៅក្រម មិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយនៅពេលដំណើការនីតិវិធីដោយអវត្តមាននៃភាគីម្ខាងទៀតឡើយ លើកលែងតែច្បាប់អនុញ្ញាត ឬ ភាគីម្ខាងទៀតនោះយល់ព្រម ។ ចៅក្រមមិនត្រូវធ្វើការស៊ើបអង្កេត ឬ ស៊ើបសួរអង្គហេតុនៃរឿងក្តីដោយឯកឯង និង ផ្ទាល់ខ្លួនទាំងក្នុងតុលាការ ទាំងក្រៅតុលាការ

លើកលែងតែច្បាប់អនុញ្ញាត ។

ចំពោះបទល្មើសព្រហ្មទណ្ឌ មេធាវីត្រូវស៊ើបអង្កេតរាល់អំពើដែលច្បាប់បញ្ញត្តថាជាបទល្មើស ប៉ុន្តែពេលដែលខ្លួនទទួលបាននូវភស្តុតាងដាក់បន្ទុកលើជនសង្ស័យណាមួយដែលគេបានដឹង ឬ មានជំនឿថា ជាភស្តុតាងបានមកពីការប្រើប្រាស់វិធីមិនស្របច្បាប់ដែលបានរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់សង្ស័យរូបនោះ ជាពិសេសទាក់ទងនឹងការធ្វើទារុណកម្ម ឬ ប្រព្រឹត្តកម្មអមនុស្សធម៌ ឬ សកម្មភាពរំលោភលើសិទ្ធិមនុស្សផ្សេងៗទៀតនោះត្រូវបដិសេធមិនប្រើភស្តុតាងបែបនោះ ដើម្បីដាក់បន្ទុកលើជនសង្ស័យឡើយ ហើយត្រូវចាត់គ្រប់វិធានការណ៍ចាំបាច់ទាំងអស់ដើម្បីធានាថាបុគ្គល ដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តខាងលើត្រូវបាននាំខ្លួនទៅកាន់តុលាការភ្លាម ។

**ប្រការ១០ : ទំនាក់ទំនង វិជ្ជាជីវៈ សង្គម និង គ្រួសារ**

នៅពេលបំពេញការងារ មេធាវីអាចជួប និង ពិភាក្សាជាមួយអ្នកមានវិជ្ជាជីវៈច្បាប់បាន ។ មេធាវីក៏អាចចូលរួមផងដែរ ក្នុងសកម្មភាពសង្គមរួមគ្នាជាមួយសមាជិកមកពីផ្នែកដទៃដែលផ្តល់សេវាកម្មច្បាប់ ។

មេធាវីមិនគួរជំនុំជំរះរឿងក្តីណា ដែលមានមេធាវីមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គលជាមួយខ្លួនឡើយ ។

**ប្រការ១១ : សកម្មភាពពាណិជ្ជកម្ម**

មេធាវីមិនអាចធ្វើជំនួញដើម្បីបានទទួលនូវប្រាក់កំរៃឬអត្ថប្រយោជន៍អ្វីឡើយ ពីព្រោះថា សកម្មភាពនោះអាចរំខានដល់ការបំពេញការងារត្រឹមត្រូវ និង មានប្រសិទ្ធិភាពរបស់ខ្លួន ឬ អាចគេយល់ថា មេធាវីប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីរកស៊ី ឬ អាចធ្វើឱ្យមេធាវី មានទំនាក់ទំនងពាណិជ្ជកម្មជាមួយបុគ្គល ដែលអាចមានរឿងក្តីនៅតុលាការ ។

**ប្រការ១២ : សកម្មភាពសង្គម និង មនុស្សធម៌**

មេធាវីត្រូវបានលើកទឹកចិត្តឱ្យចូលរួមសកម្មភាពក្នុងសង្គមជាលក្ខណៈពលរដ្ឋឯកជន ដែលទាក់ទងដល់មនុស្សធម៌ និង អប់រំ ប៉ុន្តែត្រូវជៀសវាងនូវសកម្មភាពណាមួយដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពលំអៀងរបស់ខ្លួន ឬ រំខានដល់ការបំពេញកិច្ចការតុលាការ ឬ អយ្យការ និង មិនត្រូវប្រើប្រាស់កិត្យានុភាពនៃមុខតំណែងតុលាការ ឬ អយ្យការដើម្បីទាញយកផលប្រយោជន៍សំរាប់អង្គការ ឬ ក្រុមពិសេសណាមួយឡើយ ។

**ប្រការ១៣ : ការផ្តល់សេវាកម្មច្បាប់ និង កិច្ចការច្បាប់**

មេធាវីមិនត្រូវផ្តល់សេវាកម្មច្បាប់ឡើយ ។ ប្រសិនបើចាំបាច់ ក្រៅពីគូក្តីនៃសំណុំរឿងដែលខ្លួនទទួលបន្ទុក អាចផ្តល់បាន តែមិនត្រូវយកកំរៃឡើយ ។

មេធាវីអាចធ្វើកិច្ចការច្បាប់ជាលក្ខណៈផ្ទាល់ខ្លួនបានដូចជា ការបង្រៀន ការសរសេរសៀវភៅ និង វណ្ណកម្មផ្សេងៗ ដើម្បីទទួលបានកម្រៃ ។

**ប្រការ១៤ :** អត្ថប្រយោជន៍ហិរញ្ញវត្ថុ

មេធាវីមិនត្រូវមានអត្ថប្រយោជន៍ហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍អ្វីផ្សេង ទោះដោយផ្ទាល់ក្តី ឬ ដោយ

ប្រយោលក្តី ក្នុងរឿងក្តីដែលខ្លួនកាន់ឡើយ ។

**ប្រការ១៥ ៖ ការនិយាយស្តីនៅទីសាធារណៈរបស់ចៅក្រម ក្នុងនាមជាបុគ្គល**

សេចក្តីថ្លែងរបស់ចៅក្រម អំពីបញ្ហាច្បាប់អាចមានតម្លៃធំធេង ក្នុងការជំរុញឱ្យមានការយល់ដឹងពីសាធារណៈជន លើប្រព័ន្ធតុលាការ និង ការអភិវឌ្ឍន៍ច្បាប់ ។ ក៏ប៉ុន្តែចៅក្រមត្រូវតែប្រុងប្រយ័ត្នថា ការថ្លែងជាសាធារណៈរបស់ខ្លួន ដែលបានធ្វើជាលក្ខណៈបុគ្គលនោះ អាចជាការឆ្លុះបញ្ចាំងនូវទស្សនៈតុលាការទាំងមូល និង មុខតំណែងតុលាការរបស់ខ្លួន ។ ដូច្នេះចៅក្រមត្រូវតែប្រុងប្រយ័ត្ននៅពេលធ្វើការថ្លែងជាសាធារណៈជាលក្ខណៈបុគ្គល ជាពិសេស ចៅក្រមត្រូវជៀសវាង ដាច់ខាតនូវការថ្លែង ៖

១-ទាក់ទងនឹងភាពចំរូងចំរាស់នយោបាយ

២-ពាក់ព័ន្ធនឹងគណបក្សនយោបាយ

៣-នាំអោយមានវិវាទ ឬ ការទិតៀនពីបុគ្គលិកតុលាការ ដែលមានទស្សនៈផ្ទុយគ្នា

៤-បញ្ចេញទស្សនៈ ដែលបណ្តាលអោយមានភាពលំអៀង ឬ បុរេវិនិច្ឆ័យចំពោះរឿងក្តី ដែលខ្លួនទទួលបន្ទុក ឬ នឹងទទួលបន្ទុក ។

៥-ទាក់ទងនឹងការសម្រេចសេចក្តី ឬ សាលក្រមរបស់ខ្លួន ។

**ប្រការ១៦ ៖ ការអប់រំផ្នែកច្បាប់**

ដោយផ្អែកលើចំណេះដឹងផ្នែកច្បាប់ និង បទពិសោធន៍ផ្នែកកិច្ចការតុលាការ ឬ អយ្យការ ចៅក្រមអាចរួមចំណែកផ្តល់ការអប់រំផ្នែកច្បាប់ដល់ទាំងសាធារណៈជន ទាំងអ្នកមានវិជ្ជាជីវច្បាប់ ។ ក្នុងន័យនេះចៅក្រមអាច ៖

១-ចូលរួមផ្តល់ការបណ្តុះបណ្តាលច្បាប់ ដូចជា ការសរសេរ ការផ្តល់បទឧទ្ទេសនាម ឬ បង្រៀនអំពីច្បាប់

២-ចូលរួមជាសមាជិក នៃគណៈកម្មការកែទំរង់ច្បាប់ និង តុលាការ ។

**ប្រការ១៧ ៖ ការដកខ្លួនរបស់ ចៅក្រម**

ប្រសិនបើចៅក្រមមានមូលដ្ឋានច្បាស់ថា ខ្លួនមិនអាចសម្រេចសេចក្តី ដោយអនាគតិបានទេនោះត្រូវដកខ្លួនពីការជំនុំជំរះ ដោយផ្អែកតាមក្រមនីតិវិធី ។

## ជំពូកទី៤
## គោលការណ៍ ភាពសុចរិត

**ប្រការ១៨ ៖ គោលការណ៍**

បុគ្គលសុចរិត គឺជាបុគ្គលដែលទៀងត្រង់ និង មិនប្រព្រឹត្តអំពើពុករលួយ ។ គោលការណ៍មូលដ្ឋាននៃសីលធម៌ដែលបុគ្គលសុចរិតត្រូវគោរពតាម នឹងមិនប្រែប្រួលឡើយ ទោះបីជាខ្លួននៅក្នុងតុលាការ ឬ ធ្វើសកម្មភាពផ្សេងនៅក្រៅតុលាការក៏ដោយ ។ នោះគឺជាគុណភាពនៃភាពសុចរិត ដែលអាចធ្វើឱ្យចៅក្រមថែរក្សាបាននូវឯករាជភាព និង អនាគតិទាំង

ទិដ្ឋភាពខាងក្នុង និង ទិដ្ឋភាពខាងក្រៅ ។ ដូច្នេះចៅក្រមត្រូវតែជាបុគ្គលសុចរិតមិនត្រូវប្រើប្រាស់ ឬ ឱ្យគេប្រើប្រាស់នូវកិត្យានុភាពនៃមុខតំណែងតុលាការរបស់ខ្លួន ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។

**ប្រការ១៩ : ព័ត៌មានសម្ងាត់**

ព័ត៌មានសម្ងាត់ ដែលចៅក្រមដឹងមិនត្រូវយកទៅប្រើប្រាស់សម្រាប់សកម្មភាពណា ដែលមិនទាក់ទងនឹងកិច្ចការតុលាការ ឬ អយ្យការឡើយ ។

**ប្រការ២០ : ការទទួលយកអំណោយ (កាដូ)**

ចៅក្រមត្រូវបែងចែកអោយបានច្បាស់លាស់នូវអំណោយ ដែលជូនឱ្យខ្លួនជាលក្ខណៈបុគ្គលពីមិត្តភក្តិជិតស្និទ្ធ ឬ បងប្អូនសាច់ញាតិ និង អំណោយដែលជូនឱ្យខ្លួនជាលក្ខណៈផ្លូវការ ។ បញ្ហានឹងមិនមានទេ ប្រសិនបើចៅក្រមទទួលយកអំណោយជាលក្ខណៈបុគ្គល និង មានតម្លៃតិចតួចហើយមិនមានការពាក់ព័ន្ធនឹងមុខតំណែងតុលាការ ឬ អយ្យការ ។

ចៅក្រមមិនត្រូវប្រើប្រាស់មុខតំណែងរបស់ខ្លួន ដើម្បីទាក់ទាញយកអំណោយ ការជប់លៀង ការខ្ចី ឬ ការបំពេញចិត្តអ្វីឡើយ ។ ប៉ុន្តែ ចៅក្រម អាចទទួលយកនូវអំណោយដោយសារខ្លួនបានធ្វើបទឧទ្ទេសនាម ទទួលភ្ញៀវបរទេស ឬ ចូលរួមក្នុងកម្មវិធីផ្សេងៗ ប្រសិនបើអំណោយនោះមើលទៅឃើញថា មិនមានលក្ខណៈធំដុំអាចទទួលយកបាន ។

**ប្រការ២១ : អាកប្បកិរិយា និង ការបញ្ជាក់លើឯកសារនានា**

ចៅក្រមមិនត្រូវធ្វើការបញ្ជាក់លើលិខិត ឬ ឯកសារនានាឱ្យមិត្តភក្តិ ឬ បងប្អូនសាច់ញាតិ ដោយប្រើប្រាស់ឈ្មោះមុខតំណែង និង ឋានៈរបស់ខ្លួនឡើយ ។

**ប្រការ២២ : ការប្រើប្រាស់នូវមុខតំណែងតុលាការ ឬ អយ្យការ**

ចៅក្រមមិនត្រូវប្រើប្រាស់ឈ្មោះ មុខតំណែង និង ឋានៈរបស់ខ្លួន ដើម្បីឱ្យមានការផ្គាប់ផ្គុន ឬ យកចិត្តទុកដាក់ពិសេស ឬ ដើម្បីស្វែងរកប្រយោជន៍ឡើយ ។ ឧទាហរណ៍ដូចជា : លិខិតដែលធ្វើឡើងជាលក្ខណៈឯកជនទាក់ទងនឹងបញ្ហាបុគ្គលរបស់ចៅក្រមមានជាអាទិ៍ ការទិញផ្ទះ ទិញរថយន្ត...ជាដើម ចៅក្រមត្រូវជៀសវាងប្រើប្រាស់ឈ្មោះមុខតំណែង និង ឋានៈតុលាការរបស់ខ្លួន ។

**ប្រការ២៣ : ទំនាក់ទំនងជាមួយមន្ត្រី និង បុគ្គលិកតុលាការ**

ចៅក្រមត្រូវប្រាស្រ័យទាក់ទងជាមួយមន្ត្រី និង បុគ្គលិក ក្រោមឱវាទរបស់ខ្លួន ដោយភាពទន់ភ្លន់ និង សមរម្យ ។ ចៅក្រមត្រូវចេះអត់ធ្មត់ ដោយមិនបង្ហាញឱ្យឃើញនូវអាកប្បកិរិយាដែលខ្លួនមិនរីករាយ ឬ មិនសប្បាយចិត្តចំពោះនរណាម្នាក់ ប៉ុន្តែគ្រាន់តែបង្ហាញអោយឃើញថា អំពើនោះនឹងមិនអាចទទួលយកបានទេ ។

## ជំពូកទី៥

## គោលការណ៍ សេចក្តីថ្លៃថ្នូរ

**ប្រការ២៤ : គោលការណ៍**

ចៅក្រមត្រូវតែចងចាំថា ខ្លួនជាបុគ្គលដែលស្ថិតក្រោមការឃ្លាំមើលជាអចិន្ត្រៃយ៍ពីសាធារណៈជន ។ ដូច្នេះ

ចៅក្រមត្រូវទទួលយកការកាត់បន្ថយនូវសេរីភាព និង ឆន្ទៈផ្ទាល់របស់ខ្លួនខ្លះដើម្បីឱ្យប្រជាពលរដ្ឋមើលឃើញថា មានតម្លៃ ។

**ប្រការ២៥ : ការចូលរង្គសាល ក្លឹបកំសាន្ត លេងល្បែង ជាសមាជិកភាពនៃសកម្មភាពកំសាន្ត ផ្សេងៗ**

ចៅក្រមអាចប្រើប្រាស់សិទ្ធិ និង សេរីភាពរបស់ខ្លួនដូចប្រជាពលរដ្ឋដទៃ ក្នុងការកំសាន្តផ្សេងៗនៅក្រៅតុលាការបាន ។ ប៉ុន្តែចៅក្រមត្រូវប្រុងប្រយ័ត្នថា ទោះបីជាសកម្មភាពកំសាន្តនោះស្របច្បាប់ ប្រជាប្រិយ និង អាចមានប្រយោជន៍ដល់សង្គមក៏ដោយ ក៏ពេលខ្លះអាចនាំឱ្យ ចៅក្រមបាត់បង់នូវសេចក្តីថ្លៃថ្នូរដែរ ។ ចៅក្រមក៏គួរជៀសវាងផងដែរនូវកន្លែងកំសាន្តដែលមិនមានសេចក្តីថ្លៃថ្នូរគ្រប់គ្រាន់ ។

**ប្រការ២៦ : ការចូលរួមជាមួយសាធារណៈជន**

ចៅក្រមអាចចូលរួមជាមួយសាធារណៈជន ក្រៅតុលាការ ដើម្បីរួមចំណែកក្នុងសង្គម និង អាចធ្វើសកម្មភាពដូចជា បញ្ចេញមតិលើប្រធានបទដែលមិនមែនជាច្បាប់ និង សំដែងសកម្មភាពទាក់ទងនឹងប្រវត្តិសាស្ត្រ ការអប់រំ វប្បធម៌ សិល្បៈ កីឡា ឬ សកម្មភាពសង្គមប្រហាក់ប្រហែលនេះបាន ។

**ប្រការ២៧ : ស្ថានភាពហិរញ្ញវត្ថុ**

ចៅក្រមមិនត្រូវត្អូញត្អែរអំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនប្រាប់បុគ្គលដែលមានរឿងក្តីឡើយ ។

**ប្រការ២៨ : អតីតចៅក្រម**

អតីតចៅក្រមអាចប្រើប្រាស់សិទ្ធិ និង សេរីភាព ដើម្បីដឹកនាំជីវភាពរបស់ខ្លួនដូចពលរដ្ឋដទៃដែរ ។ ប៉ុន្តែអតីតចៅក្រមមិនត្រូវនិយាយ ឬ ធ្វើសកម្មភាពណាមួយ ដែលគេអាចមើលឃើញថា ខ្លួនធ្វើក្នុងនាមតុលាការ ឬ ពាក់ព័ន្ធនឹងអំណាចតុលាការឡើយ ។

## ជំពូកទី ៦
## គោលការណ៍ ឧរិយភាព

**ប្រការ២៩ : គោលការណ៍**

ចៅក្រមត្រូវធានាថា ខ្លួនបំពេញកិច្ចការតុលាការ ឬ អយ្យការប្រកបដោយវីរិយភាព គឺត្រូវព្យាយាមខិតខំប្រឹងប្រែងបំពេញកិច្ចការតុលាការអោយបានឆាប់រហ័ស និង មានសុក្រឹតភាព ថែរក្សា និង បង្កើននូវចំណេះដឹងជំនាញរបស់ខ្លួន ដើម្បីបំពេញកិច្ចការតុលាការ ឬ អយ្យការឱ្យបានសុក្រឹត និង មានគុណភាព ។

ចៅក្រម មិនត្រូវធ្វើកិច្ចការអ្វីដែលមានវិសមិតភាពជាមួយនឹងការទទួលខុសត្រូវប្រកបដោយវីរិយភាពនៃកិច្ចការតុលាការ ឬ អយ្យការឡើយ ។

**ប្រការ៣០ : អត្ថិភាពនៃមូលដ្ឋាន ឬ សំអាងហេតុនៃសេចក្តីសម្រេច**

ការរៀបចំមូលដ្ឋាន ឬ សំអាងហេតុនៃសេចក្តីសម្រេច គឺជាដំណើរការលំបាក និង ប្រើប្រាស់ពេលច្រើន ។ ក្នុងន័យនេះ ចៅក្រម គប្បីមានពេលវេលាគ្រប់គ្រាន់ដើម្បីស្រាវជ្រាវ ពិភាក្សា និង សរសេរនូវមូលដ្ឋាន ឬ សំអាងហេតុនៃសេចក្តីសម្រេចនោះ ។ ប៉ុន្តែចៅក្រមមិនត្រូវអូសបន្លាយពេលវេលានេះរហូតដល់ពាត់វេងយុត្តិធម៌ឡើយ ។

**ប្រការ៣១ : កិច្ចការអាទិភាព**

កិច្ចការតុលាការ ឬ អយ្យការរបស់ចៅក្រមមានអាទិភាពជាងកិច្ចការដទៃ ។ ចៅក្រមត្រូវធានាថា កិច្ចការដទៃដែលខ្លួនត្រូវបំពេញនៅក្រៅតុលាការ ដូចជាសមាជិកភាពនៃគណៈកម្មការ ឬ ក្រុមប្រឹក្សាណាមួយ មិនត្រូវរំខានដល់ប្រសិទ្ធិភាពនៃកិច្ចការរបស់តុលាការ ឬ អយ្យការឡើយ ។ ទន្ទឹមនឹងនេះចៅក្រមណាម្នាក់ដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកកិច្ចការរដ្ឋបាល ឬ កិច្ចការដទៃ បន្ថែមលើកិច្ចការតុលាការ ឬ អយ្យការ គប្បីទទួលបាននូវការផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីអោយចៅក្រមនោះបំពេញកិច្ចការទាំងនោះប្រកបដោយវិរិយភាព ។

**ប្រការ៣២ : ការត្រួតពិនិត្យបុគ្គលិកតុលាការ ឬ អយ្យការក្រោមឱវាទ**

បច្ចុប្បន្ននេះចៅក្រម បំពេញកិច្ចការតុលាការផង និង កិច្ចការរដ្ឋបាលខ្លះផង ។ ដូច្នេះកិច្ចការខ្លះត្រូវបំពេញដោយបុគ្គលិកតុលាការ ឬ អយ្យការក្រោមការត្រួតពិនិត្យ និងណែនាំពីចៅក្រម ។ ក្នុងន័យនេះចៅក្រមត្រូវត្រួតពិនិត្យលើបុគ្គលិកតុលាការ ឬ អយ្យការទាំងនោះឱ្យបំពេញកិច្ចការដែលខ្លួនទទួលខុសត្រូវប្រកបដោយវិរិយភាព ។

**ប្រការ៣៣ : សកម្មភាពផ្ទាល់ខ្លួន និងការទទួលស្គាល់**

លទ្ធភាពរបស់ចៅក្រមក្នុងការបំពេញកិច្ចការ តុលាការ ឬ អយ្យការរបស់ខ្លួនប្រកបដោយវិរិយភាព គឺពឹងផ្អែកទៅលើទំហំការងារ បុគ្គលិកជំនួយគ្រប់គ្រាន់ សម្ភារៈសម្រាប់បម្រើការងារគ្រប់គ្រាន់ និង ពេលវេលា ។ ដូច្នេះចៅក្រម គប្បីទទួលបានបុគ្គលិកជំនួយគ្រប់គ្រាន់ សម្ភារៈសម្រាប់បម្រើការងារគ្រប់គ្រាន់ និង ពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការតុលាការ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ពេលវេលា និង សម្ភារៈផ្ទាល់ខ្លួនឡើយ ។

**ក្រមសីលធម៌នេះត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម យល់ព្រម**
**នាសម័យប្រជុំលើកទី ១៣ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧**

*ព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧*

**ព្រះប្រធាន**
**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

**នរោត្តម សីហមុនី**

# គោលការណ៍ជាមូលដ្ឋាន

# ស្ដីពី

# ឯករាជ្យភាពរបស់តុលាការ

# គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ

Basic Principles on the Independence of the judiciary

ត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៧ ស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តលើអ្នកទោសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងមីលែន ចាប់ពីថ្ងៃទី ២៦ ខែ សីហា ដល់ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៨៥ ហើយត្រូវបានគាំទ្រដោយសេចក្តីសំរេចចិត្តលេខ ៤០/៣២ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ និងសេចក្តីសំរេចចិត្តលេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៨៥ របស់មហាសន្និបាត អ.ស.ប ។

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួនថានឹងបង្កើតនូវលក្ខខណ្ឌនានាដែលអាចរក្សាបាននូវយុត្តិធម៌ ដើម្បីសំរេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការលើកទឹកចិត្ត និងជំរុញឱ្យមានការគោរពសិទ្ធិមនុស្ស និងការគោរពសេរីភាពជាសារវ័ន្ត ដោយគ្មានការរើសអើង ។

*ដោយហេតុថា* សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស បានចែងជាពិសេសនូវគោលការណ៍មួយចំនួនដូចជាគោលការណ៍ស្តីពីសមភាពចំពោះមុខច្បាប់ គោលការណ៍ស្តីពីការសន្មតជាមុនថាគ្មានទោស គោលការណ៍ស្តីពីសិទ្ធិក្នុងការទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយដែលមានសមត្ថកិច្ច មានឯករាជ្យភាព និងមិនលំអៀងហើយដែលតុលាការនេះបានបង្កើតឡើងដោយច្បាប់ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាទាំងពីរនេះបានធានានូវការអនុវត្តសិទ្ធិទាំងនោះ ហើយលើសពីនេះទៅទៀតកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានធានាបន្ថែមទៀតពីសិទ្ធិក្នុងការទទួលបាននូវការជំនុំជំរះដោយគ្មានការពន្យារពេល ដែលមិនសមហេតុមិនសមផលឡើយ ។

*ដោយហេតុថា* ជាញឹកញាប់ វានៅតែមានខ្វះចន្លោះរវាងទស្សនៈដែលបានកំណត់ក្នុងគោលការណ៍ទាំងនោះ និងស្ថានភាពពិត ។

*ដោយហេតុថា* ការរៀបចំ និងការគ្រប់គ្រងវិស័យយុត្តិធម៌ នៅតាមបណ្តាប្រទេសទាំងឡាយត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវតែខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនោះឱ្យក្លាយជាការពិតយ៉ាងពេញលេញ

*ដោយហេតុថា* វិធាននានាដែលកំពុងប្រើប្រាស់ក្នុងតុលាការ គួរតែមានទិសដៅធ្វើអោយចៅក្រមអាចអនុវត្តតាមគោលការណ៍ទាំងនោះ ។

*ដោយហេតុថា* ចៅក្រមជាអ្នកទទួលខុសត្រូវក្នុងការចេញសេចក្តីសំរេចចុងក្រោយលើអាយុជីវិត សេរីភាព សិទ្ធិកាតព្វកិច្ច និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ។

*ដោយហេតុថា* សមាជលើកទី៦ របស់ អ.ស.ប ស្តីអំពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តទៅលើជនល្មើស តាមសេចក្តីសំរេចរបស់ខ្លួនលេខ ១៦ បានអំពាវនាវសុំឱ្យគណៈកម្មាធិការទប់ស្កាត់ និងគ្រប់គ្រងបទល្មើស ដាក់បញ្ចូលទៅក្នុងចំណោមបញ្ហាអាទិភាពរបស់ខ្លួន នូវការបង្កើតគោលការណ៍ណែនាំពាក់ព័ន្ធនឹងឯករាជ្យភាពរបស់ចៅក្រម ការជ្រើសរើសការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ។

ហេតុដូច្នេះហើយ បានជាគេយល់ថា វាជាការប្រពៃណាស់ ដែលគេត្រូវយកចិត្តទុកដាក់គិតគូរដំបូងបំផុត ចំពោះតួនាទីចៅក្រមក្នុងប្រព័ន្ធយុត្តិធម៌ និងចំពោះការជ្រើសរើស ការបណ្តុះបណ្តាល និងក្រមសីលធម៌របស់ចៅក្រម ។

គោលការណ៍ជាមូលដ្ឋានខាងក្រោមនេះ ត្រូវបានបង្កើតឡើង ដើម្បីជួយរដ្ឋជាសមាជិកនានា ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការធានា និងការលើកស្ទួយនូវឯករាជ្យភាពតុលាការ ដែលរដ្ឋាភិបាលទាំងឡាយគួរធ្វើការពិចារណា និងគោរពតាមក្នុងក្របខ័ណ្ឌច្បាប់ និងការអនុវត្តជាក់ស្តែងក្នុងក្របខ័ណ្ឌជាតិ ហើយត្រូវបញ្ជាក់ប្រាប់ចៅក្រម មេធាវី សមាជិកអង្គនីតិប្រតិបត្តិ សមាជិកអង្គនីតិបញ្ញត្តិ និងសាធារណៈជនទូទៅឱ្យបានដឹងផងដែរ ។ គោលការណ៍ទាំងនេះត្រូវបានបង្កើតឡើងជាពិសេស សំរាប់ចៅក្រមអាជីព អនុវត្តតាម ប៉ុន្តែចៅក្រមក្រៅក្របខ័ណ្ឌ ក៏អនុវត្តតាមគោលការណ៍នេះឱ្យបានយ៉ាងសមរម្យដូចគ្នាផងដែរ ។

## ឯករាជ្យភាពតុលាការ

១. រដ្ឋត្រូវធានានូវឯករាជ្យភាពតុលាការ និងត្រូវចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ជាតិ ។ នេះគឺជាកាតព្វកិច្ចរបស់ស្ថាប័នទាំងអស់ ទាំងស្ថាប័នរដ្ឋ និងស្ថាប័នផ្សេងៗទៀត ក្នុងការគោរពប្រតិបត្តិ និងជួយឃ្លាំមើលពីឯករាជ្យភាពតុលាការ ។

២. តុលាការត្រូវសំរេចរឿងក្តីទាំងអស់នៅចំពោះមុខខ្លួន ដោយមិនលំអៀង ជាពិសេសផ្អែកលើអង្គហេតុ និងអង្គច្បាប់ដោយមិនមានការដាក់កំហិត ការប្រើឥទ្ធិពលដែលមិនត្រឹមត្រូវ ការជំរុញ ការកៀបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែកទោះដោយផ្ទាល់ ឬដោយប្រយោល ពីមជ្ឈដ្ឋានណាមួយ ឬដោយមូលហេតុណាមួយក៏ដោយ ។

៣. តុលាការត្រូវមានយុត្តាធិការលើគ្រប់រឿងក្តីទាំងអស់ដែលមានចរិតជាការវិនិច្ឆ័យ ហើយមានអំណាចពេញលេញក្នុងការសំរេចរឿងក្តីណាមួយដែលបានប្តឹងសុំឱ្យតុលាការសំរេច នៅក្នុងសមត្ថកិច្ចរបស់ខ្លួន តាមច្បាប់កំណត់ ។

៤. មិនត្រូវឱ្យមានការជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់តុលាការដោយពុំសមស្រប ឬដោយគ្មានមូលដ្ឋានត្រឹមត្រូវឡើយ ។ ការសំរេច ឬវិនិច្ឆ័យរបស់តុលាការ ពុំត្រូវឱ្យមានការសើរើពិនិត្យឡើងវិញឡើយ ។ ប៉ុន្តែគោលការណ៍នេះពុំបានឃាត់ឃាំងមិនអោយធ្វើការសើរើពិនិត្យតាមបែបតុលាការ ឬការបន្ធូរបន្ថយទោស ឬការសំរាលទោសដោយអាជ្ញាធរមានសមត្ថកិច្ច ចំពោះទោសដែលតុលាការបានសំរេចស្របតាមច្បាប់ឡើយ ។

៥. ជនគ្រប់រូបមានសិទ្ធិទទួលបានការវិនិច្ឆ័យទោសពីតុលាការធម្មតា ឬសាលាក្តីដែលប្រើប្រាស់នីតិវិធីដែលមានស្រាប់ ។ សាលាក្តីទាំងឡាយណាដែលមិនប្រើនីតិវិធីដែលមានស្រាប់ឱ្យបានត្រឹមត្រូវតាមច្បាប់ទេនោះ សាលាក្តីនោះមិនត្រូវបង្កើតឡើងទេ ព្រោះវាអាចប៉ះពាល់ដល់យុត្តាធិការរបស់តុលាការធម្មតា ឬសាលាក្តីដទៃទៀត ។

៦. គោលការណ៍ឯករាជ្យភាពតុលាការ អនុញ្ញាត និងតម្រូវឱ្យតុលាការធានាដល់ការជំនុំជំរះ ឬការវិនិច្ឆ័យទោសឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវ និងយុត្តិធម៌ ហើយត្រូវគោរពសិទ្ធិរបស់គូភាគី ។

៧. រដ្ឋជាសមាជិកនីមួយៗ មានកាតព្វកិច្ចផ្តល់ធនធានគ្រប់បែបយ៉ាង ដើម្បីឱ្យតុលាការអាចបំពេញមុខងារ របស់ខ្លួនឱ្យបានត្រឹមត្រូវ ។

## សេរីភាពក្នុងការសំដែងមតិ និងការបង្កើតសមាគម

៨. អនុលោមតាមសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មន្ត្រីតុលាការ ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសេរីភាពពេញលេញក្នុងការសំដែងមតិ ប្រកាន់នូវជំនឿ ការបង្កើតសមាគមហើយនិងការរួមប្រជុំគ្នា ។ ប៉ុន្តែក្នុងការប្រើប្រាស់សិទ្ធិសេរីភាពទាំងនេះ ចៅក្រមទាំងអស់ត្រូវតែប្រកាន់ខ្ជាប់ជានិច្ចនូវឥរិយាបថបែបនេះ ដើម្បីរក្សាសេចក្តីថ្លៃថ្នូរចំពោះតុលាការ ចំពោះភាពមិនលំអៀង និងចំពោះឯករាជ្យភាពតុលាការ ។

៩. ចៅក្រមទាំងឡាយ ត្រូវមានសេរីភាពពេញលេញក្នុងការបង្កើត និងចូលរួមក្នុងសមាគមជាមួយចៅក្រម ឬអង្គការផ្សេងទៀត ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន និងដើម្បីជំរុញឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន ព្រមទាំងដើម្បីការពារដល់ឯករាជ្យភាពតុលាការ ។

## លក្ខណសម្បត្តិ ការជ្រើសរើស និងការបណ្តុះបណ្តាល

១០. បុគ្គលដែលត្រូវជ្រើសរើសឱ្យចូលបំរើការក្នុងតុលាការ ត្រូវតែជាបុគ្គលសុចរិត ទៀងត្រង់ និងមានសមត្ថភាពដោយបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ឬមានចំណេះដឹងខ្ពង់ខ្ពស់ខាងផ្នែកច្បាប់ ។ ការជ្រើសរើសចៅក្រមឱ្យបំរើការនៅតុលាការ ទោះបីតាមវិធីណាក៏ដោយ ក៏ត្រូវតែប្រុងប្រយ័ត្នជានិច្ចកុំឱ្យមានការចាត់តាំងចៅក្រម ដោយមូលហេតុមិនសមរម្យ ។ ក្នុងការជ្រើសរើសចៅក្រម មិនត្រូវឱ្យមានការរើសអើងចំពោះបុគ្គលណាម្នាក់ដោយមូលហេតុ ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិដើម ឬឋានៈសង្គម ទ្រព្យសម្បត្តិ ដើមកំណើតជាតិ ឬ ឋានៈដទៃទៀត លើកលែងតែការតម្រូវឱ្យបេក្ខជនសំរាប់តុលាការនោះ ដែលត្រូវតែមានសញ្ជាតិនៃប្រទេសសាមីប៉ុណ្ណោះ ហើយឈរលើមូលហេតុបែបនេះ គេមិនត្រូវចាត់ទុកថា ជាការរើសអើងឡើយ ។

## លក្ខខណ្ឌការងារ និងមុខតំណែង

១១. អាណត្តិនៃការងារ ឯករាជ្យភាព សន្តិសុខ ប្រាក់បៀវត្សន៍ លក្ខខណ្ឌការងារ ប្រាក់សោធននិវត្តន៍ ហើយនិងអាយុចូលនិវត្តន៍ របស់ចៅក្រម ត្រូវធានាឱ្យបានគ្រប់គ្រាន់ដោយច្បាប់ ។

១២. ចៅក្រមគ្រប់រូប ទោះជាត្រូវតែងតាំង ឬត្រូវបោះឆ្នោតជ្រើសរើសក្តី ត្រូវតែធានានូវការកាន់មុខតំណែងរហូតដល់អាយុចូលនិវត្តន៍តាមច្បាប់កំណត់ ឬរហូតដល់ចប់អាណត្តិនៃសាលាក្តីនោះ បើសិនជាសាលាក្តីនោះអាចកើតមានឡើង

១៣. ប្រសិនជាមានការតំលើងឋានន្តរសក្តិដល់ចៅក្រម គួរផ្អែកលើកត្តាសត្យានុម័ត ជាពិសេស គឺជាអ្នកមានសមត្ថភាព មានចិត្តសុច្ចរិត ទៀងត្រង់ និងមានបទពិសោធន៍ក្នុងការងារ ។

១៤. ការបែងចែករឿងក្តីឱ្យចៅក្រមនៅតុលាការ គឺជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋបាលតុលាការ ។

## ការសំងាត់ខាងវិជ្ជាជីវៈ និងអភ័យឯកសិទ្ធិ

១៥. តុលាការត្រូវមានកាតព្វកិច្ចរក្សាការសំងាត់ខាងវិជ្ជាជីវៈ ចំពោះការពិភាក្សា និងពតិមានសំងាត់ដែលបានទទួល នៅក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ក្រៅតែពីកិច្ចដំណើរការទាំងឡាយដែលត្រូវធ្វើជាសាធារណៈហើយមិនត្រូវបង្ខំឱ្យតុលាការបំភ្លឺលើបញ្ហាអាថិកំបាំងទាំងនោះឡើយ ។

១៦. ដោយមិនធ្វើឱ្យប៉ះពាល់ ឬបំពារបំពានលើនីតិវិធីខាងបទវិន័យ ឬលើសិទ្ធិប្តឹងឧទ្ធរណ៍ ឬលើការទាមទារសំណង ពីរដ្ឋទេ ហើយដើម្បីឱ្យស្របតាមច្បាប់ជាតិ ចៅក្រមគួរមានអភ័យឯកសិទ្ធិ ដែលត្រូវរួចផុតពីបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងជម្ងឺចិត្តជាលុយកាក់ ដោយសារទង្វើមិនត្រឹមត្រូវ ឬការខកខានមិនបានបំពេញមុខងាររបស់ខ្លួនជាចៅក្រម

## ការដាក់វិន័យ ការព្យួរការងារ និងការដកចេញពីមុខតំណែង

១៧. បើមានការចោទប្រកាន់ ឬពាក្យប្តឹងតវ៉ាទៅលើចៅក្រមណាមួយ ក្នុងឋានៈខ្លួនជាអ្នកប្រកបវិជ្ជាជីវៈក្នុងកិច្ចការតុលាការ គេត្រូវយករឿងនេះទៅដោះស្រាយឱ្យបានរួសរាន់ និងដោយយុត្តិធមិតាមនីតិវិធីដ៏ត្រឹមត្រូវ ។ ចៅក្រមត្រូវមានសិទ្ធិទទួលបានការបើកសវនាការមួយដើម្បីជំនុំជំរះរឿងក្តីរបស់ខ្លួនប្រកបដោយយុត្តិធមិ ។ ការសួរដេញដោលលើរឿងរ៉ាវក្នុងដំណាក់កាលដំបូងនេះ ត្រូវរក្សាទុកជាការសំងាត់ជានិច្ច វាលែងតែមានការស្នើសុំពីចៅក្រមរូបនេះ ។

១៨. គេអាចព្យួរ ឬដកចៅក្រមចេញពីមុខតំណែង ដោយសារមូលហេតុអសមត្ថភាព ឬអត្តចរិកមិនសមរម្យសំរាប់ការបំពេញភារកិច្ចរបស់ខ្លួន ។

១៩. រាល់កិច្ចដំណើរការក្នុងការដាក់វិន័យ ការព្យួរ ឬការដកចេញពីមុខតំណែង ត្រូវកំណត់អោយស្របទៅតាមនិយាមនៃក្រមសីលធមិចៅក្រមដែលមានស្រាប់ ។

២០. រាល់កិច្ចដំណើរការក្នុងការសំរេចដាក់វិន័យ ការព្យួរ ឬការដកចៅក្រមចេញពីមុខតំណែង ត្រូវស្ថិតក្រោមការពិនិត្យមើលឡើងវិញដោយឯករាជ្យ ។ គោលការណ៍នេះមិនអាចអនុវត្តចំពោះសេចក្តីសំរេចរបស់តុលាការកំពូល និងស្ថាប័ននានាខាងនីតិបញ្ញត្តិ ក្នុងការចោទប្រកាន់ នៅចំពោះមុខតុលាការ ឬកិច្ចដំណើរការដែលស្រដៀងគ្នានេះទេ ។

# គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា

អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ ។

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញរបស់អង្គសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួន ថានឹងបង្កើតនូវលក្ខខណ្ឌដែលអាចរក្សាបាននូវភាពយុត្តិធម៌ និងបានប្រកាសតាមគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់ខ្លួនអំពីការធ្វើឱ្យបានសម្រេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយឥតមានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ

*ដោយហេតុថា* សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានតំកល់ទុកនូវគោលការណ៍សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោសពៃរ៍ និងសិទ្ធិទទួលការជំនុំជំរះក្តីដ៏ត្រឹមត្រូវ និងជាសាធារណៈមួយ ពីតុលាការឯករាជ្យ និងមិនលំអៀង

*ដោយហេតុថា* ជាញឹកញាប់ នៅមានចន្លោះមួយរវាងទស្សនៈយល់ឃើញវែងឆ្ងាយដែលកំណត់គោលការណ៍ទាំងនោះជាមូលដ្ឋាន និងស្ថានការណ៍ពិត

*ដោយហេតុថា* ការរៀបចំ និងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសទាំងឡាយ ត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនោះឱ្យក្លាយជាការពិតយ៉ាងពេញលេញ

*ដោយហេតុថា* ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តតាមការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន គួរតែលើកស្ទួយការគោរព និងការប្រតិបត្តិតាមរបស់ខ្លួនចំពោះគោលការណ៍ទាំងឡាយដែលបានពោលខាងលើ ដូច្នេះនាំឱ្យមានការចូលរួមចំណែកដើម្បីភាពយុត្តិធម៌ខាងព្រហ្មទណ្ឌដ៏សមរម្យ សមភាព និងដើម្បីប្រជាពលរដ្ឋ ឱ្យមានប្រសិទ្ធិភាពប្រឆាំងនឹងឧក្រិដ្ឋកម្ម ។

*ដោយហេតុថា* ជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិជំនាញដែលតម្រូវក្នុងការបំពេញមុខងាររបស់ខ្លួនឱ្យបានសម្រេច តាមរយៈរូបមន្តនៃការជ្រើសរើសដ៏ល្អប្រសើរ និងការហ្វឹកហ្វឺនផ្នែកច្បាប់ និងជំនាញ ហើយនិងតាមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ ដើម្បីគោលការណ៍ណែនាំដូចមានចែងខាងក្រោមនេះ ដែលត្រូវបានរៀបចំឡើងយ៉ាងជាក់លាក់ដើម្បីជួយដល់រដ្ឋជាសមាជិកក្នុងការងាររបស់ខ្លួន ដើម្បីធានា និងលើកស្ទួយប្រសិទ្ធិភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវរបស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ គប្បីត្រូវបានគោរពតាម និងយកទៅពិចារណាដោយរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍របស់ខ្លួនហើយគួរតែផ្សព្វផ្សាយដល់ព្រះរាជអាជ្ញាព្រមទាំងអ្នកឯទៀតៗ ដូចជាចៅក្រម មេធាវី សមាជិកសាខាអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។ គោលការណ៍ណែនាំ បច្ចុប្បន្នត្រូវបានរៀបចំឡើងជាសំខាន់គឺសំដៅចំពោះព្រះរាជអាជ្ញាសាធារណៈ ក៏ប៉ុន្តែគោលការណ៍ ទាំងនេះអនុវត្ត

បានដោយស្មើភាពគ្នា ក្នុងលក្ខណៈសមស្របចំពោះព្រះរាជអាជ្ញាទាំងឡាយដែលត្រូវបានតែងតាំងឡើងនៅលើមូលដ្ឋានពិសេសផងដែរ ។

## លក្ខណសម្បត្តិ ការជ្រើសរើស និងការហ្វឹកហ្វឺន

១. ជនទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាព្រះរាអាជ្ញា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុច្ចរិត និងមានសមត្ថភាព ព្រមទាំងមានការហ្វឹកហ្វឺន និងលក្ខណសម្បត្តិសមរម្យផង ។

២. រដ្ឋទាំងឡាយត្រូវធានាថា :

(ក) លក្ខណៈជ្រើសរើសព្រះរាជអាជ្ញា ត្រូវមានការការពារមិនឱ្យមានការតែងតាំងទាំងឡាយណាដែលឈរលើភាពលំអៀង ឬបុរេនិច្ឆ័យ ដោយបំបាត់ចោលនូវរាល់ការរើសអើងណាមួយ ប្រឆាំងនឹងបុគ្គលនៅលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិដើម ឋានៈសង្គម ឬជាតិពន្ធ ទ្រព្យសម្បត្តិ ដើមកំនើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត លើកលែងតែការតំរូវឱ្យបេក្ខជនសំរាប់ការិយាល័យអយ្យការនោះត្រូវតែមានសញ្ជាតិនៃប្រទេសសាម៉ីប៉ុណ្ណោះ ដែលគេមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

(ខ) ព្រះរាជអាជ្ញាត្រូវមានការអប់រំ និងការហ្វឹកហ្វឺនត្រឹមត្រូវ ហើយត្រូវអោយយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធមិនតួនាទីរបស់ខ្លួន យល់ដឹងអំពីការការពាររដ្ឋធម្មនុញ្ញនឹងច្បាប់ចំពោះសិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់ អន្តរជាតិផង ។

## ឋានៈ និងលក្ខខណ្ឌនៃសេវាកម្ម

៣. ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធមិ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលានូវកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ។

៤. រដ្ឋត្រូវធានាថា ព្រះរាជអាជ្ញាមានលទ្ធភាពអាចបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបង្អាក់ ការយាយីរំខាន ការជ្រៀតជ្រែកមិនសមស្រប ឬដាក់ឱ្យទទួលខុសត្រូវខាងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬវិស័យដទៃទៀតដោយមិនសមហេតុផល ។

៥. ព្រះរាជអាជ្ញា និងក្រុមគ្រួសាររបស់គេ ត្រូវតែមានកិច្ចការពារខាងផ្លូវកាយពីសំណាក់អាជ្ញាធរនៅពេលណាដែលសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេទទួលនូវការគំរាមកំហែង ដោយសារតែការបំពេញមុខងារជាព្រះរាជអាជ្ញានោះ ។

៦. ការកំណត់លក្ខខណ្ឌសេវាកម្មដ៏សមហេតុផលរបស់ព្រះរាជអាជ្ញា ប្រាក់ទូទាត់គ្រប់គ្រាន់ សំរាប់ការងារដែលបានធ្វើ និងនៅទីណាដែលអាចអនុវត្តបាន រយៈពេលកាន់មុខតំណែង ប្រាក់សោធន និងអាយុចូលនិវត្តន៍ ត្រូវតែមានចែងក្នុងច្បាប់ ឬវិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សាយ ។

៧. ការតម្លើងឋានៈព្រះរាជអាជ្ញា នៅទីណាក៏ដោយដែលមានប្រព័ន្ធបែបនេះ ត្រូវផ្អែកលើកត្តាសត្យានុម័តនានាជាពិសេសគឺលក្ខណសម្បត្តិខាងវិជ្ជាជីវៈ សមត្ថភាព សេចក្តីសុច្ចរិត និងបទពិសោធន៍ ហើយត្រូវសំរេចឱ្យបានស្របតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង ។

## សេរីភាពក្នុងការបញ្ចេញមតិ និងបង្កើតសមាគម

៨. ព្រះរាជអាជ្ញា ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ជំនឿ ការបង្កើតសមាគម និងការប្រជុំ ។ ជាពិសេសព្រះរាជអាជ្ញាមានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈនូវរាល់បញ្ហាដែលទាក់ទង និងច្បាប់ ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការជំរុញ និងការពារសិទ្ធិមនុស្ស ព្រមទាំងការចូលរួម ឬបង្កើតអង្គការប្រចាំតំបន់ អង្គការជាតិ ឬអន្តរជាតិ និងចូលរួមការប្រជុំរបស់គេ ដោយគ្មានការទទួលរងនូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់ ឬដោយសារសមាជិកភាពរបស់គេនៅក្នុងអង្គការស្របច្បាប់ណាមួយនោះឡើយ ។ ក្នុងការប្រើប្រាស់នូវសិទ្ធិទាំងអស់នេះ ព្រះរាជអាជ្ញាជានិច្ចជាកាលត្រូវប្រតិបត្តិខ្លួនឱ្យស្របតាមច្បាប់ និងបទដ្ឋានព្រមទាំងក្រមសីលធម៌ទាំងឡាយនៃវិជ្ជាជីវៈរបស់ខ្លួនដែលត្រូវបានគេទទួលស្គាល់ ។

៩. ព្រះរាជអាជ្ញា មានសិទ្ធិសេរីភាពក្នុងការចូលរួម និងបង្កើតសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀត ដើម្បីតំណាងឱ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការហ្វឹកហ្វឺនវិជ្ជាជីវៈ ហើយ និងដើម្បីការពារឋានៈរបស់ខ្លួន ។

## តួនាទីព្រះរាជអាជ្ញាក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ

១០. តួនាទីអយ្យការត្រូវតែចែកឱ្យដាច់ពីមុខងារតុលាការ

១១. ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងកិច្ចដំនើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តន៍ក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលការអនុវត្តន៍សាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ ។

១២. ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ និងឱ្យបានឆាប់រហ័ស ស្របតាមច្បាប់កំណត់ ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកំពស់សិទ្ធិមនុស្ស ហេតុដូច្នេះ ត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន ។

១៣. ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ :

(ក) អនុវត្តមុខនាទីរបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។

(ខ) ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។

(គ) រក្សារឿងក្តីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬបើពុំដូច្នោះទេ គឺជាតំរូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។

(ឃ) ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្ដីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដល់ជនរងគ្រោះ ដើម្បីឱ្យស្របតាមសេចក្ដីប្រកាសស្ដីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះ ក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច ។

១៤. ព្រះរាជអាជ្ញាមិនត្រូវផ្ដើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬមិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតំកល់រឿងមិនចាត់ការ នៅពេលដែលការស៊ើបអង្កេតដោយលំអៀងមួយ បង្ហាញឱ្យឃើញថា ការចោទប្រកាន់នេះពុំមានមូលដ្ឋាន ។

១៥. ព្រះរាជអាជ្ញា ត្រូវផ្ដល់ការយកចិត្តទុកដាក់លើការធ្វើបណ្ដឹងអាជ្ញាចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃៗទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយ និងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ នៅទីណាដែលមានការអនុញ្ញាត្តិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់ ។

១៦. នៅពេលណាដែលព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យ ដែលគេដឹង ឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តកម្មកាចសាហាវអមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតនោះ ព្រះរាជអាជ្ញាត្រូវបដិសេធ មិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជំរាបដល់តុ លាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថា អ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធី បែបនោះ ត្រូវបាននាំខ្លួនមកកាន់តុលាការ ។

## មុខងារឆន្ទានុសិទ្ធិ

១៧. នៅបណ្ដាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានប្រគល់ឱ្យនូវមុខការឆន្ទានុសិទ្ធិ ច្បាប់វិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សព្វផ្សាយ ត្រូវមានចែងអំពីគោលការណ៍ណែនាំដើម្បីលើកស្ទួយភាពយុត្តិធម៌ត្រឹមត្រូវ និងមិនប្រែប្រួលនៃវិធីធ្វើសេចក្ដីសំរេចនានា ក្នុងដំណើរការធ្វើបណ្ដឹងអាជ្ញា ដោយរួមទាំងការចាប់អនុវត្តន៍ ឬការលប់ចោលបណ្ដឹងអាជ្ញានោះផង ។

## ជំរើសផ្សេងៗក្នុងការធ្វើបណ្ដឹងអាជ្ញា

១៨. ស្របតាមច្បាប់ជាតិ ព្រះរាជអាជ្ញាត្រូវធ្វើការពិចារណាសមស្រប ក្នុងការលប់ចោលបណ្ដឹងអាជ្ញា បញ្ឈប់ការរឿងក្ដីដោយមានភ្ជាប់លក្ខ័ណ ឬដោយឥតលក្ខ័ណ ឬដោយបង្វែររឿងព្រហ្មទណ្ឌចេញពីប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ។ តាមគោលបំណងនេះ រដ្ឋទាំងឡាយត្រូវរិះរកលទ្ធភាពឱ្យបានពេញលេញក្នុងការអនុម័តយកតាមគំរោងការណ៍បង្វែរ ដែលមិនត្រឹមតែជួយសំរាលបន្ទុកដ៏ច្រើនលើសលប់របស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជៀសវាងបាននូវភាពអាប់យសពីការឃុំខ្លួនមុនការជំនុំជំរះក្ដីពីដីកាចោទប្រកាន់ និងពីការកាត់ឱ្យជាប់ទោស ព្រមទាំងពីផលមិនល្អដែលអាចកើតមានពីការដាក់ឱ្យជាប់ពន្ធនាគារទៀតផង ។

១៩. នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានគេផ្តល់ឱ្យនូវមុខការឆន្ទានុសិទ្ធិដូចជាការសំរេចថា តើត្រូវបណ្តឹងអាជ្ញាចំពោះយុវជនប្រព្រឹត្តបទល្មើស ឬអត់នោះ គេត្រូវតែផ្តោតការពិចារណា ពិសេស១ទាំងឡាយទៅលើប្រភេទ និងទម្ងន់នៃបទល្មើស ទៅលើកិច្ចការពារសង្គម ទៅលើបុគ្គលិកលក្ខណៈ និងសាវតារបស់យុវជននោះសិន ។ ក្នុងការធ្វើសេចក្តីសំរេចនោះ ព្រះរាជអាជ្ញា ជាពិសេសត្រូវពិចារណាអំពីជំរើសផ្សេង១ដែលអាចមាន ដើម្បីជំនួសឱ្យការធ្វើបណ្តឹង អាជ្ញាក្រោមច្បាប់ និងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធស្តីពីយុត្តិធមិសំរាប់យុវជន ។ ព្រះរាជអាជ្ញាត្រូវព្យាយាមខិតខំឱ្យអស់ ពីលទ្ធភាពរបស់ខ្លួន ក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនតែនៅពេលណាដែលចាំបាច់ជាអប្បបរិមាប៉ុណ្ណោះ ។

## ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល

២០. ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពក្នុងការធ្វើបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាត្រូវខិតខំឱ្យអស់ពីសមត្ថភាពក្នុងកិច្ចសហការជាមួយ នគរបាល តុលាការ មេធាវី អ្នកការពារក្តី សាធារណៈ ហើយ និងជាមួយក្រសួង ឬស្ថា ប័នផ្សេង១ទៀតរបស់រដ្ឋាភិបាល ។

## ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ

២១. បទល្មើសនឹងវិន័យរបស់ព្រះរាជអាជ្ញា ត្រូវផ្អែកទៅលើច្បាប់ ឬបទបញ្ជាស្របច្បាប់នានា ។ បណ្តឹងតវ៉ាប្រឆាំងនឹងព្រះរាជអាជ្ញាដែលចោទថា ព្រះរាជអាជ្ញានោះបានប្រព្រឹត្តយ៉ាងប្រត្យក្សក្នុងលក្ខណៈមួយប្រាសចាកពីបទដ្ឋានវិជ្ជាជីវៈ ត្រូវតែដោះស្រាយឱ្យបានឆាប់រហ័ស និងត្រឹមត្រូវក្រោមនីតិវិធីសមស្រប ។ ព្រះរាជអាជ្ញាមានសិទ្ធិទទួលសវនាការដ៏ត្រឹមត្រូវមួយ ។ សេចក្តីសំរេច ត្រូវស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញដែលប្រកបដោយឯករាជ្យភាព ។

២២. ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យលើព្រះរាជអាជ្ញា ត្រូវធានានូវការវាយតម្លៃ និងការសំរេចដែលមានសត្យានុម័ត ។ ការដាក់ទណ្ឌកម្ម នឹងត្រូវកំណត់សំរេចដោយស្របតាមច្បាប់ ស្របតាមបទវិន័យវិជ្ជាជីវៈ និងស្របតាមបទដ្ឋាន និងក្រមសីលធមិឯទៀតដែលបានបង្កើតឡើង ហើយ និងស្របទៅតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះផង ។

## ការប្រតិបត្តិតាមគោលការណ៍ណែនាំ

២៣. ព្រះរាជអាជ្ញាត្រូវគោរពតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះ ។ គេក៏ត្រូវបង្ការ ព្រមទាំងប្រឆាំងឱ្យបានសកម្មទល់នឹងការរំលោភណាមួយដែលកើតមាន ឱ្យអស់ពីលទ្ធភាពដែលខ្លួនអាចធ្វើទៅបានផងដែរ ។

២៤. ព្រះរាជអាជ្ញាទាំងឡាយណាដែលជឿដោយមានហេតុផលគួរជឿថា មានការរំលោភណាមួយទៅលើគោលការណ៍ណែនាំបច្ចុប្បន្នបានកើតឡើង ឬជិតនឹងកើតឡើងនោះ ត្រូវរាយការណ៍អំពីបញ្ហានោះដល់អាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយនៅទីណាដែលចាំបាច់ ត្រូវរាយការណ៍ដល់អាជ្ញាធរ ឬអង្គការសមស្របនានា ដែលត្រូវបានគេប្រគល់អំណាចឱ្យដើម្បីដោះស្រាយ ឬដើម្បីពិនិត្យមើលឡើងវិញ ។

RULE

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខ:**...០០៤៤/១៤...សរបព.ពមព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤

ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ វេលាម៉ោង៨ និង ៣០នាទី នៅវិមានសន្តិភាពមានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង ៖

**១- សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ**
**២- សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**
**៣- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា**
**៤-បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្ម និងការធ្វើឲ្យស៊ីចង្វាក់នៃនីតិវិធីគយ។

អនុវត្តតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី នាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ នីតិកាលទី៥ នៃរដ្ឋសភាកាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ ក្រសួងយុត្តិធម៌ បានដាក់ចេញការងារ ជាអាទិភាពចម្បងរបស់ខ្លួនគឺការរៀបចំសេចក្តីព្រាងច្បាប់គោលសំខាន់ៗទាំង៣ ទាក់ទងនឹងវិស័យតុលាការ ពោលគឺ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។ ការរៀបចំច្បាប់គោលទាំង៣ នេះ គឺជាការចាប់ផ្តើមដ៏សំខាន់មួយ សម្រាប់នីតិកាលទី៥ នៃរដ្ឋសភានេះលើការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាផ្នែកមួយដ៏សំខាន់នៃស្នូលយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ច្បាប់គោលទាំង៣ នេះនឹងបង្កើតបានជាមូលដ្ឋានដ៏សំខាន់ដើម្បីឈានទៅសម្រេចឲ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ។ម្យ៉ាងទៀតច្បាប់គោលទាំង៣ នេះ គឺជាច្បាប់ដែលមានចែងចង្អុលក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចាត់ទុកជាប្រភេទច្បាប់រៀបចំអង្គការដ៏មានសារៈសំខាន់ ពាក់ព័ន្ធដល់ការរៀបចំ និងការគ្រប់គ្រងដំណើរការនៃ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខៈ ០២៣ ២១២ ៤៩០, ទូរស័ព្ទៈ ០១២ ៨៨៥ [illegible] ៦០៨
អ៊ីមែលៈ pressocm@gmail.com

អំណាចតុលាការ ដែលជាអំណាចមួយក្នុងចំណោមអំណាចគ្រប់គ្រងរដ្ឋទាំង៣ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ដោយហេតុថា ច្បាប់គោលទាំង៣ នេះ មានភាពឆ្លើយឆ្លងប្រទាក់ក្រឡាគ្នាទៅវិញទៅមកដូចនេះសេចក្តីព្រាងច្បាប់ទាំង៣ នេះ ត្រូវបានរៀបចំ និងតាក់តែងឡើងព្រមពេលជាមួយគ្នា ក្នុងគោលបំណងធានាឲ្យបាននូវសង្គតិភាព និងភាពរលូនរវាងបទប្បញ្ញត្តិពាក់ព័ន្ធនានា ក៏ដូចជាដើម្បីធានាបាននូវសុខដុមនីយកម្មនៃការអនុវត្តគោលនយោបាយ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការសម្រាប់នីតិកាលទី៥ នៃរដ្ឋសភានេះ។

សេចក្តីព្រាងច្បាប់គោលទាំងបីនេះ ត្រូវបានតាក់តែងឡើងដោយផ្អែកតាមបទពិសោធន៍នៃប្រទេសដែលមាននីតិរដ្ឋរីកចម្រើនរឹងមាំនានា និងដោយមានការជួយរៀបចំពីនាក់ជំនាញការច្បាប់របស់សាធារណៈរដ្ឋបារាំង។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចអនុម័តនូវ ៖

## **១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ**

សេចក្តីព្រាងច្បាប់អង្គការតុលាការ រួមមាន៩១ មាត្រា និងចែកចេញជា០៨ ជំពូក។

គោលបំណងនៃសេចក្តីព្រាងច្បាប់នេះ គឺការធានាឯករាជ្យនៃអំណាចតុលាការ ការធានារក្សាអនាគតិ និងការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ការធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គតុលាការ និងអង្គការអយ្យការ ដើម្បីលើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស។ គោលដៅនៃសេចក្តីព្រាងច្បាប់នេះ គឺការកំណត់អំពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គការតុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ និងការកំណត់ពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ការបង្កើតឲ្យមានតុលាការជំនាញនៅតាមសាលាដំបូងនីមួយៗ។ តុលាការជំនាញទាំងនោះរួមមានតុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្ម និងតុលាការការងារ។ល។

ក្រៅពីនេះ គឺការបង្កើតឲ្យមានសភាជំនាញនៅសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់។ សភាជំនាញទាំងនោះរួមមាន សភារដ្ឋប្បវេណី សភាព្រហ្មទណ្ឌ សភាស៊ើបសួរ សភាពាណិជ្ជកម្ម និងសភាការងារ។

សេចក្តីព្រាងច្បាប់នេះ ក៏បង្កើតឲ្យមាននីតិវិធីនៃការប្តឹងសុំមោឃកម្មចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយភាគីទាំងឡាយនៃរឿងក្តី និងបុគ្គលដែលមានប្រយោជន៍ ដោយរួមទាំងតំណាងអយ្យការផង ប្រសិនបើមានហេតុដែលបំពានលើវិធានស្តីពីវិសមិតភាព។

សេចក្តីព្រាងច្បាប់នេះក៏បានបើកផ្លូវដើម្បីឲ្យមានការជំនុំជម្រះ លើបណ្តឹងសើរើឬបណ្តឹងជំនុំជម្រះសារជាថ្មីក្នុងករណីដែលមានការស្នើសុំឲ្យមានការពិនិត្យ និងការសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រ ដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**២-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួមមាន៣១មាត្រា និងចែកចេញជា ០៦ ជំពូក។

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានវិសាលភាពអនុវត្តទៅលើចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជាដោយរៀបចំឲ្យមានការទម្រង់ស៊ីជម្រៅទាំងនៅក្នុងសមាសភាព ទាំងនៅក្នុងការបំពេញភារកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយឲ្យការកែទម្រង់វិស័យយុត្តិធម៌កាន់តែមានប្រសិទ្ធភាព និងស៊ីជម្រៅស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងអភិបាលកិច្ច។

ដើម្បីធានាបាននូវអព្យាក្រឹតភាពក្នុងការអនុវត្តការងាររបស់ខ្លួន សេចក្តីព្រាងច្បាប់នេះកំណត់ថា មុខងារសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាសមាជិកជ្រើសតាំងចំនួន៨រូបក្នុងចំណោមសមាជិក១១រូប នៃក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានកំណត់អាណត្តិរយៈពេល ៥ឆ្នាំ នៅក្នុងអាណត្តិរបស់ខ្លួននោះមានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញានៅសាលាដម្រះក្តី លើកលែងតែប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកម្ពុជាកំពូល និងការបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការកំណត់អំពីគោលការណ៍វិសមិតភាពនៃមុខងារនេះ គឺជាជំហាននៃកំណែទម្រង់ដ៏ស៊ីជម្រៅក្នុងការគ្រប់គ្រងស្ថាប័នតុលាការ ដើម្បីធានាបាននូវប្រសិទ្ធភាពពិតប្រាកដនៃការងារកំណែទម្រង់លើវិស័យយុត្តិធម៌។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយដើម្បីជួយដល់កិច្ចដំណើរការរបស់ខ្លួន ជាពិសេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ។

**៣- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា**

សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញារួមមាន ១១១ មាត្រា និងចែកចេញជា០៦ ជំពូក។

សេចក្តីព្រាងច្បាប់នេះ កំណត់ពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាព្រមទាំង គោលការណ៍ផ្សេងៗទៀតទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជាលើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ។ សេចក្តីព្រាងច្បាប់នេះ កំណត់ថា បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឲ្យបំពេញមុខងារជាចៅក្រម និងព្រះរាជអាជ្ញា ត្រូវជាអ្នកមានសមត្ថភាព សុចរិត និងមានសីលធម៌ស្អាតស្អំ។៣/

សេចក្ដីព្រាងច្បាប់ ក៏កំណត់ផងដែរអំពីក្របខណ្ឌចៅក្រមដែលមាន០៣ ឋានន្តរស័ក្តិ គឺឧត្តមចៅក្រម វរៈចៅក្រម និងអនុចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺជាអ្នកសម្រេច និងលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាកពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រម។ ក្របខ័ណ្ឌព្រះរាជអាជ្ញាមានបីឋានន្តរស័ក្តិ គឺឧត្តមព្រះរាជអាជ្ញា វរៈព្រះរាជអាជ្ញា និងអនុព្រះរាជអាជ្ញា។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រពីការតែងតាំង ការផ្លាស់ប្តូរការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលប់ឈ្មោះព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់រដ្ឋមន្ត្រីរបស់ក្រសួងយុត្តិធម៌។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**៤-បញ្ហាផ្សេងៗ៖ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូនទៅសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិលើ៖** ពិធីសារនៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្ម និងការធ្វើឲ្យស៊ីសង្វាក់នៃនីតិវិធីគយ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍កោតសរសើរ និងថ្លែងអំណរគុណចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធ ក្នុងកិច្ចសហការជួយការពារក្សាសន្តិសុខសុវត្ថិភាព បានល្អជូនប្រជាពលរដ្ឋទូទាំងប្រទេសបានសប្បាយរីករាយ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ពិសេសកម្មវិធីអង្គរសង្រ្កាននៅរមណីដ្ឋានអង្គរដែលបានរៀបចំបានល្អប្រសើរដោយសហភាពសហព័ន្ធយុវជនកម្ពុជា។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២ និង០០នាទី ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥
# ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃពុធ ទី២១ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង៨:០០នាទីព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។ កូរ៉ុមដំបូងនាពេលព្រឹកនេះ មានចំនួន ៦៥រូប ។

អង្គសភាបានបន្តពិភាក្សា អនុម័តតាមរបៀបវារៈកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ និងដែលមានលទ្ធផលដូចខាងក្រោម៖

**១-ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើលិខិតសន្យាធានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស៊ីធីលុម អេសអេ សម្រាប់គម្រោង វិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការ អគិខខ្សាន់ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺ សាធារណៈនៅរាជធានី ភ្នំពេញ ។**

ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា ជាអ្នក រាយការណ៍ជូនអង្គសភា និងឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តី ព្រាងច្បាប់។ សមាជិករដ្ឋសភាមានមតិ ចំនួន០២រូបគឺ ឯកឧត្តម សួស យ៉ារ៉ា និងលោកជំទាវ ឡោក ខេង ។

សេចក្តីព្រាងច្បាប់មាន ៣មាត្រា ត្រូវបានអង្គសភាអនុម័ត យល់ព្រម ដោយសម្លេង ៦៥ នៃចំនួនសមាជិក រដ្ឋសភាទាំងមូល។



វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៩៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

**២-ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ។**

**ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភានិង **ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់។ សមាជិករដ្ឋសភាមានមតិចំនួន០២រូប **គឺឯកឧត្តម សួស យ៉ារ៉ា និង ឯកឧត្តម ឈាង វុន ។**

អង្គសភាបានធ្វើការអនុម័តសេចក្តីព្រាងច្បាប់មួយជំពូកម្តងៗ ដោយអនុម័តបានចំនួន០២ជំពូក គឺជំពូកទី១ និងជំពូកទី២។

អង្គសភាបានផ្អាកការប្រជុំនៅវេលាម៉ោង១១:៥៨នាទី និងបន្តសម័យប្រជុំទៀតនៅថ្ងៃព្រហស្បតិ៍ ទី២២ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៨:០០ព្រឹក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥

## ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង៨:០០នាទីព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តបើកសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។ **កូរ៉ុមដំបូងនាពេលព្រឹកនេះ មានចំនួន ៦៨រូប ។**

អង្គសភាបានបន្តពិភាក្សា អនុម័តតាមរបៀបវារៈ ដែលបានអនុម័តរួចហើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ដែលមានលទ្ធផលដូចខាងក្រោម៖

### ១-សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ

សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ត្រូវបាន **ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា និង **ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារ សេចក្តីព្រាងច្បាប់។ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលមាន ៨ជំពូក ៩១មាត្រា ត្រូវបានអង្គសភាអនុម័តយល់ព្រមបាន ២ជំពូក កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤។

អង្គសភាបានបន្តការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការនេះ មួយជំពូកម្តងៗ ចាប់ពីជំពូកទី៣ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៣ ចំនួន ៦៥សំឡេង នៅវេលាម៉ោង០៨:២០នាទី**

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៤ ចំនួន៦៨សំឡេង នៅវេលាម៉ោង០៨:៤៨នាទី**

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៥ ចំនួន៦៨សំឡេង នៅវេលាម៉ោង០៨:៥០នាទី**



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៦ ចំនួន ៦៨សំឡេង នៅវេលាម៉ោង០៩:១០នាទី**

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៧ ចំនួន៦៨សំឡេង នៅវេលាម៉ោង០៩:៥០នាទី**

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៨ ចំនួន៦៨សំឡេង នៅវេលាម៉ោង១០:០៨នាទី**

**-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន ៦៨សំឡេង នៅវេលាម៉ោង១០:០៩នាទី។**

សមាជិកសភា ដែលបានចូលរួមមានមតិក្នុងសេចក្តីព្រាងច្បាប់នេះចំនួន ០៣រូប មកពីគណបក្សប្រជាជនកម្ពុជា មាន **ឯកឧត្តម ឈាង វុន, ឯកឧត្តម សួស យ៉ារ៉ា និង ឯកឧត្តម គាត ឈន់។**

## ២- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

**ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា និង**ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់។ សេចក្តីព្រាងច្បាប់មានចំនួន១១១មាត្រា និងចែកចេញជា០៦ជំពូក។

អង្គសភាបានអនុម័តយល់ព្រមទទួលយកសេចក្តីព្រាងច្បាប់ មកធ្វើការពិភាក្សា និងអនុម័តដោយចំនួន ៦៨សំឡេង។

អង្គសភាបានពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញាមួយជំពូកម្តងៗ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១ ចំនួន ៦៨សំឡេង នៅវេលាម៉ោង១២:៥៩នាទី**

សមាជិកសភា ដែលបានចូលរួមមានមតិក្នុងសេចក្តីព្រាងច្បាប់នេះចំនួន ០៤រូប មកពីគណបក្សប្រជាជនកម្ពុជា មាន **ឯកឧត្តម ម៉ុក ម៉ារ៉េត, លោកជំទាវ ឡោក ខេង, ឯកឧត្តម ឈាង វុន** និង**ឯកឧត្តម សួស យ៉ារ៉ា**។

អង្គសភាបានផ្អាកការប្រជុំនៅវេលាម៉ោង១២:០០នាទី ហើយនឹងបន្តសម័យប្រជុំពេញអង្គជាបន្តទៀតនៅថ្ងៃសុក្រ ទី២៣ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៨:០០ព្រឹក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប។

**រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤**

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥
## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃសុក្រ ទី២៣ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង៨:០០នាទីព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តបើកសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។ **កូរ៉ុមដំបូងនាពេលព្រឹកនេះ មានចំនួន ៦៦រូប ។**

អង្គសភាបានបន្តពិភាក្សា និងអនុម័តតាមរបៀបវារៈ ដែលបានអនុម័តរួចហើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ និងដែលមានលទ្ធផលដូចខាងក្រោម៖

**១- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា**

សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ត្រូវបាន **ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា និង **ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់។

សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមាន ៦ជំពូក និង១១១មាត្រា ត្រូវបានអង្គសភាអនុម័តបាន ១ជំពូក កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤។

អង្គសភាបានបន្តការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា មួយជំពូកម្តងៗ ចាប់ពីជំពូកទី២ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

**-អង្គសភាបានអនុម័តយល់ព្រមជំពូកទី២ ចំនួន ៦៦សំឡេង នៅវេលាម៉ោង០៩:០៥នាទី**



វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨

ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៣ ចំនួន ៦៦សំឡេង នៅវេលាម៉ោង០៩:៣០នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៤ ចំនួន ៦៥សំឡេង នៅវេលាម៉ោង០៩:៣២នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៥ ចំនួន ៦៥សំឡេង នៅវេលាម៉ោង០៩:៣៥នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៦ ចំនួន ៦៥សំឡេង នៅវេលាម៉ោង០៩:៣៦នាទី

**-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន ៦៥សំឡេង នៅវេលាម៉ោង០៩:៥៧នាទី។**

សមាជិកសភា ដែលបានចូលរួមមានមតិក្នុងសេចក្តីព្រាងច្បាប់នេះចំនួន ០១រូប មកពីគណបក្សប្រជាជនកម្ពុជា មាន **ឯកឧត្តម ចាយ បូរិន**។

**២-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។**

**ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា** ប្រធានគណៈកម្មការ នីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា និង **ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងសហការី តំណាងរាជរដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់។

អង្គសភាបានអនុម័តយល់ព្រម ទទួលយកសេចក្តីព្រាងច្បាប់មកធ្វើការពិភាក្សា និងអនុម័តដោយចំនួន ៦៥សំឡេង ។

អង្គសភាបានពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមួយជំពូកម្តងៗ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១ ចំនួន៦៥សំឡេង នៅវេលាម៉ោង១០:២៦នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី២ ចំនួន៦៥សំឡេង នៅវេលាម៉ោង១០:៤៥នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៣ ចំនួន៦៥សំឡេង នៅវេលាម៉ោង១១:៣០នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៤ ចំនួន៦៥សំឡេង នៅវេលាម៉ោង១១:៤០នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៥ ចំនួន៦៥សំឡេង នៅវេលាម៉ោង១១:៤៣នាទី

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៦ ចំនួន៦៥សំឡេង នៅវេលាម៉ោង១១:៤៥នាទី

**-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន ៦៥សំឡេង នៅវេលាម៉ោង១១:៤៦នាទី**

សមាជិកសភា ដែលបានចូលរួមមានមតិក្នុងសេចក្តីព្រាងច្បាប់នេះចំនួន ០២រូប មកពីគណបក្សប្រជាជនកម្ពុជា មាន **ឯកឧត្តម ឡយ សុផាត** និង **ឯកឧត្តម ឈាង វុន**។

អង្គសភាបានផ្អាកការប្រជុំនៅវេលាម៉ោង១១:៥០នាទី  ចំពោះព័ត៌មានការបន្តសម័យប្រជុំពេញអង្គរដ្ឋសភា នឹងមានជម្រាបជូនដំណឹងនៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប។

**រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨**

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន
លេខ ៦៧៧/០៦១៤/អ.ពស/ខ-ម

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣
# ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នាថ្ងៃព្រហស្បតិ៍ ទី១២ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង០៨:០០ព្រឹក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា ដោយវត្តមានសមាជិកព្រឹទ្ធសភាមានចំនួន ៤៤ រូប ។ របៀបវារៈមានដូចខាងក្រោម៖

**១-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ**

**២-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា**

**៣-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

អង្គប្រជុំបានដំណើរការតាមរបៀបវារៈ និងសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**១-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ**

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ លើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស ធានាក្នុងការផ្តល់ភាពយុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ បង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងជាយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការមិនអាចខ្វះបានដល់ការចូលរួមយ៉ាងសំខាន់ក្នុងការកសាងប្រទេសជាតិឲ្យរឹងមាំផ្នែកយុត្តិធម៌សង្គម ធានាឲ្យមាននីតិរដ្ឋ លិទ្ធិប្រជាធិបតេយ្យ ការពារសិទ្ធិមនុស្ស និងប្រឆាំងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ និងរួមចំណែកជួយពង្រឹងសុវត្ថិភាពសង្គម។

ឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងសហការីអញ្ជើញមកការពារសេចក្តីព្រាងច្បាប់នេះ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន ៤៤ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**២-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា**

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពអនុវត្តន៍ចំពោះតែចៅក្រម និងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ និងជាប្រយោជន៍ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួនប្រកបដោយឯករាជ្យភាព អព្យាក្រឹតភាព និងផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់ៗគ្នា ។

ឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងសហការីអញ្ជើញមកការពារសេចក្តីព្រាងច្បាប់នេះ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន ៤៤ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**៣-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសម្រាប់ជាប្រយោជន៍ដល់ការគ្រប់គ្រងស្ថាប័នតុលាការ ដើម្បីធានានូវប្រសិទ្ធភាពពិតប្រាកដនៃការងារកែទម្រង់លើវិស័យយុត្តិធម៌ដែលមិនអាចខ្វះបាន។

ឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងសហការីអញ្ជើញមកការពារសេចក្តីព្រាងច្បាប់នេះ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន ៤៤ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការស្តីទី**

ឡោក ឆាយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៤៧/០០៤/២០១៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៤៩/០០៣/២០១៤ កបធ.ច

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៣ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៣ នាទី ។

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ក្រោយពីបានស្ដាប់សេចក្ដីរបាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្ដីពី បទប្បញ្ញត្តិទូទៅ មាន ១១ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ១១ ដែលចែងពី គោលបំណង គោលដៅ និងរចនាសម្ព័ន្ធរបស់តុលាការ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្ដីពី សាលាដំបូង និងអយ្យការអមសាលាដំបូង ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ២៣ មាត្រា គឺពីមាត្រា ១២ ដល់មាត្រា ៣៤ ដែលចែងពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាដំបូង ការបង្កើតឱ្យមានតុលាការជំនាញដូចជា តុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្មនិងតុលាការការងារ សមត្ថកិច្ចរបស់សាលាដំបូងនិងសមត្ថកិច្ចរបស់តុលាការជំនាញនីមួយៗ សមាសភាពនិងមុខងាររបស់អយ្យការអមសាលាដំបូង លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ភារកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ការតែងតាំងនិងរចនាសម្ព័ន្ធដឹកនាំលេខាធិការដ្ឋានរដ្ឋបាល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្ដីពី សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ២០ មាត្រា គឺពីមាត្រា ៣៥ ដល់មាត្រា ៥៤ ដែលចែងពី ការរៀបចំនិង

ការប្រព្រឹត្តទៅរបស់សាលាឧទ្ធរណ៍ ការបង្កើតឱ្យមានសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍តំបន់ និងសភាជំនាញនៅតាមសាលាឧទ្ធរណ៍នីមួយៗរួមមាន សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាស៊ើបសួរ សភាពាណិជ្ជកម្មនិងសភាការងារ សមាសភាពរបស់សភានីមួយៗនិងវិធានការគ្រប់គ្រងសម្រាប់ដំណើរការនៃសាលាឧទ្ធរណ៍ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ សមត្ថកិច្ចរបស់សភាជំនាញនីមួយៗនិងសមត្ថកិច្ចរបស់សភារួមក្រុម សមាសភាពនិងមុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍និងរចនាសម្ព័ន្ធដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពី តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ១៩ មាត្រា គឺពីមាត្រា ៥៥ ដល់មាត្រា ៧៣ ដែលចែងពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការកំពូល ការបង្កើតឱ្យមានសភាជំនាញនៅតុលាការកំពូល ដូចជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្មនិងសភាការងារ សមាសភាពរបស់សភានីមួយៗ វិធានការគ្រប់គ្រងនៅក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូលនិងការណែនាំសភាទាំងអស់របស់តុលាការកំពូល សមាសភាពនិងមុខងាររបស់មហាអយ្យការអមតុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលនិងរចនាសម្ព័ន្ធដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពី វិសមិតភាព មាន ០៥ មាត្រា គឺពីមាត្រា ៧៤ ដល់មាត្រា ៧៨ ដែលចែងពី មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរនិងមុខងារជំនុំជម្រះត្រូវបែងចែកដាច់ពីគ្នា គោលការណ៍ចូលរួមជំនុំជម្រះក្តីរបស់ចៅក្រម និងនីតិវិធីប្តឹងសុំមោឃកម្ម ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្តីពី ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី មាន ០១ មាត្រា គឺមាត្រា ៧៩ ដែលចែងពី កញ្ចប់ថវិការបស់សាលាដំបូងនិងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្តីពី អន្តរប្បញ្ញត្តិ មាន ១១ មាត្រា គឺពីមាត្រា ៨០ ដល់មាត្រា ៩០ ដែលចែងពី ការបន្តអានុភាពអនុវត្តនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងតុលាការយោធានិងអយ្យការអមតុលាការយោធា ព្រមទាំងចែងអំពីការរៀបចំឱ្យមានវិធានអន្តរប្បញ្ញត្តិទាក់ទងនឹងសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ

ក្នុងករណីមិនទាន់មានសាលាឧទ្ធរណ៍តំបន់ សមត្ថកិច្ចនៃសភាវិនិច្ឆ័យនៃសាលាជម្រះក្ដីជាន់ខ្ពស់ ក្នុងករណីដែលសភាពាណិជ្ជកម្មនិងសភាការងារនៃសាលាជម្រះក្ដីជាន់ខ្ពស់មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម និងសមត្ថកិច្ចរបស់តុលាការវិនិច្ឆ័យនៃសាលាជម្រះក្ដីជាន់ទាបនិងសភាវិនិច្ឆ័យនៃសាលាជម្រះក្ដីជាន់ខ្ពស់ ក្នុងករណីមិនទាន់មានសាលាជម្រះក្ដីរដ្ឋបាល និងករណីមិនទាន់មានបទប្បញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម នីតិវិធីការងារ និងនីតិវិធីរដ្ឋបាល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៨ ស្ដីពី អវសានប្បញ្ញត្តិ មាន ០១ មាត្រា គឺមាត្រា ៩១ ដែលចែងពី បទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ និង ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង៨ជំពូក ៩១មាត្រា នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៤៩/០០៦/២០១៤
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**
លេខ : ១៤៨/០០២/២០១៤ កបធ.ច
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៥ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៣ ដែលចែងពីការកំណត់គោលដៅ គោលបំណង និងវិសាលភាពនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែកចេញជា ២ ផ្នែក និងមាន ៦ មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៩ ៖

-ផ្នែកទី១ ស្តីពីសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ៤ មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៧ ដែលចែងពីសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បែបបទនិងនីតិវិធីនៃការ

បោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាណត្តិរបស់សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការជ្រើសតាំងសមាជិកសម្រាប់ជំនួសសមាជិកដែលទទួលមរណភាព ឬលាលែងពីតំណែង ឬបាត់បង់លក្ខណៈសម្បត្តិ ឬមិនអាចបំពេញមុខងាររបស់ខ្លួនបានដោយប្រការណាមួយ របៀបបទនៃការដកចេញពីមុខតំណែងចំពោះសមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម វិសមិតភាពមុខងាររបស់សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតួនាទីព្រះរាជតំណាងរបស់ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ផ្នែកទី២ ស្ដីពីអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ២ មាត្រា គឺ មាត្រា ៨ និង មាត្រា ៩ ដែលចែងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយស្ថិតនៅក្រោមរដ្ឋបាលកណ្ដាលនៃក្រសួងយុត្តិធម៌ ដើម្បីធ្វើជាសេនាធិការសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន ។ ជំពូកទី២ នេះ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៣ ស្ដីពីកិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ៨ មាត្រា គឺពីមាត្រា ១០ ដល់មាត្រា ១៧ ដែលចែងពីរបៀបបទនៃការកោះប្រជុំ និងកូរ៉ុមនៃកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នីតិវិធីនៃការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គោលការណ៍រក្សាការសម្ងាត់នៃកិច្ចប្រជុំ ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងនាមជាតំណាងឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការបង្កើតបទបញ្ជាផ្ទៃក្នុងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការកំណត់កញ្ចប់ថវិកា និងអាណាប័កទទួលសិទ្ធិ ការទទួលប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងប្រជុំ របបឧបត្ថម្ភនានា និងការប្រើប្រាស់ត្រារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្ដីពីសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែកចេញជា ២ ផ្នែក និងមាន ៩ មាត្រា គឺពី មាត្រា ១៨ ដល់មាត្រា ២៦ ៖

-ផ្នែកទី១ ស្ដីពីសមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមាន ២ មាត្រា គឺ មាត្រា ១៨ និង មាត្រា ១៩ ដែលចែងពីរបៀបបទ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ ការផ្អាកពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះចៅក្រម ការដំឡើងថ្នាក់ ការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រមនិងព្រះរាជអាជ្ញា ការផ្ដល់យោបល់លើសេចក្ដីស្នើច្បាប់ឬសេចក្ដីព្រាងច្បាប់ដែល

ទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃវិស័យតុលាការ ការពិនិត្យនិងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា

-ផ្នែកទី២ ស្ដីពីសមត្ថកិច្ចរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យចៅក្រមនិងព្រះរាជអាជ្ញាមាន ៧ មាត្រា គឺពីមាត្រា ២០ ដល់មាត្រា ២៦ ដែលចែងពីបែបបទ និងនីតិវិធីនៃការប្រជុំក្រុមប្រជុំរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្នុងការដាក់វិន័យចំពោះចៅក្រម ព្រះរាជអាជ្ញា ប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ការបង្កើតឱ្យមានក្រុមអធិការកិច្ច ដើម្បីជួយការងារក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម និងអានុភាពនៃសេចក្ដីសម្រេចរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។ ជំពូកទី៤ នេះ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៥ ស្ដីពីអន្តរប្បញ្ញត្តិ មាន ៤ មាត្រា គឺពីមាត្រា ២៧ ដល់មាត្រា ៣០ ដែលចែងពីសមាសភាពនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តការងាររបស់ខ្លួនរហូតដល់ពេលសមាសភាពថ្មីត្រូវបានតែងតាំងជាផ្លូវការ បែបបទ នីតិវិធីនិងថិរវេលានៃការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានចែងក្នុងមាត្រា ៤ ចាប់ពីចំណុចទី ៨ ដល់ចំណុចទី ១១ ការចាត់ឱ្យចៅក្រមឬព្រះរាជអាជ្ញាដែលបម្រើការងារនៅតាមសាលាជម្រះក្ដីនិងនៅតាមអង្គការអយ្យការអមសាលាជម្រះក្ដី ចុះស្រាវជ្រាវនិងស៊ើបអង្កេតលើសំណុំរឿងវិន័យសម្រាប់អំឡុងពេលដែលក្រុមអធិការកិច្ចនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមមិនទាន់ត្រូវបានតែងតាំង និងវិសមិតភាពមុខងារដែលបញ្ញត្តក្នុងមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះចៅក្រមឬព្រះរាជអាជ្ញាដែលបំពេញមុខងារក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្ដីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣១ ដែលចែងពីច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង ៦ ជំពូក ៣១ មាត្រា នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ :២៤៨/០០៥/២០១៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៤៧/០០១/២០១៤ កបធ.ច

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៤ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៤ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពី បទប្បញ្ញត្តិរួម មាន ៧ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៧ ដែលចែងពីគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ វិសាលភាពនៃការអនុវត្ត បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារជាចៅក្រមនិងព្រះរាជអាជ្ញា និងការកំណត់ដាក់ចៅក្រមនិងព្រះរាជអាជ្ញាឱ្យស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពី ចៅក្រម ចែកចេញជា ១៤ ផ្នែក និង មាន ៦៦ មាត្រា គឺពីមាត្រា ៨ ដល់មាត្រា ៧៣ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការឈប់សម្រាក ការជ្រើសរើសចៅក្រម ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះចៅក្រម កាតព្វកិច្ចចៅក្រម វិន័យកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពី ព្រះរាជអាជ្ញា ចែកចេញជា ១៤ ផ្នែក និង មាន ៣២ មាត្រា គឺពីមាត្រា ៧៤ ដល់មាត្រា ១០៥ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការសម្រាកប្រចាំឆ្នាំ ការជ្រើសរើសព្រះរាជអាជ្ញា ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះព្រះរាជអាជ្ញា កាតព្វកិច្ចព្រះរាជអាជ្ញា វិន័យកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពី វិសមិតភាព មាន ២ មាត្រា គឺមាត្រា ១០៦ និង មាត្រា ១០៧ ដែលចែងពី វិសមិតភាពមុខងាររបស់ចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពី អន្តរប្បញ្ញត្តិ មាន ៣ មាត្រា គឺពីមាត្រា ១០៨ ដល់មាត្រា ១១០ ដែលចែងពី ការធ្វើសមាហរណកម្មចៅក្រមនិងព្រះរាជអាជ្ញាក្នុងក្របខណ្ឌគ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចូលទៅក្នុងក្របខណ្ឌចៅក្រមនិងព្រះរាជអាជ្ញា តាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែចៅក្រមនៃតុលាការយោធានិងព្រះរាជអាជ្ញាអមតុលាការយោធា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្តីពី អវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ១១១ ដែលចែងពី បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទុកជានិរាករណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៦ ជំពូក ១១១ មាត្រា នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤៤៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតែងតាំង និងផ្ទេរមុខតំណែង អនុប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញារង ប្រធាន អនុប្រធាន ចៅក្រម ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង :

### I. <u>តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល</u>

| | |
|---|---|
| ១.ឯកឧត្តម **ជីវ កេង** | ប្រធានសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាអនុប្រធានតុលាការកំពូល |
| ២.ឯកឧត្តម **និល ណុន** | ប្រធានសាលាដំបូងខេត្តសៀមរាប ត្រូវបានតែងតាំងជាអនុប្រធានតុលាការកំពូល |
| ៣.ឯកឧត្តម **សេង ប៊ុនឃាង** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ត្រូវបានតែងតាំងជាអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | |
|---|---|
| ៤.លោក **ជុំ សំបាន** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពត ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល |
| ៥.លោក **សេង នាង** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូល |
| ៦.លោកស្រី **ចាំង ស៊ីណាត** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូល |
| ៧.លោកស្រី **សែម សក្តិកូឡា** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូល |
| ៨.លោក **តែ សំអាង** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូល |

II-**សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍**

| | |
|---|---|
| ៩-លោក **អិន វ៉ាន់វិបុល** | ប្រធានសាលាដំបូងខេត្តកណ្តាល ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាឧទ្ធរណ៍ |
| ១០.លោក **ស៊ិន វិសាល** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមសាលាឧទ្ធរណ៍ |
| ១១.លោក **តូ ពៅស៊ិន** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាចៅក្រមសាលាឧទ្ធរណ៍ |
| ១២.លោក **ខួន រតនា** | ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ត្រូវបានតែងតាំងជាចៅក្រមសាលាឧទ្ធរណ៍ |
| ១៣.ឯកឧត្តម **ហ៊ាន រិទ្ធិ** | ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានតែងតាំងជាអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ |
| ១៤.ឯកឧត្តម **សុខ រឿន** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ |

III-**សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

**ក. សាលាដំបូងរាជធានី-ខេត្ត**

| | |
|---|---|
| ១៥.លោក **អាំង មាលតី** | ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាប្រធានសាលាដំបូងរាជធានីភ្នំពេញ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១៦.លោក **ហុក ម៉ាន់ធីណា** អនុប្រធានសាលាដំបូងខេត្តកណ្ដាល ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តកណ្ដាល

១៧.លោក **គេខ រគេនា** ប្រធានសាលាដំបូងខេត្តកំពង់ចាម ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

១៨.លោក **នៅ យ៉ារ័ត្ន** ប្រធានសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាប្រធានសាលាដំបូងខេត្តកំពង់ចាម

១៩.លោក **ឡៅ សុថា** ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាប្រធានសាលាដំបូងខេត្តព្រះវិហារ

២០.លោក **ជា វណ្ណៈ** ចៅក្រមសាលាដំបូងខេត្តកំពង់ចាម ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តបាត់ដំបង

២១.លោក **ខួន ណារ៉ា** អនុប្រធានសាលាដំបូងខេត្តកំពត ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តសៀមរាប

២២.លោក **ងី សុខ** ចៅក្រមសាលាដំបូងខេត្តសៀមរាប ត្រូវបានតែងតាំងជាប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ

២៣.លោក **គុប ឈុនហេង** ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកោះកុង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

២៤.លោក **តាំង ស៊ុនឡាយ** ចៅក្រមសាលាឧទ្ធរណ៍ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

២៥.លោក **ស្វាយ គុញ** ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

២៦.លោក **លី សុខលេខ** ចៅក្រមសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

២៧.លោក **អ៊ឹម វណ្ណៈ** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

២៨.លោក **ម៉ុង មុនីសោភា** ចៅក្រមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

២៩.លោក **ឃី នៃ** ចៅក្រមសាលាដំបូងខេត្តស្វាយរៀង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៣០.លោក **នូ វាសនា** ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៣១.លោក **ហេង គេសរ៉េ** ចៅក្រមសាលាដំបូងខេត្តកោះកុង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៣២.លោក **រស់ ពិសិដ្ឋ** ចៅក្រមសាលាដំបូងខេត្តកំពត ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៣៣.លោក **គីម ម៉េង** ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

៣៤.លោក **សាយ សម្ផស្សរស្មី** ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

៣៥.លោក **អ៊ុំ សុវណ្ណ** ចៅក្រមសាលាដំបូងខេត្តរតនគិរី ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

៣៦.លោក **ឌី សំណាង** ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

៣៧.លោក **ស៊ិន ធិរៈ** ចៅក្រមសាលាដំបូងខេត្តកណ្ដាល ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម

៣៨.លោក **សោ សុភា** ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម

៣៩.លោក **ឆ្នាំ ប៊ុណ្ណា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

៤០.លោក **លិ សុខា** ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

៤១.លោកស្រី **រស់ ផូរ** ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់

៤២.លោក **ថោង ផល្លារឡើ** ចៅក្រមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់

៤៣.លោក **ម្លុច ធិសាល** ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

៤៤.លោក **ជួន វណ្ណៈ** ចៅក្រមសាលាដំបូងខេត្តកំពត ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

៤៥.លោក **ឯក ប៉ូលីហ៊ីល** ចៅក្រមសាលាដំបូងខេត្តរតនគិរី ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

៤៦.លោក **ម៉ែន រត្ថា** ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តតាកែវ

៤៧.លោក **សុខ ប៊ុណ្ណារិទ្ធិ** ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

៤៨.លោក **ស៊ឹម ធុន្ធី** ចៅក្រមសាលាដំបូងខេត្តតាកែវ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

| | |
|---|---|
| ៤៩.លោក **គង់ តារានាគ** | ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ |
| ៥០.លោក **អ៊ិន មុផា** | ចៅក្រមសាលាដំបូងខេត្តពោធិសាត់ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តព្រៃវែង |
| ៥១.លោក **ចុក ទូន** | ចៅក្រមសាលាដំបូងខេត្តក្រចេះ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តកំពង់ធំ |
| ៥២.លោក **ហេង ផល្លា** | ចៅក្រមសាលាដំបូងខេត្តក្រចេះ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាចៅក្រមសាលាដំបូងខេត្តស្វាយរៀង |

**ខ- អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

| | |
|---|---|
| ៥៣.លោកស្រី **ចាន់ សុរស្មី** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តក្រចេះ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ |
| ៥៤.លោក **ប៊ុ ប៊ុនហាង** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកោះកុង |
| ៥៥.លោក **ប៉ែន សារ៉ាត** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង |
| ៥៦.លោក **ច្រឹង ខ្មៅ** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តតាកែវ |
| ៥៧.លោក **មាស សុគន្ធិ** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តតាកែវ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តព្រៃវែង |
| ៥៨.លោក **កើត ចណ្ណារ៉េត** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តសៀមរាប |
| ៥៩.លោក **ទី សុខិនថាល់** | ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តក្រចេះ |
| ៦០.លោក **ឯក ឆេងហួត** | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពត |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៦១.លោក **អ៊ុត សុធា** | | ចៅក្រមសាលាដំបូងខេត្តសៀមរាប ត្រូវបានតែងតាំងជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ |
| ៦២.លោក **យុ និត្យឧត្តុនៈ** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ត្រូវបានតែងតាំងជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៦៣.លោកស្រី **ម៉ុនីញ ម៉ុណ្ណារី** | | អនុប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៦៤.លោក **កែវ សុជាតិ** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៦៥.លោក **កុល មុន** | | ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ត្រូវបានតែងតាំងជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ៦៦.លោក **ឡុង ហុកម៉េង** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល |
| ៦៧.លោក **ហេង ផេង** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តសៀមរាប ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល |
| ៦៨.លោក **សេង ម៉េងស្រ៊ុន** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង |
| ៦៩.លោក **សឿន មុនីរ័ត្ន** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រៃវែង |
| ៧០.លោក **អ៊ូ ផារត** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ |
| ៧១.លោក **សាយ ណុរ៉ា** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ |
| ៧២.លោក **មាស ឧត្តរា** | | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកោះកុង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧៣.លោក **រស់ សារ៉ាំ** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តរតនគិរី ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

៧៤.លោក **ជីម ចាន់សារា** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ចាម

IV-**<u>ចៅក្រម និងព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌</u>**

៧៥.លោក **ពេញ ទិបុល** ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ត្រូវ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារនៅក្រសួងយុត្តិធម៌

៧៦.លោក **សោ សាខុន** ប្រធានសាលាដំបូងខេត្តព្រះវិហារ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារនៅក្រសួងយុត្តិធម៌

៧៧.លោក **គី ម៉ារនេរ៉ា** ចៅក្រមសាលាដំបូងខេត្តព្រៃវែង ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារនៅក្រសួងយុត្តិធម៌

៧៨.លោក **នុប សុធនវិសុទ្ធ** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ត្រូវបានផ្ទេរមុខតំណែងឲ្យមកបំពេញការងារនៅក្រសួងយុត្តិធម៌

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវ**ទទួលបន្ទុក**អនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*នស/រកត.១៤០៤.៤៥៤*

*ន សីហមុនី*

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៤*

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៤/៤៤៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៩០៣ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការដាក់ឲ្យចូលនិវត្តន៍ចៅក្រម និងព្រះរាជអាជ្ញា ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានអនុញ្ញាតឲ្យបន្តការងារ ចំពោះចៅក្រម និងព្រះរាជអាជ្ញា ចំនួន ៤០ រូប ៖

| | |
|---|---|
| ១ - ឯកឧត្តម **ឌិត មុន្ទី** | ប្រធានតុលាការកំពូល |
| ២ - ឯកឧត្តម **ឃឹម ប៉ុណ្ណ** | អនុប្រធានតុលាការកំពូល |
| ៣ - លោក **ឌី ណោច** | ចៅក្រមតុលាការកំពូល |
| ៤ - លោក **ប្រាក់ គឹមសាន** | ចៅក្រមតុលាការកំពូល |
| ៥ - លោក **យស់ សុខឿន** | ចៅក្រមតុលាការកំពូល |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៦ - លោក **សោម សិរីវឌ្ឍ** ចៅក្រមតុលាការកំពូល
៧ - លោក **អ៊ឹម គឹមស្រ៊ី** ចៅក្រមតុលាការកំពូល
៨ - លោកស្រី **គិម សន្តាវី** ចៅក្រមតុលាការកំពូល
៩ - ឯកឧត្តម **ជូន ស៊ុនឡេង** អនុប្រធានសាលាឧទ្ធរណ៍
១០ - លោក **សំរិទ្ធ សុផល** ចៅក្រមសាលាឧទ្ធរណ៍
១១ - លោក **អ៊ុំ សារិទ្ធ** ចៅក្រមសាលាឧទ្ធរណ៍
១២ - ឯកឧត្តម **ឆិត សុទ្ធី** អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍
១៣ - លោក **ប៉ាន់ គឹមលាន** ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
១៤ - ឯកឧត្តម **ជីវ កេង** ប្រធានសាលាដំបូងរាជធានីភ្នំពេញ
១៥ - លោក **ណាយ គង់** អនុប្រធានសាលាដំបូងខេត្តសៀមរាប
១៦ - លោក **គឹម អេង** អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ
១៧ - លោក **ម្លូច ឆ្លាម** ប្រធានសាលាដំបូងខេត្តតាកែវ
១៨ - លោក **តាំ ឈាន** ប្រធានសាលាដំបូងខេត្តកំពត
១៩ - លោក **ជុំ សំបាន** ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពត
២០ - លោក **ខ្លុត ពេជ្រ** ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ
២១ - លោក **ហួន ម៉ានី** ប្រធានសាលាដំបូងខេត្តកោះកុង
២២ - លោក **ចេង ប៊ុនលី** អនុប្រធានសាលាដំបូងខេត្តកោះកុង
២៣ - លោក **នេព សុខុម** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង
២៤ - លោក **ថោង អុល** ប្រធានសាលាដំបូងខេត្តពោធិ៍សាត់
២៥ - លោក **ឃុ ឃីននី** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់
២៦ - លោកស្រី **ស៊ឹម សារម៉ី** អនុប្រធានសាលាដំបូងខេត្តកំពង់ធំ
២៧ - លោក **តាត់ គឹមសៀ** ចៅក្រមសាលាដំបូងខេត្តព្រៃវែង
២៨ - លោក **ឌុច ចន្ថា** ចៅក្រមសាលាដំបូងខេត្តព្រៃវែង
២៩ - លោក **មុច សារិន** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រៃវែង
៣០ - លោក **សំ សារុន** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្វាយរៀង
៣១ - លោក **សុខ លាន** អនុប្រធានសាលាដំបូងខេត្តក្រចេះ
៣២ - លោកស្រី **បេ គឹមយាន** ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង
៣៣ - លោក **ផាត់ ថៃ** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្ទឹងត្រែង
៣៤ - លោក **សោ សាខុន** ប្រធានសាលាដំបូងខេត្តព្រះវិហារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៣៥ - លោក **ម៉ក់ គាន** ចៅក្រមសាលាដំបូងខេត្តប៉ៃលិន

៣៦ - លោកជំទាវ **លី ឌួចឡេង** ចៅក្រមក្រសួងយុត្តិធម៌

៣៧ - លោកស្រី **ស្វាយ ស៊ីសារុន** ចៅក្រមក្រសួងយុត្តិធម៌

៣៨ - លោក **និត្យ ឫទ្ធី** ចៅក្រមក្រសួងយុត្តិធម៌

៣៩ - ឯកឧត្តម **កាន់ ឈើន** នាយកសាលាភូមិន្ទក្រឡាបញ្ជី

៤០ - ឯកឧត្តម **អ៊ុក ឡូច** នាយកសាលាភូមិន្ទអាជ្ញាសាលា

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវ**ទទួលបន្ទុក**អនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស.រកត.១៤០៤.៤៥៣

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០១៤*